កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ the messenger

ខែ មិថុនា | ឆ្នាំ ២០២១ | លេខទី ១៤០

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

JUNE, 2021 | #140

RADIO VERITAS ASIA Khmer

## សូមចូលរួមបន្តអនុវត្តវិធានការ «៣កុំ និង៣ការពារ»

ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ នៅក្នុងសហគមន៍។

### ៣កុំ

- កុំទៅកន្លែងមានមនុស្សច្រើន
- កុំចាប់ដៃគ្នា
- កុំនៅក្នុងបន្ទប់បិទជិតគ្មានខ្យល់ចេញចូល

### ៣ការពារ

- ពាក់ម៉ាស់
- រក្សាគម្លាតសង្គមនិងគម្លាតសុវត្ថិភាពបុគ្គល (១,៥ ម៉ែត្រ)
- លាងសម្អាតដៃឱ្យបានញឹកញាប់

## យើងចូលរួមចាក់វ៉ាក់សាំងកូវីដ-១៩

ដើម្បីបង្ការនូវភាពធ្ងន់ធ្ងរនៃជំងឺនិងដើម្បីសង្គ្រោះជីវិត។




វ៉ាក់សាំងកូវីដ-១៩ បានឆ្លងកាត់ការធ្វើតេស្តគ្លីនិក និងបានធ្វើការវាយតម្លៃអំពីសុវត្ថិភាពនៅគ្រប់ដំណាក់កាលទាំងអស់យ៉ាងហ្មត់ចត់។

របាយការណ៍បន្ទាន់អំពីជំងឺវីរុសកូវីដ-១៩ លេខទូរស័ព្ទ ១១៥

## WHO ជម្រុញឱ្យមានវិធានការខ្ពស់ទប់ស្កាត់កូវីដ១៩

ទំព័រ-៦



## វិបត្តិកូវីដ-១៩៖ ស្ត្រីជាកម្មករសំណង់នៅទ្រើងនិងខ្វះខាត



ទំព័រ-១០-១១

## លោកអភិបាល អូលីវីយេ ផ្ដល់ជំនួយជូនរដ្ឋបាលខេត្តតាកែវ

ទំព័រ-១៧



## ព្រះសហគមន៍ជំនួយដល់មណ្ឌលចត្តាឡីស័កស្រុករតនៈមណ្ឌល

ទំព័រ-២២



# អត្តសញ្ញាណ

គ្រប់មនុស្សទាំងអស់ដែលមានជីវិតនៅលើផែនដីនេះ សុទ្ធតែមានអត្តសញ្ញាណមួយជាសម្គាល់ មានដូចជា ពូជសាសន៍ សញ្ជាតិ ភាសា អក្សរ សាសនា ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ ពណ៌សំបុរ។ល។

តែបើបុគ្គលវិញ គឺមានភេទ អាយុ ឈ្មោះ កំពស់ សញ្ជាតិ និងដើមកំណើតរបស់ខ្លួន ។ កើតនៅឯណា? រស់នៅកន្លែងណា? មានមុខរបរអ្វី។ល។ ទាំងនោះសុទ្ធ តែជាចំណុចសម្គាល់ដែលអាចកំណត់ចំណាំអត្តសញ្ញាណ របស់បុគ្គល ក្រុមមនុស្ស។ ចំពោះវត្ថុ សត្វ និងរុក្ខជាតិក៏មានប្រហាក់ប្រហែលគ្នាដែរ។ បើមិនដូច្នោះទេ យើងនឹងវង្វេង បង្កឱ្យមានភាពច្របូកច្របល់មិនខាន។ អត្តសញ្ញាណ គឺត្រូវបានកំណត់ដោយច្បាប់ជាតិ និងអន្តរជាតិ ឬច្បាប់ធម្មជាតិ សម្រាប់សត្វ និងធម្មជាតិ។

សម្រាប់ប្រជាជនកម្ពុជា ឬជនជាតិខ្មែរ ក៏មានអត្តសញ្ញាណជាក់លាក់របស់ខ្លួនទាំងអស់ រួមទាំងភាសា ពណ៌សំបុរ របៀបរស់នៅ សាសនា វប្បធម៌ ប្រពៃណី ដែលកេរ្តិ៍ដំណែលរបស់បុព្វបុរស ដែលមានបានបន្សល់ទុកមក ដែលបានទទួលស្គាល់ក្នុងក្របខណ្ឌច្បាប់។ ចុះបើជាតិមួយបាត់អត្តសញ្ញាណរបស់ខ្លួន នោះនឹងទៅជាអ្វី? គឺជាតិសាសន៍នោះរលាយហើយ។ ដូច្នេះត្រូវស្គាល់ឱ្យបានច្បាស់សាល់អំពីខ្លួនយើង សាសនារបស់យើង វប្បធម៌របស់យើង ភាសារបស់យើង...។ល។ យើងត្រូវរួបរួមថែរក្សាកេរ្តិ៍មរតកដែលដូនតា បានបន្សល់ទុកមកឱ្យគង់វង្ស និងថែមទាំងអភិវឌ្ឍឱ្យប្រសើរឡើងផង។

### *ចុះយើងជាគ្រីស្តបរិស័ទវិញ តើយើងមានអត្តសញ្ញាណយ៉ាងដូចម្តេច នៅក្នុងអង្គព្រះគ្រីស្ត?*

មកដល់កន្លែងនេះ ចម្លើយដែលព្រះវិញ្ញាណបំភ្លឺដល់បងប្អូន នូវអ្វីដែលបានយល់ច្បាស់ និងជឿ អំពីរបៀបដែលព្រះជាម្ចាស់បានទតឃើញ និងអ្វីដែលព្រះអង្គបានមានព្រះបន្ទូលមកកាន់យើងទាំងអស់គ្នា។ ព្រះជាម្ចាស់ ជាសេចក្តីស្រលាញ់ ហើយព្រះអង្គបានស្រលាញ់មនុស្សយើងហួសពីការស្មាន។ ទាំងអស់មានចែងក្នុងព្រះគម្ពីរទាំងអស់។

តាមជំនឿ យើងបានជឿថា ព្រះជាម្ចាស់បានត្រាស់ហៅយើងម្នាក់ៗចំឈ្មោះរបស់ខ្លួន ដើម្បីឱ្យទទួលស្គាល់អត្តសញ្ញាណរបស់ខ្លួនជាបុត្រធីតារបស់ព្រះអង្គ ដោយត្រូវរួមដំណើរក្នុងព្រះយេស៊ូគ្រីស្ត ប្រកបដោយសេចក្តីស្រលាញ់។ រួមដំណើរជីវិត ក្នុងគ្រួសាររបស់ព្រះអង្គផងដែរ គឺព្រះសហគមន៍។ ព្រះសហគមន៍ជារូម កាយរបស់ព្រះគ្រីស្ត ជាប្រជារាស្ត្រ ដែលមានជីវិតយ៉ាងពិតប្រាកដ ព្រះអង្គមានវត្តមានជាយើងជានិច្ច។

ព្រះជាម្ចាស់តែងមានទំនាក់ទំនងជាមួយយើងជានិច្ច តាមរយៈការអធិដ្ឋាន អធិដ្ឋានព្រះកាយព្រះគ្រីស្ត ពេលយើងទូលអង្វររកព្រះអង្គដើម្បីការពារ និងថែរក្សា និងសូមព្រះអង្គសង្គ្រោះពេលស្ថិតក្នុងគ្រាលំបាក។ ដូច្នេះបងប្អូន នៅក្នុងគ្រាដ៏លំបាកនៃជំងឺកូវីដ១៩ កំពុងរីករាលដាល ហើយបានធ្វើឱ្យមនុស្សជាច្រើនស្លាប់។ តើព្រះជាម្ចាស់បោះបង់យើងចោល មែនទេក្នុងគ្រានេះ? មនុស្សជាច្រើនតែងចំអក ដាក់អ្នកជឿ ដែលផ្ញើជីវិតលើព្រះជាម្ចាស់។

### *ព្រឹត្តិការណ៍ក្នុងពិភពលោកយើងនេះ នឹងសំនួរដែលគេបានលើកឡើង គឺច្បាស់ណាស់បងប្អូន ដើម្បីបញ្ជាក់ម្តងទៀតអំពីជំនឿរបស់យើងជាគ្រីស្តបរិស័ទ តើយើងអាចប្រកាសជំនឿរបស់យើងយ៉ាងដូចម្តេចចំពោះសំនួរទាំងអស់នេះ?*

ម្នាក់ៗបានអានព្រះគម្ពីរ អំពីការសង្គ្រោះរបស់ព្រះម្ចាស់ ចំពោះប្រជារាស្ត្រអ៊ីស្រាអែល។ ព្រះអង្គបានចាត់លោកម៉ូសេឱ្យដឹកនាំពួកគេចេញពីប្រទេសអេហ្ស៊ីប ឱ្យរួចផុតពីការបំផ្លាញការកៀបសង្កត់ ចេញពីភាពជាទាសករ។ តែពេលពួកគេត្រូវរងទុក្ខលំបាកក្នុងវាលរហោស្ថានគេប្រមាថ គេរកវិធីផ្សេងៗ ដើម្បីថ្វាយបង្គំ និងបោះបង់ព្រះជាម្ចាស់ តែព្រះអង្គមិនបោះបង់គេឡើយ។ មានព្រឹត្តិការណ៍ជាច្រើនដែលអាចជាជំនួយក្នុងការពិចារណារបស់បងប្អូនបាន។ សំខាន់បំផុតនោះ គឺតើបងប្អូនផ្ទាល់ រកឃើញវត្តមានរបស់ព្រះជាម្ចាស់ ក្នុងជីវិតរបស់ខ្លួនយ៉ាងដូចម្តេច? បងប្អូនរក្សាអត្តសញ្ញាណរបស់ខ្លួនក្នុងអង្គព្រះគ្រីស្តយ៉ាងដូចម្តេច? សូមបងប្អូនបន្តអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានកម្លាំងឱ្យយើងម្នាក់ៗតស៊ូ ជំនះគ្រប់ការលំបាកនាពេលនេះ និងរួមគ្នាក្នុងជំនឿតែមួយផង៕



CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# កិច្ចសហប្រតិបត្តិការកម្ពុជា-អាមេរិកលើការជួញដូរមនុស្សនិងបរិស្ថាន ល្អប្រសើរ

*អត្ថបទ៖ ផល សុផានិត*

ប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក សម្រេចបានជាផ្លែផ្កាយ៉ាងល្អប្រសើរ លើកិច្ចសហប្រតិបត្តិការ លើការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

ការវាយតម្លៃរួមគ្នានេះ ធ្វើឡើងនៅក្នុងកិច្ចជំនួបពិភាក្សារវាងសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោក W. Patrick Murphy ឯកអគ្គរដ្ឋទូតវិសមញ្ញ និងពេញសមត្ថភាពរបស់សហរដ្ឋអាមេរិកប្រចាំកម្ពុជា។

នាឱកាសនោះ សម្ដេចក្រឡាហោមបានមានប្រសាសន៍ថាតាមរយៈទស្សនកិច្ចនេះដ៏មានសារៈសំខាន់នេះ នឹងបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ និងមិត្តភាពរវាងប្រទេសទាំងពីរកាន់តែខ្លាំងក្លាយថែមទៀត។

ជាមួយគ្នានេះ សម្ដេចក្រឡាហោម ក៏បានថ្លែងអំណរគុណតាមរយៈ ឯកអគ្គរដ្ឋទូត ជូនចំពោះរដ្ឋាភិបាលអាមេរិកដែលបានផ្ដល់ការគាំទ្រដល់ការងារជួយប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩នៅកម្ពុជា។



សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោក W. Patrick Murphy ឯកអគ្គរដ្ឋទូតវិសមញ្ញ និងពេញសមត្ថភាព របស់សហរដ្ឋអាមេរិកប្រចាំកម្ពុជា។ រូបភាព៖ ហ្វេសប៊ុកសម្ដេចក្រឡាហោម ស ខេង

នៅលើវិស័យអនុវត្តច្បាប់វិញ សម្ដេចក្រឡាហោម និង ឯកអគ្គរដ្ឋទូតអាមេរិក សុទ្ធតែបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការល្អលើការងារប្រយុទ្ធប្រឆាំងបទល្មើស ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសកិច្ចគាំពារកុមារ និងការអនុវត្តតាមសេចក្ដីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិ។

ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការលើការងារពាក់ព័ន្ធវិស័យបរិស្ថាន ឯកអគ្គរដ្ឋទូតអាមេរិក បានជម្រាបជូនសម្ដេចក្រឡាហោមជាបច្ចុប្បន្ននេះមានគម្រោងមួយចំនួនពាក់ព័ន្ធនឹងការងារបរិស្ថានកំពុងដំណើរការនៅកម្ពុជាក្រោម ការជួយគាំទ្ររបស់សហរដ្ឋអាមេរិក ហើយ ចង់ឃើញវឌ្ឍនភាពបន្តរីកចំរើនលើការងារទាំងនោះពាក់ព័ន្ធនឹងវិស័យបរិស្ថាននេះ។

សម្ដេចក្រឡាហោមបានមានប្រសាសន៍ថា ក្រៅពីការងារពង្រឹងកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ ភាគីទាំងពីរក៏អាចកំណត់នូវវិស័យផ្សេងៗទៀត សម្រាប់ពង្រីកកិច្ចសហប្រតិបត្តិការជាមួយគ្នា ហើយនៅក្នុងវិស័យបរិស្ថាននេះ សម្ដេចបានមានប្រសាសន៍ថារាជរដ្ឋាភិបាលកម្ពុជាតែងតែគិតគូ និងផ្ដោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការថ្លឹងថ្លែងអំពីការអភិវឌ្ឍ និងផលប៉ះពាល់ទៅលើបញ្ហាបរិស្ថាន។

សម្ដេចបានបន្ថែមថារាជរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានតែងតែចាត់ទុកអ្នកធ្វើការងារផ្នែកបរិស្ថានជាដៃគូ និងតែងតែលើកទឹកចិត្តអ្នកធ្វើការងារពាក់ព័ន្ធនឹងបញ្ហានេះ ចាត់ទុកគ្នាជាដៃគូទៅវិញទៅមក ដើម្បីដោះស្រាយបញ្ហារួមជាមួយគ្នា។

នាឱកាសនោះដែរ សម្ដេចក្រឡាហោម ក៏បានសង្កត់ធ្ងន់ដែរថា កន្លងមកក៏មានសកម្មភាពមួយចំនួនដែលបានធ្វើឡើងក្រោមហេតុផលនៃសកម្មភាពការពារបរិស្ថាន ប៉ុន្តែមានចេតនាបង្កបញ្ហាអសន្តិសុខ ប៉ះពាល់សណ្ដាប់សាធារណៈ ដែលសកម្មភាពទាំងនោះ អាជ្ញាធរមានសមត្ថកិច្ចត្រូវតែមានវិធានការសមស្របទៅតាមច្បាប់៕

# លោក ប្រាជ្ញ ចន្ទ ជាបេក្ខភាពប្រធានគ.ជ.ប

*អត្ថបទ៖ ផល សុផានិត*

គណបក្សប្រជាជនកម្ពុជា បានសម្រេចជ្រើសរើសលោក ប្រាជ្ញ ច័ន្ទ អតីតប្រធានគណៈកម្មការទី១ នៃរដ្ឋសភា ជាបេក្ខជនប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលសេចក្ដីសម្រេចនេះ បានដាក់ជូនសម័យប្រជុំពេញអង្គរដ្ឋសភារួចហើយ ដើម្បីបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្ត។ នេះបើតាមការឱ្យដឹងពីលោក ឡេង ប៉េងឡុង អ្នកនាំពាក្យរដ្ឋសភា។

នៅរសៀលថ្ងៃទី១៦ ខែមិថុនា លោក ឡេង ប៉េងឡុង អគ្គលេខាធិការ និងជាអ្នកនាំពាក្យរដ្ឋសភាបានឱ្យដឹងថា លិខិតរបស់គណបក្សប្រជាជនកម្ពុជា បានបញ្ជូនដល់រដ្ឋសភាហើយ។ អគ្គលេខាធិការរដ្ឋសភា នឹងបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីកំណត់សម័យប្រជុំពេញអង្គ ដែលអាចនឹងប្រព្រឹត្តនៅសប្ដាហ៍ក្រោយនេះ ដើម្បីបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តលើបេក្ខជន ប្រធាន គ.ជ.ប ឯកឧត្តម ប្រាជ្ញ ចន្ទ។



លោក ឡេង ប៉េងឡុង បានបន្តថា នៅថ្ងៃនេះដែរ ឯកឧត្តម ប្រាជ្ញ ចន្ទ បានដាក់ពាក្យលាលែងពី តំណែងប្រធានគណៈកម្មការទី១ និងជាសមាជិករដ្ឋសភាផងដែរ។

បន្ទាប់ពីបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ កាលពីម្សិលមិញ រដ្ឋសភាបានទទួលយកបេក្ខជន២រូប ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីដាក់ជូនគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សឈ្នះឆ្នោត ជ្រើសរើស ដើម្បីដាក់ជូនសម័យប្រជុំសភាពេញអង្គ បោះឆ្នោតផ្ដល់សេចក្ដីទុកចិត្ត។ បេក្ខជនទាំង ០២រូបនោះ រួមមានទី១.ឯកឧត្តម ប្រាជ្ញ ចន្ទ អតីតប្រធានគណៈកម្មការទី១ នៃរដ្ឋសភា និងទី២. ឯកឧត្តម ការ លាន។

ក្នុងចំណោមបេក្ខជនទាំងពីរដែលគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាអនុម័តយល់ព្រមជាបេក្ខជនឈរឈ្មោះនោះ នឹងត្រូវជ្រើសរើសយកម្នាក់ ដើម្បីកាន់តំណែងជាប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជំនួសលោក ស៊ិក ប៊ុនហុក ដែលបានដាក់ពាក្យលាលែងពីតំណែងកាលពីថ្ងៃទី១ ខែមិថុនា ដែលការលាលែងពីតំណែងជាប្រធានគ.ជ.ប របស់លោក ស៊ិក ប៊ុនហុក ដោយសារមានបញ្ហាជំងឺប្រចាំកាយ ហើយត្រូវបានគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាអនុម័តយល់ព្រមតាម សំណើ កាលពីថ្ងៃទី៤ ខែមិថុនា៕

# ក្រសួងសុខាភិបាលហាមឃាត់ការលក់ឧបករណ៍តេស្តរកអង់ទីគ័រការពារកូវីដ-១៩

*អត្ថបទ៖ ផល សុផានិត*

ក្រសួងសុខាភិបាល បានសម្រេចហាមឃាត់ការចែកចាយលក់ និងធ្វើតេស្តរហ័សរកអង់ទីគ័រការពារជំងឺកូវីដ-១៩ តាមរយៈឧបករណ៍ធ្វើតេស្តដៃគ្មានលេខបញ្ជិកា និងគ្មានការទទួលស្គាល់ពីក្រសួង។ នេះបើតាមសេចក្ដីប្រកាសព័ត៌មាននៅព្រឹកថ្ងៃទី២១ ខែមិថុនា។

ក្រសួងសុខាភិបាលបញ្ជាក់ឲ្យដឹងថា មានគណនីហ្វេសប៊ុកចំនួន៤ដែលមានឈ្មោះថា បងប្រុស, Leng Kuchnika Pol, Srey Nit និង TMS-Trust Medical Services បាននិងកំពុងផ្សព្វផ្សាយលក់តេស្តរហ័ស រកអង់ទីគ័រការពារជំងឺកូវីដ-១៩ គ្មានលេខបញ្ជិកា និងពុំមានការទទួលស្គាល់ពីក្រសួងសុខាភិបាល និងក៏មានសេវាសុខាភិបាលឯកជនមួយចំនួនទៀត ក៏កំពុងយកឧបករណ៍ទាំងនេះ ទៅធ្វើតេស្តជូនប្រជាពលរដ្ឋយ៉ាងអនាធិបតេយ្យ។



ក្រសួងសុខាភិបាល បានបញ្ជាក់ថា៖ «តេស្តរហ័សរកអង់ទីគ័រការពារជំងឺកូវីដ-១៩ ដែលកំពុងចរាចរណ៍នេះ គឺពុំមានការចុះបញ្ជិកាពីក្រសួងសុខាភិបាលនៅឡើយ ហើយក៏ពុំទាន់មានការទទួលស្គាល់ពីអង្គការសុខភាពពិភពលោក (WHO) នៅឡើយដែរ ហើយលទ្ធផលដែលបានមកពីការប្រើប្រាស់តេស្តទាំងនេះ គឺមិនអាចជឿជាក់បានឡើយ»។

ក្រសួងបានបន្ថែមថា ក្រសួងសុខាភិបាលតម្រូវឱ្យបុគ្គលទាំងអស់ និងម្ចាស់សេវាសុខាភិបាលឯកជនទាំងអស់ ត្រូវបញ្ឈប់ការផ្សព្វផ្សាយ ឬលក់ ឬប្រើប្រាស់តេស្តរហ័សទាំងនេះជាបន្ទាន់។

ដើម្បីជៀសវាងនូវការខាតបង់ប្រាក់ និងបង្កឱ្យមានភាពអនាធិបតេយ្យក្នុងសង្គម ដែលធ្វើប៉ះពាល់ដល់ គោលនយោបាយរបស់រាជរដ្ឋាភិបាលដែលកំពុងចាក់វ៉ាក់សាំងកូវីដ-១៩ នៅទូទាំងប្រទេសនោះ ក្រសួងសុខាភិបាលអំពាវនាវដល់សាធារណជនទាំងអស់ ត្រូវឈប់ជឿលើការឃោសនាកុហក បោកប្រាស់ភូតភរទាំងនោះ ដោយត្រូវបញ្ឈប់ជាបន្ទាន់ ការប្រើប្រាស់តេស្តរហ័សរកអង់ទីគ័រការពារជំងឺកូវីដ-១៩គ្មានលេខបញ្ជិកាពីក្រសួងសុខាភិបាល។

ជាមួយគ្នានេះក្រសួងសុខាភិបាលព្រមានចាត់វិធានការយ៉ាងតឹងរឹងបំផុត ចំពោះសេវាសុខាភិបាលឯកជនណា ដែលនៅតែឆ្លៀតឱកាសប្រើប្រាស់ឧបករណ៍តេស្តរហ័ស រកអង់ទីគ័រការពារជំងឺកូវីដ-១៩ នេះ ព្រមទាំងជនពាក់ព័ន្ធដទៃទៀតដែលបាននិងកំពុងបន្តផ្សព្វផ្សាយ ឬលក់តេស្តរហ័សទាំងនេះ ទៅតាមច្បាប់ដែលមានជាធរមាន៕

# វិធានថ្មីសម្រាប់រោងចក្រសហគ្រាសនៅភ្នំពេញក្នុងពេលកូវីដ១៩

*អត្ថបទ៖ ផល សុផានិត*

លោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ បានដាក់ចេញផែនការស្ដីពីវិធានការគ្រប់គ្រងការរីករាលដាលជំងឺកូវីដ-១៩ តាមបណ្ដារោងចក្រ និងសហគ្រានៅក្នុង ភូមិសាស្ត្ររាជធានីភ្នំពេញ។




យោងសេចក្ដីសម្រេចរបស់សាលារាជធានីភ្នំពេញ ចេញនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ បានឱ្យដឹងថា ផ្អែកតាមបទពិសោធន៍នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ នៅតាមបណ្ដារោងចក្រ សហគ្រាសមួយចំនួនក្នុងរាជធានីភ្នំពេញ ដែលមានការឆ្លងបន្តរាយប៉ាយនៅទីកន្លែងស្នាក់នៅរបស់បុគ្គលិក និងកម្មករ កម្មការនី និងរោងចក្រសហគ្រាសផ្សេងៗទៀត បណ្ដាលមកពី ការស្នាក់នៅរបស់បុគ្គលិក កម្មករ កម្មការនី និយោជិតច្រើនរោងចក្រ សហគ្រាស ប្រមូលផ្ដុំក្នុងផ្ទះជួល ឬអគារជួលរួមគ្នា។ ការធ្វើដំណើរដោយមធ្យោបាយរួម របស់បុគ្គលិក ដែលមិនមែនបម្រើការក្នុងរោងចក្រ សហគ្រាសតែមួយ។ ការទិញម្ហូបអាហារមិនរៀបរយ។ ការអនុវត្តមិនត្រឹមត្រូវតាមការណែនាំរបស់ក្រសួងសុខាភិបាល និង កត្តារួមផ្សំជាច្រើនទៀត។

ប្រភពដដែល បន្ថែមថា វិធានការចំពោះមុខ ដើម្បីប្រយុទ្ធ និងទប់ស្កាត់ ការរីករាលដាលជំងឺកូវីដ-១៩ ក្នុងរោងចក្រ សហគ្រាសនេះ សាលារាជធានីភ្នំពេញ បាននឹងកំពុងជំរុញការពិភាក្សារវាងក្រសួងសុខាភិបាល ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធថ្នាក់ជាតិ។ ជំរុញយុទ្ធនាការ ជាតិចាក់វ៉ាក់សាំង ការពារជំងឺកូវីដ-១៩ ជូនបុគ្គលិក កម្មករ និងកម្មការនី នៅរាជធានីភ្នំពេញ។

ប្រភពបន្ថែមថា បន្តរៀបចំច្រកសុវត្ថិភាពសម្រាប់សង្គ្រោះបន្ទាន់ រៀបចំបញ្ចូលព័ត៌មាន និងប្រព័ន្ធបញ្ចូនសម្លេងទៅគ្រប់អគារក្នុងរោងចក្រ សហគ្រាស ដើម្បីផ្សព្វផ្សាយ និងការអប់រំណែនាំបន្ថែមពីវិធានការសុខាភិបាល។ រៀបចំបន្ទប់ទទួលទានអាហារដោយឡែកៗពីគ្នា សម្អាតអនាម័យ បរិស្ថាន និងបាញ់ថ្នាំសម្លាប់មេរោគជាប្រចាំ ត្រៀមទីតាំងសមស្រប សម្រាប់ធ្វើតេស្តយកសំណាក អនុវត្តវិធានចត្តាឡីស័ក ឬព្យាបាលជំងឺកូវីដ-១៩កម្រិតស្រាល ត្រៀមឧបករណ៍តេស្តរហ័ស រកវីរុសកូវីដ-១៩ បន្តធ្វើបច្ចុប្បន្នភាពជាប្រចាំនូវបញ្ជីឈ្មោះ និងព័ត៌មានចាំបាច់របស់បុគ្គលិក និងកម្មករ និយោជិត និងវិធានការផ្សេងៗមួយចំនួនទៀត។

រដ្ឋបាលរាជធានីភ្នំពេញ បន្ថែមថា សហគ្រាស រោងចក្រ គួររៀបចំឱ្យមានហេដ្ឋារចនា សម្ព័ន្ធសមស្រប អគារបំពេញការងារស្ថិតនៅដោយឡែកពីគ្នា គួរចុះកិច្ចព្រមព្រៀងក្នុងភាពជាដៃគូជាមួយម្ចាស់ផ្ទះជួល ឬអគារស្នាក់នៅរួម ដែលមានស្ទង់ដារស់នៅសមរម្យ និងនៅជិតទីតាំងរោងចក្រ គួររៀបចំឱ្យមានមធ្យោបាយធ្វើដំណើររួមមួយត្រូវសហការជាមួយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីរៀបចំសណ្ដាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ នៅជុំវិញទីតាំងរោងចក្រ សហគ្រាសខ្លួន គួរសិក្សា និងបង្វែរមូលដ្ឋានអាជីវកម្មទៅនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស និងមធ្យោបាយមួយចំនួន។

គិតត្រឹមឆមាសទីមួយ ឆ្នាំ២០២១ នេះ នៅរាជធានីភ្នំពេញ រោងចក្រវិនិយោគមានចំនួន ៧៤៦មូលដ្ឋាន និងឧស្សាហកម្មខ្នាតតូច សិប្បកម្មមានចំនួន ៤ ៩៨៥ មូលដ្ឋាន បានបង្កើតការងារដោយផ្ទាល់ចំនួន ៤៧៦ ៣៥៩នាក់ និងដោយប្រយោលជាច្រើនសែននាក់ផ្សេងទៀត។ អនុគណៈកម្មាធិការវិនិយោគរាជធានីភ្នំពេញ បានចុះបញ្ជីស្នាពជូនរោងចក្រវិនិយោគចំនួន ៣៤មូលដ្ឋានបន្ថែមទៀត៕

# អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បំភ្លឺការអនុវត្តច្បាប់ស្ដីពីអន្តោប្រវេសន៍ ជនបរទេសខុសច្បាប់ និងការរៀបចំសណ្ដាប់ធ្នាប់តាមដងទន្លេ

*អត្ថបទ៖ ផល សុផានិត*





នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ (ឆ្វេង) អគ្គនាយកអន្តោប្រវេសន៍ និងសកម្មភាពរើលំនៅដ្ឋានបណ្ដែតទឹករបស់ប្រជាជនវៀតណាមនាពេលកន្លងមក។

អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ នៅថ្ងៃទី ១៦ ខែមិថុនា ចេញសេចក្ដីបំភ្លឺជុំវិញការអនុវត្តច្បាប់ស្ដីពីអន្តោប្រវេសន៍ ជនបរទេសខុសច្បាប់ និងការរៀបចំសណ្ដាប់ធ្នាប់តាមដងទន្លេ ជាការឆ្លើយតបនឹងមតិសារព័ត៌មាន។

យោងលិខិតរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ការគ្រប់គ្រងការតាំងទីលំនៅ និងការរៀបចំសណ្ដាប់ធ្នាប់លំនៅដ្ឋាន គឺជាតួនាទីភារកិច្ចរបស់អាជ្ញាធរដែនដី ដែលមិនស្ថិតក្រោមតួនាទីភារកិច្ច របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ឡើយ។ ភារកិច្ចស្នូលអគ្គនាយកដ្ឋាន មានតួនាទីភារកិច្ចធ្វើជាសេនាធិការជូនក្រសួងមហាផ្ទៃ លើការគ្រប់គ្រងជនបរទេស ក៏ដូចជាការអនុវត្តច្បាប់ចំពោះជនបរទេសដែលស្នាក់នៅ និងបម្រើការងារដោយខុសច្បាប់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

សេចក្ដីបំភ្លឺ បន្ថែមថា កន្លងមកអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានពង្រឹងការអនុវត្តច្បាប់ជាប្រចាំ ចំពោះជនបរទេសខុសច្បាប់តាមគ្រប់រូបភាព ដោយធ្វើការឃាត់ខ្លួនកសាងសំណុំរឿងបញ្ជូនទៅតុលាការ និងអនុវត្តការបណ្ដេញចេញពីព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ស្ដីពីអន្តោប្រវេសន៍។ ជាក់ស្ដែងចាប់តាំងពីឆ្នាំ២០១៤ រហូតដល់០៥ខែដើមឆ្នាំ២០២១នេះ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានធ្វើការបណ្ដេញជនបរទេសខុសច្បាប់ ចេញពីព្រះរាជាណាចក្រកម្ពុជា សរុបចំនួន ១៨,៤៧០នាក់ ស្រី ៣,០៦០នាក់ មាន ១០៤សញ្ជាតិ។

ប្រភពដដែលបន្ថែមថា អគ្គនាយកដ្ឋានស្នើសុំលោកនាយកសារព័ត៌មាន ផ្ដល់កិច្ចសហការតាមរយៈការផ្ដល់ព័ត៌មានជាក់លាក់អំពីជនបរទេសខុសច្បាប់ ដើម្បីអគ្គនាយកដ្ឋាន ចាត់កម្លាំងទៅធ្វើការត្រួតពិនិត្យ ស្របតាមនីតិវិធីច្បាប់។

កាលពីពេលថ្មីៗនេះ តាមរយៈបណ្ដាញទំនាក់ទំនងសង្គមហ្វេសប៊ុក កាលពីថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ លោក សយ សុភាព អគ្គនាយកសារព័ត៌មានដើមអំពិល បានលើកឡើងយ៉ាងដូច្នេះថា «សុំកុំឱ្យជានប្រវត្តិសាស្ត្ររជ្ជកាលជ័យជេដ្ឋាទី២ វិលមកវិញ ទឹកនិងគោកខៀវតែខ្មុចដូចតែគ្នា។ ត្រូវរៀនសូត្រតាមប្រទេសបិតាប្រជាធិបតេយ្យ។ បើប្រព្រឹត្តខុសច្បាប់ប្រទេស ជាប់គុកហើយបណ្ដេញចេញ ដូចជាករណី សហរដ្ឋអាមេរិក បណ្ដេញពលរដ្ឋខ្មែរកន្លងមកឬបណ្ដេញជនអន្តោប្រវេសន៍ ខុសច្បាប់ចេញ ពីប្រទេសគេ។

លោកបន្តថា៖«ថ្មីៗនេះ វៀតណាមបណ្ដេញពលរដ្ឋខ្មែរជាង១០០នាក់ត្រឡប់មកវិញដោយចោទប្រកាន់ចូលប្រទេសគេខុសច្បាប់។ និយាយពីខ្មែរវិញ ចូរខ្មែរ អានប្រវត្តិសាស្ត្រ រជ្ជកាល ព្រះស្រី សុរិយោពណ៌ ១៨០៣ ដល់ ១៨៣៥ និងរាជបុត្រ ជ័យជេដ្ឋាទី២ ដែលយួនចាប់ផ្ដើមមានឥទ្ធិពលលើខ្មែររហូតមកដោយសារមហេសី ង៉ៀនហ្គុកង៉ាន់ ឬ ព្រះនាងអង្គចូវ»។

លោកបានរំលឹកពីប្រវត្តិសាស្ត្រ ដែលយួនមកដំបូងជិះទូក មកដល់អរិយក្សត្រ នៅលើទូកមួយរយៈ បន្ទាប់មកនៅលើគោកតែម្ដង។ មិនខុសគ្នាទេរូបភាពបែបនេះ៕

# APP ថ្មី ជួយសម្រួលដល់គម្រោងថែទាំសុខភាពមាតានិងទារក

*អត្ថបទ៖ ផល សុផានិត*

ក្រសួងសុខាភិបាលសហការណ៍ ជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន (JICA) តាមរយៈ «គម្រោងលើកកម្ពស់ការថែទាំបន្តនៅកម្ពុជាផ្តោតលើការថែទាំស្ត្រី និងទារកក្នុងពេលសម្រាល និងក្រោយពេលសម្រាល (JICA-IINeoC Project)» និង Maternity Foundation បានចាប់ដៃគូសហការរួមគ្នាបង្កើតកម្មវិធីការសម្រាលកូនដោយសុវត្ថិភាពលើទូរស័ព្ទដៃជាភាសាខ្មែរ (Safe Delivery App) ដែលជាឧបករណ៍ (Tools) បណ្តុះបណ្តាល និងជំនួយស្មារតីដល់បុគ្គលិកថែទាំសុខភាព ដើម្បីធានាឲ្យបាននូវសុវត្ថិភាពសម្រាប់ម្តាយ និងទារកទើបនឹងកើតនៅក្នុងប្រទេសកម្ពុជា។

យោងសេចក្តីប្រកាសរួមរវាងក្រសួងសុខាភិបាល និង JICA នៅថ្ងៃទី៩ ខែមិថុនានេះ បញ្ជាក់ថា ទោះបីជាប្រទេសកម្ពុជាត្រូវបានគេទទួលស្គាល់ថា ជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួនដែលទទួលបានជោគជ័យ ក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់មាតា និងទារកក៏ដោយ ក៏អត្រាមរណភាពមាតានៅតែត្រូវបានគេប៉ាន់ប្រមាណថាមានចំនួន ១៦០នាក់ ក្នុងចំណោមកំណើតរស់ ១០០,០០០នាក់ និងអត្រាមរណភាពទារកមានចំនួន ២៥នាក់ក្នុងចំណោមកំណើតរស់ ១,០០០នាក់ ក្នុងឆ្នាំ២០១៧ ។ ការធ្វើឱ្យប្រសើរឡើងនូវសុខភាពមាតា និងទារកគឺជាអាទិភាពមួយរបស់រាជរដ្ឋាភិបាល។

ដើម្បីទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ និងការគាំទ្រដល់បុគ្គលិកថែទាំសុខភាព កម្មវិធីការសម្រាលកូនដោយសុវត្ថិភាពនេះ (Safe Delivery App) គឺជាឧបករណ៍ថ្មីដ៏ល្អបំផុតមួយដែលងាយស្រួលប្រើ មានប្រសិទ្ធិភាព និងប្រកបដោយភាពច្នៃប្រឌិត។ កម្មវិធីនេះ (App) បានដាក់ឲ្យប្រើប្រាស់ដោយឥតគិតថ្លៃ ហើយដំណើរការនៃការប្រើប្រាស់កម្មវិធីនេះ គឺមិនត្រូវការអ៊ីនធឺណេតទេ (Offline) វាងាយស្រួលប្រើ ហើយការណែនាំក៏មានលក្ខណៈរស់រវើក ដើម្បីណែនាំបុគ្គលិកថែទាំសុខភាពក្នុងការថែទាំបន្ទាន់ផ្នែកសម្ភព និងទារកទើបនឹងកើត ក៏ដូចជាការគ្រប់គ្រងស្ថានភាពនៅពេលអ្នកជំងឺមានផ្ទុកជំងឺ Covid-19 ។

កម្មវិធីនេះមានរួមបញ្ចូលទាំងវីដេអូ កម្រងសំណួរ ការពិពណ៌នាអំពីនីតិវិធីជាក់ស្តែង និងបញ្ជីឱសថដែលឆ្មប និងបុគ្គលិកថែទាំសុខភាពតែងតែយកជាឯកសារយោង នៅពេលបំពេញការងារ




ពេលទំនេរ ឬក៏ជាផ្នែកមួយនៃការបណ្តុះបណ្តាលរបស់ពួកគាត់។

Maternity Foundation និងគម្រោង JICA-IINeoC បាននឹងកំពុងសហការដើម្បីគាំទ្ររដ្ឋាភិបាលតាម រយៈការអភិវឌ្ឍកម្មវិធីថ្មីលើទូរស័ព្ទដៃជាភាសាខ្មែរស្តីពីការសម្រាលកូនដោយសុវត្ថិភាពតាំងពីឆ្នាំ២០២០ មកម្ល៉េះ។ អ្នកជំនាញមកពីមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក (NMCHC) សមាគមសម្ភព និងរោគស្ត្រីកម្ពុជា ទីភ្នាក់ងារ JICA និង អង្គការពាក់ព័ន្ធដទៃទៀត បានបង្កើតគណៈកម្មាធិការដើម្បីពិនិត្យយ៉ាងហ្មត់ចត់ និងស្របតាមខ្លឹមសារវេជ្ជសាស្ត្រផងដែរ។ ខ្លឹមសារនៃកម្មវិធីការសម្រាលបុត្រប្រកបដោយសុវត្ថិភាពនេះ ត្រូវបានអនុម័តដោយក្រសួងសុខាភិបាល និងប្រគល់សិទ្ធិទៅឱ្យ Maternity Foundation សម្រាប់ការអភិវឌ្ឍកម្មវិធីនេះជាភាសាខ្មែរ។

ការដាក់ចេញឲ្យប្រើប្រាស់ និងអនុវត្តកម្មវិធីនេះ (App) ជាភាសាខ្មែរ នៅទូទាំងប្រទេសបានចាប់ផ្តើមនៅឆ្នាំ ២០២១ ដែលដឹកនាំដោយគម្រោង JICA-IINeoC និងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក (NMCHC) ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរសុខាភិបាលក្នុងតំបន់ ក៏ដូចជា Maternity Foundation។

សកម្មភាពសំខាន់ៗមួយចំនួនរួមមាន ការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល និងការណែនាំអំពីកម្មវិធីលើទូរស័ព្ទដៃនេះ (App) ព្រមទាំងការត្រួតពិនិត្យ និងវាយតម្លៃដើម្បីចងក្រងឯកសារអំពីផលប៉ះពាល់ និងការចាប់យកមេរៀន ក៏ដូចជាការអនុវត្តដ៏ល្អ។ ទាំងអស់នេះ ដើម្បីធានាបាននូវការគាំទ្រដែលអាចធ្វើទៅបានដ៏ល្អបំផុត សម្រាប់បុគ្គលិកថែទាំសុខភាពដោយការប្រើនូវកម្មវិធីនេះ (App) នៅក្នុងការអនុវត្តន៍ការងារប្រចាំថ្ងៃរបស់ពួកគាត់ ដើម្បីធានាសុវត្ថិភាពនៃការសម្រាលកូនសម្រាប់មាតា និងទារកទើបនឹងកើត។

លោកស្រី Anna Frellsen នាយកប្រតិបត្តិនៃ Maternity Foundation ថ្លែងថា ៖«យើងខ្ញុំបានទន្ទឹងរង់ចាំថ្ងៃនេះ ដែលយើងទាំងអស់គ្នាទទួលបានកម្មវិធីការសម្រាលកូនដោយសុវត្ថិភាព ជាភាសាខ្មែរ (Safe Delivery App) នៅក្នុងដៃរបស់ពេទ្យឆ្មប និងអ្នកដែលមានជំនាញខាងផ្នែកបង្កើតកូនដទៃផ្សេងទៀត នៅទូទាំងប្រទេសកម្ពុជា។ ពួកគាត់បានជួយសង្គ្រោះជីវិតមនុស្សជារៀងរាល់ថ្ងៃ ហើយពួកយើងអាចជួយគាំទ្រពួកគាត់តាមរយៈកម្មវិធីការសម្រាលកូនដោយសុវត្ថិភាពជាភាសាខ្មែរនេះដែលជាការបំពេញបន្ថែមថ្មីចំពោះការងារ និងការបណ្តុះបណ្តាលរបស់ពួកគាត់ផងដែរ។ សូមថ្លែងអំណរគុណចំពោះភាពជាដៃគូដ៏អស្ចារ្យរបស់យើងខ្ញុំជាមួយនិងក្រសួងសុខាភិបាល និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)»។

លោកស្រី Kamei Haruko ប្រធានតំណាងការិយាល័យ JICA ប្រចាំប្រទេសកម្ពុជា បញ្ជាក់ថា៖ «ខ្ញុំជឿជាក់យ៉ាងមុតមាំថាកម្មវិធីការសម្រាលកូនដោយសុវត្ថិភាពនៅលើទូរស័ព្ទដៃជាភាសាខ្មែរនេះ នឹងជំរុញឲ្យបុគ្គលិកថែទាំសុខភាពធានាបាននូវការផ្តល់សេវាសម្រាលកូនដែលមានសុវត្ថិភាព និងមានភាពល្អប្រសើរជាងមុនសម្រាប់ម្តាយ និងទារកទើបនឹងកើតនៅក្នុងប្រទេសកម្ពុជា»។

កម្មវិធីនេះអាចទាញបានដោយសេរី និងឥតគិតថ្លៃនៅលើ Google Play សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទ Android៖ https://play.google.com/store/apps/details?id=dk.maternity.safedelivery&hl=en&gl=US

និងនៅក្នុង App Store សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទ iOS៖ https://apps.apple.com/dk/app/safe-delivery/id985603707

ពេលបានទាញយកកម្មវិធីហើយ ដើម្បីបានជាភាសាខ្មែរសូមធ្វើការចុច៖ Setting>>Version>>Cambodia ជាការស្រេច៕

# ស្ថាប័នពីរ សហការពន្លឿននីតិវិធី អនុវត្តការកាត់ពិន្ទុលើបណ្ណបើកបរ តាមរយៈកម្មវិធីទូរសព្ទដៃ



*អត្ថបទ៖ ផល សុផានិត*

លោកទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក (គ.ស.ច.គ) នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ នេះ បានដឹកនាំកិច្ចប្រជុំពិភាក្សាស្តីពីការរៀបចំនីតិវិធីអនុវត្តការកាត់ពិន្ទុលើបណ្ណបើកបរ ដើម្បីពង្រឹងការអនុវត្ត ច្បាប់ចរាចរណ៍ផ្លូវគោក ។

កិច្ចប្រជុំនេះក៏មានការចូលរួមពី នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងជាអនុប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក រួមទាំងថ្នាក់ដឹកនាំក្រសួង និងមន្ត្រីជំនាញបច្ចេកទេសមួយចំនួនផងដែរ។

នីតិវិធីនៃការកាត់ពិន្ទុបណ្ណបើកបរ នឹងត្រូវធ្វើឡើងតាមរយៈកម្មវិធីនៅលើទូរស័ព្ទដៃស្មាតហ្វូន ដែលអនុញ្ញាតឱ្យសមត្ថកិច្ចនគរបាលចរាចរណ៍ធ្វើការ ដកពិន្ទុបណ្ណបើកបរដោយស្វ័យប្រវត្តិ និងជូនដំណឹងទៅកាន់ស្ថាប័នចេញបណ្ណបើកបរ និងម្ចាស់បណ្ណដែលប្រព្រឹត្តខុសនឹងច្បាប់ចរាចរណ៍ផ្លូវគោក។

បច្ចុប្បន្ននេះក្រុមការងារជំនាញនៃនាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ នៃក្រសួងសាធារណការ និងដឹកជញ្ជូន បាននិងកំពុងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាមួយនេះឡើង។ កម្មវិធីនេះអាចចាប់យករូបភាពយានយន្តដែលបើកបរល្មើសនឹងច្បាប់ ដោយការស្កេនលើបណ្ណបើកបរ ដើម្បីកាត់បន្ថយពិន្ទុចំពោះអ្នកបើកបរយានយន្ត ខុសច្បាប់ទៅតាមស្ថាននៃបទល្មើស ដូចជា៖ មិនពាក់ខ្សែក្រវាត់សុវត្ថិភាព បើកបរលើសល្បឿនកំណត់ បើកបរក្នុងស្ថានភាពស្រវឹង ផ្ទុកមនុស្សលើសកំណត់ ឬល្មើសភ្លើងសញ្ញាជាដើម។

ថ្លែងក្នុងប្រជុំនេះ លោកទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល បានជំរុញលើកទឹកចិត្តឱ្យអង្គប្រជុំពិភាក្សា ផ្លាស់ប្តូរយោបល់ ផ្តល់ជាតុចូលសំខាន់ៗ ដើម្បីកែសម្រួលនីតិវិធីអនុវត្ត ការកាត់ពិន្ទុលើបណ្ណបើកបរនេះ កាន់តែប្រសើរឡើង ដើម្បីឈានដល់ការធ្វើបទបង្ហាញជូនសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក មុននឹងសម្រេចឈានទៅអនុវត្តជាក់ស្តែង។

ជាមួយគ្នានោះដែរនាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន បានប្តេជ្ញាត្រៀមសហការ និងចូលរួមជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន និងមន្ត្រីជំនាញ បច្ចេកទេស ដើម្បីអនុវត្តគំនិតផ្តួចផ្តើមនេះ ឱ្យបានជោគជ័យក្នុងការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងបានសម្តែងនូវការកោតសរសើរ និងគាំទ្រដោយស្មោះចំពោះ គំនិតផ្តួចផ្តើមនេះ ដែលជាការឆ្លុះបញ្ចាំងនូវមោទនភាពរបស់ជាតិយ៉ាងពិតប្រាកដ។

នាយឧត្តមសេនីយ៍សន្តិបណ្ឌិត ក៏បានគូសបញ្ជាក់ពីសារៈសំខាន់នៃការអប់រំផ្សព្វផ្សាយតាមគ្រប់រូបភាពទៅដល់គ្រប់ស្រទាប់មហាជនទាំងអស់ ជាពិសេសអ្នកប្រើប្រាស់ យានយន្តគ្រប់ប្រភេទ គ្រឹះស្ថានអប់រំ តាមមូលដ្ឋានគ្រប់ស្ថាប័នគ្រប់គ្រងរបស់រដ្ឋនិងឯកជន អំពីនីតិវិធីនៃការកាត់ពិន្ទុបណ្ណបើកបរតាមរយៈកម្មវិធីនៅលើទូរស័ព្ទដៃ។

គួរកត់សម្គាល់ផងដែរថា យោងតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បានកំណត់ឱ្យគ្រប់បណ្ណបើកបរត្រូវមាន ពិន្ទុសរុប១២ពិន្ទុ ហើយចំនួនពិន្ទុនេះត្រូវកាត់បន្ថយ ទៅតាមស្ថាននៃការប្រព្រឹត្តបទល្មើសចរាចរណ៍ ចាប់ពី១ពិន្ទុដល់៦ពិន្ទុ ហើយក្នុងករណីអស់ពិន្ទុ គឺបណ្ណបើកបរត្រូវទុកជាមោឃៈ បើអ្នកបើកបរចង់បានបណ្ណបើកបរថ្មី ត្រូវរៀននិងប្រឡងយកបណ្ណបើកបរឡើងវិញ ក្នុងរយៈពេលយ៉ាងតិច៦ខែ គិតចាប់ពីថ្ងៃដែលបណ្ណបើកបរត្រូវទុកជាមោឃៈ៕

# WHO ជម្រុញឲ្យមានវិធានការខ្ពស់ទប់ស្កាត់កូវីដ១៩

*អត្ថបទ៖ អមរិន្ទ ដានុត*

អង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជា (WHO) បានលើកឡើងថា កម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលសំខាន់ នៅក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ។ សកម្មភាពរួមគ្នា និងការចូលរួមរបស់សហគមន៍ទាំងមូលនៅថ្ងៃនេះ កំណត់នូវអ្វីដែលនឹងកើតឡើងនៅថ្ងៃស្អែក ដែលនឹងអាចជា ការកើនឡើងនូវចំនួនករណីឆ្លង និងចំនួនករណីស្លាប់ ឬក៏ជាការធ្លាក់ចុះនៃចំនួនករណីឆ្លង ការសង្គ្រោះជីវិត និងការវិលត្រឡប់ទៅរកជីវភាពធម្មតាតាមបែប គន្លងថ្មីមួយ។

លោកស្រីវេជ្ជបណ្ឌិត Li Ailan តំណាងអង្គការសុខភាពពិភពលោកប្រចាំកម្ពុជា បានឱ្យដឹងថា ៖ «យើងត្រូវធ្វើអ្វីៗទាំងអស់ដែលយើងអាចធ្វើទៅបាន ដើម្បីការពារការរីករាលដាលនៃមេរោគ និងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាព សង្គម និងសេដ្ឋកិច្ច។ វាចាំបាច់ណាស់ក្នុងការ ស្វែងរកមធ្យោបាយដែលមានប្រសិទ្ធភាពជាងមុន ដើម្បីធានាការអនុវត្ត និងគោរពតាមវិធានការ សុខភាពសាធារណៈ និងសង្គម ជាពិសេសតាមរយៈការចូលរួមឲ្យបានច្រើនជាងមុនរបស់ សហគមន៍គ្រប់គ្នា»។

WHOប្រចាំកម្ពុជា បានធ្វើការស្ទង់មតិ កាលពីខែឧសភា ឆ្នាំ២០២១ ដើម្បីស្វែងយល់អំពីអាកប្បកិរិយា និងការយល់ឃើញអំពីជំងឺកូវីដ-១៩ បានរកឃើញថា សហគមន៍នៅកម្ពុជាមានភាពនឿយណាយ និងយល់ឃើញថា ស្ថានភាពមានហានិភ័យកម្រិតទាប។

លោកស្រី Li Ailan បានមានប្រសាសន៍ថា៖ «លទ្ធផលរកឃើញទាំងនេះ ធ្វើឲ្យខ្ញុំព្រួយបារម្ភ។ ខ្ញុំយល់ច្បាស់ថាប្រជាពលរដ្ឋយើងមានការធុញទ្រាន់ បន្ទាប់ពីការប្រយុទ្ធប្រឆាំងនឹងវីរុសអស់រយៈពេលជាច្រើនខែមក ប៉ុន្តែយើងគ្មានជម្រើសផ្សេងទៀតទេ។ យើងត្រូវតែបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីបញ្ឈប់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ប្រជាពលរដ្ឋគ្រប់រូប មានតួនាទីសំខាន់ណាស់»។



*លោកស្រីវេជ្ជបណ្ឌិត Li Ailan (កណ្តាល) តំណាងអង្គការសុខភាពពិភពលោកប្រចាំកម្ពុជា។ រូបភាព៖ អង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជា*

លោកស្រីបានបន្តថា គោលដៅរួម គឺដើម្បីបញ្ឈប់ការរាលដាលនៃវីរុសកូវីដ-១៩ និងការពារកុំឲ្យ ជំងឺកូវីដ-១៩ បន្តរីករាលដាលនៅក្នុងសហគមន៍ទ្រង់ទ្រាយធំដែលមានផលប៉ះពាល់ធំធេង និងធ្ងន់ធ្ងរដល់ផ្នែកសុខាភិបាល សេដ្ឋកិច្ច និងសង្គម។ ដើម្បីអាចជៀសវាងបាន គ្រប់គ្នាត្រូវតែផ្តោតការយកចិត្តទុកដាក់ទៅលើប្រសិទ្ធភាពនៃអន្តរាគមន៍នានាតាមរយៈការអនុវត្ត និងគោរពតាមវិធានការ សុខភាពសាធារណៈ និងវិធានការសង្គមដែលបានដាក់ចេញ។

អង្គការដដែលនេះបានលើកឡើងទៀតថា ប្រសិនបើវីរុសរាលដាលពាសពេញសហគមន៍របស់នោះ វិធានការបិទខ្ទប់ និងការរឹតបន្តឹងទ្រង់ទ្រាយធំ អាចនឹងត្រូវដាក់ចេញ ហើយនឹងប៉ះពាល់ដល់គ្រប់វិស័យ រួមទាំងផ្នែកអាជីវកម្ម សកម្មភាពសាសនា និងការងារផងដែរ។ ការឆ្លងក្នុងសហគមន៍ទ្រង់ទ្រាយធំ នឹងធ្វើឲ្យមន្ទីរពេទ្យ និងមូលដ្ឋានសុខាភិបាល ទ្រទ្រង់លែងបាន ដែលប្រការនេះ នឹងមានន័យថាពលរដ្ឋដែលមាន ជំងឺកូវីដ-១៩ និងពលរដ្ឋដែលមានជំងឺផ្សេងៗទៀត មិនអាចទទួលបានការថែទាំដែលពួកគាត់ត្រូវការនោះទេ។

លោកស្រីវេជ្ជបណ្ឌិត Li Ailan បានឱ្យដឹងទៀតថា ៖ «ខ្ញុំយល់ពីមូលហេតុដែលបងប្អូនយើងជាច្រើនចង់ចេញទៅក្រៅ។ មនុស្សត្រូវការចំណូល។ យើងទាំងអស់គ្នាចង់ស្រូបខ្យល់អាកាសបរិសុទ្ធ ដើរជុំវិញ បរិភោគអាហារ និងទទួលទានភេសជ្ជៈនៅខាងក្រៅ និងទៅជួបមិត្តភក្តិ។ ប៉ុន្តែ ចំពោះជំងឺកូវីដ-១៩ ដែលករណីឆ្លងថ្មីនៅតែបន្តកើតឡើងរាល់ថ្ងៃ»។

អង្គការសុខភាពពិភពលោក លើកទឹកចិត្តរាជរដ្ឋាភិបាល និងដៃគូ ឲ្យពង្រឹងការប្រាស្រ័យទាក់ទងអំពីហានិភ័យជាយុទ្ធសាស្ត្រដោយផ្អែកលើភស្តុតាង និងពង្រឹងអន្តរាគមន៍ដែលជម្រុញ ការចូលរួមរបស់សហគមន៍ ដោយប្រើវេទិការ និងវិធីចម្រុះ ដើម្បីចូលទៅដល់ និងជម្រុញការចូលរួម ពីសហគមន៍ជាពិសេសពីស្ត្រី យុវជន និងអ្នកដឹកនាំសហគមន៍ ក៏ដូចជាបុគ្គលិកសុខាភិបាល៕

# កម្ពុជាស្នើទូតវៀតណាម បំពេញបែបបទបញ្ជូនពលរដ្ឋរស់នៅខុសច្បាប់នៅកម្ពុជាទៅវៀតណាមវិញ



*អត្ថបទ៖ ផល សុផានិត*

ការលើកឡើងបែបនេះបានធ្វើឡើងក្នុងជំនួបរវាង លោកនាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍ ជាមួយ លោក វូ ក្វាងមីញ ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា នារសៀលថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២១ នៅទីស្តីការអគ្គនាយកដ្ឋាន អន្តោប្រវេសន៍។

ប្រភពបញ្ជាក់ថា លោកនាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ សុំឲ្យ ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាម បន្តជម្រុញកិច្ចសហប្រតិបត្តិការ ធ្វើយ៉ាងណាបំពេញបែបបទ ដើម្បីបញ្ជូនអ្នកទាំងនោះទៅប្រទេសវៀតណាមវិញឲ្យបានឆាប់។ លោកនាយឧត្តមសេនីយ៍ បញ្ជាក់ថា កិច្ចប្រតិបត្តិការការងារគ្រប់គ្រងជនបរទេស និងការអនុវត្តន៍ច្បាប់អន្តោប្រវេសន៍នៅកម្ពុជា គឺមានមិនដែលមានការរើសអើងឡើយ។

ជាមួយគ្នានេះ លោក វូ ក្វាងមីញ Vu Quang Minh បានថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែង របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ លើការងារគ្រប់គ្រងជនបរទេស ជាពិសេសប្រជាជនវៀតណាម ដែលកំពុងស្នាក់នៅក្នុងប្រទេសកម្ពុជានាពេលកន្លងមក ក្នុងនោះរួមមាន: ការងារជំរឿនស្ថិតិជនបរទេស, ការទទួលពាក្យស្នើសុំ និងផ្តល់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ដល់ជនបរទេស និងការអនុវត្តច្បាប់អន្តោប្រវេសន៍ ជាដើម។ ទន្ទឹមនឹងនេះ ឯកឧត្តមឯកអគ្គរដ្ឋទូត ក៏បានលើកឡើងអំពីបញ្ហាប្រឈមមួយចំនួន ពាក់ព័ន្ធនឹងសិទ្ធិ និងប្រសិទ្ធភាពនៃការប្រើប្រាស់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ របស់ប្រជាជនវៀតណាមនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តផងដែរ ។

ពាក់ព័ន្ធនឹងបញ្ហាប្រឈម ដែលលោកឯកអគ្គរដ្ឋទូត វៀតណាម បានលើកឡើង លោកនាយឧត្តមសេនីយ៍ អគ្គនាយកអន្តោប្រវេសន៍ បានជម្រាបជូនថា នឹងធ្វើការសម្របសម្រួលបន្ថែមទៀត លើការងារផ្សព្វផ្សាយបទបញ្ញត្តិ ស្តីពីសិទ្ធិក្នុងការប្រើប្រាស់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ សម្រាប់ជនបរទេសនៅក្នុងប្រទេសកម្ពុជា ដល់អាជ្ញាធរមូលដ្ឋានតាមរាជធានី ខេត្ត ដើម្បីឲ្យមានការយល់ដឹង និងអនុវត្តត្រឹមត្រូវឈរលើមូលដ្ឋានច្បាប់។

ជាមួយគ្នានេះដែរ ចំពោះជនជាតិវៀតណាម ដែលរស់នៅខុសច្បាប់ ក្នុងប្រទេសកម្ពុជា លោក គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍ ក៏បានស្នើឲ្យ ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាម បន្តជម្រុញកិច្ចសហប្រតិបត្តិការ ធ្វើយ៉ាងណាបំពេញបែបបទ ដើម្បីបញ្ជូនអ្នកទាំងនោះទៅប្រទេសវៀតណាមវិញឲ្យបានឆាប់។

ដោយលោកនាយឧត្តមសេនីយ៍ អគ្គនាយកអន្តោប្រវេសន៍ បានបញ្ជាក់ដែរថា កិច្ចប្រតិបត្តិការការងារគ្រប់គ្រងជនបរទេស និងការអនុវត្តន៍ច្បាប់អន្តោប្រវេសន៍នៅកម្ពុជា គឺមានមិនដែលមានការរើសអើងឡើយ៕



# អត្តឃាត គឺជារឿងដែលយុវជនគួរតែយកចិត្តទុកដាក់!

*អត្ថបទ៖ អរិយបុត្រ*

អំពើអត្តឃាតគឺជារឿងដែលធ្ងន់ធ្ងរមួយសម្រាប់យុវជនកម្ពុជា ក៏ដូចជាយុវជននៅក្នុងតំបន់អាស៊ានទាំងមូលគួរតែយកចិត្តទុកដាក់ ពីព្រោះនៅក្នុងមួយឆ្នាំៗគេបានរកឃើញថា យុវជននៅក្នុងតំបន់នេះ ជាច្រើនបានប្រព្រឹត្តអំពើដ៏ល្ងង់ខ្លៅមួយនេះ។

កាលពីសប្តាហ៍មុន អង្គការសុខភាពពិភពលោកបានចេញផ្សាយនូវរបាយការណ៍មួយដែលខ្លួនបានសិក្សា អំពីអំពើអត្តឃាតនៅលើពិភពលោក ហើយនៅក្នុងនោះគេបានរកឃើញថា នៅក្នុងមួយឆ្នាំៗ យុវជននៅ ក្នុងតំបន់អាស៊ាន ដោយរួមទាំងកម្ពុជាផងរាប់សិបនាក់បានធ្វើអត្តឃាត។

យោងតាមរបាយការណ៍របស់ទីភ្នាក់ងារសុខភាពរបស់អង្គការសហប្រជាជាតិដែលបានសិក្សាអំពីករណីអត្តឃាតនៅក្នុងឆ្នាំ២០១៩ បានអះអាងថា ជារៀងរាល់ឆ្នាំ មានយុវជនប្រមាណជា ៧០៣.០០០ នាក់ បានប៉ុនប៉ងធ្វើអត្តឃាតដោយខ្លួនឯង។ ប្រភពដដែលបានបន្តថា ពួកគេគឺស្ថិតនៅក្នុងក្រុមអាយុ ពី១៥ ដល់ ២៩ ឆ្នាំ នៅក្នុងនោះ ពលរដ្ឋអាស៊ាន ក៏មានចំនួនខ្ពង់ប្រមាណជា ២ ម៉ឺននាក់ដែរ ។

របាយការណ៍ដដែលបានអះអាងថា នៅទូទាំងប្រទេសប្រ៊ុយណេ មានអ្នកដែលធ្វើអត្តឃាតចំនួនតែ១២ នាក់ទេតិចជាងគេ ប៉ុន្តែនៅប្រទេសឡាវ គឺមាន ៣៩០ នាក់ នៅសិង្ហបុរី មាន ចំនួន ៦៥០ នាក់ នៅកម្ពុជាយើងគឺមាន ៨០០ នាក់ ដោយនៅក្នុងនោះ គេដឹងថា មាន ប្រុស៥៦៦ នាក់ និង ស្ត្រី មាន ២៣៤ នាក់ ។ ប្រភពដដែលបានឲ្យដឹងថា កម្ពុជា គឺមានអត្រាអ្នកដែលធ្វើអត្តឃាតនេះ លំដាប់ទី៤ នៅអាស៊ាន ។

ប្រភពដដែលបានបន្តថា សម្រាប់ប្រទេសមីយ៉ានម៉ា វិញ គឺមានសរុប ១.៥៦៥ នាក់, ម៉ាឡេស៊ី មាន ១.៨២៣ នាក់, នៅប្រទេស ហ្វីលីពីន មាន ២.៣២៥ នាក់ នៅប្រទេសថៃវិញ គឺមាន ៦.១៤៧ នាក់ នៅឥណ្ឌូនេស៊ីមានសរុបចំនួន ៦.៥៤៤ នាក់ និងនៅវៀតណាម គឺមានចំនួនរហូតដល់ទៅ ៧.២៤៩ នាក់ ។

របាយការណ៍ដដែលនេះបានអះអាងថា ការសម្លាប់ខ្លួននៅលើពិភពលោក គឺឈរនៅលំដាប់លេខរៀងទី៤ នៃបុព្វហេតុនៃការស្លាប់របស់យុវជនច្រើនបំផុតនៅលើពិភពលោក បន្ទាប់ពីគ្រោះថ្នាក់ចរាចរណ៍នៅលើទ្រូងផ្លូវ ជំងឺរបេង និង អំពើហិង្សាអន្តរបុគ្គល ។ អំពើអត្តឃាត វាបានសម្លាប់មនុស្សច្រើនជាងជំងឺអេដស៍ គ្រុនចាញ់ មហារីកសុដន សង្គ្រាម ឬ ក៏ការបាញ់សម្លាប់មនុស្សទៅទៀត ។

របាយការណ៍នោះបានព្រមានទៀតថា រាល់ការធ្វើអត្តឃាតគឺជាសោកនាដកម្មដែលជះឥទ្ធិពលដល់គ្រួសារសហគមន៍ និងប្រទេសទាំងមូលនិងមានឥទ្ធិពលយូរអង្វែងលើប្រជាជនជាពិសេសគឺសេចក្តីសោកសង្រេងដែលបានបន្សល់ទុកដល់គ្រួសាររបស់ពួកគេ។

ទាក់ទងនឹងបរិបទនៃអំពើអត្តឃាតនៅក្នុងសង្គមកម្ពុជា លោក ប៉ាង រតនា ជាមន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា បានប្រាប់អ្នកសារព័ត៌មានមួយថា បញ្ហាអត្តឃាតនេហគឺជាបញ្ហាសង្គមមួយ ដែលទាំងអស់គ្នាគួរតែយកចិត្តទុកដាក់។ លោកបានបន្តថា មូលហេតុចំបងដែលបណ្តាលមានអំពើអត្តឃាតនេះនៅក្នុងសង្គមកម្ពុជាគឺបណ្តាលមកពីជំងឺបាក់ទឹកចិត្ត វិបត្តិស្នេហ៍ វិបត្តិសេដ្ឋកិច្ច សំពាធការងារ វិបត្តិគ្រួសារ ជាដើម។ល។

លោកបានបន្តថា តាមការសង្កេតផ្ទាល់ខ្លួនរបស់លោក អំពើអត្តឃាតនៅក្នុងសង្គមកម្ពុជាហាក់មានកំណើត កើនឡើងចាប់ពីរង្វង់ឆ្នាំ២០១១ មក ហើយពលរដ្ឋដែលធ្វើអត្តឃាត គឺភាគច្រើនពីចន្លោះ ១៨ ដល់ ៣០ ឆ្នាំ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក្មេងជាងនេះក៏មាន ចាស់ជាងនេះក៏មាន។

លោកបានសង្កត់ធ្ងន់ថា នេះជាបញ្ហាសង្គមដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជា ពីព្រោះវាទាក់ទងនឹងធនធានមនុស្ស ដូច្នេះ ស្ថាប័នសាធារណៈឬឯកជន សហគមន៍ឬក្រុមគ្រួសារជនរងគ្រោះត្រូវយកចិត្តទុកដាក់ដើម្បីចៀសវាងបញ្ហានេះកើតឡើងចំពោះបុគ្គលណាមួយ។

លោកបានគូសបញ្ជាក់ថា៖ «នេះគឺជាបញ្ហាសំខាន់ដែលយើងទាំងអស់គ្នាគួរតែយកចិត្តទុកដាក់ហើយគួរតែធ្វើអ្វីមួយដើម្បីការពារបញ្ហានេះនៅក្នុងសង្គមរបស់យើង»។

បច្ចុប្បន្នអង្គការសុខភាពពិភពលោកបាននិយាយថាមានតែ ៣៨ ប្រទេសប៉ុណ្ណោះដែលត្រូវបានគេដឹងថាមានយុទ្ធសាស្ត្របង្ការការធ្វើអត្តឃាតថ្នាក់ជាតិ ដោយសារតែបញ្ហានេះ អង្គការនេះ កំពុងតែជំរុញឲ្យប្រទេសនានា រៀបចំគោលនយោបាយថ្នាក់ជាតិមួយឆ្លើយតបនឹងបញ្ហានេះ។

អង្គការនេះបានអះអាងថា ការពន្លឿនយន្តការឈានទៅរកការកាត់បន្ថយការធ្វើអត្តឃាតគឺចាំបាច់ដើម្បីឆ្លើយតបទៅនឹងគោលដៅនៃការអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលបានកំណត់ការកាត់បន្ថយនៃអត្រាធ្វើអត្តឃាតឲ្យបានមួយភាគបី នៅឆ្នាំ ២០៣០៕



# WB នៅកម្ពុជា៖ សេដ្ឋកិច្ចកម្ពុជាកើនជិត ៨% ក្នុងឆ្នាំ២០២១



*អាគារពាណិជ្ជកម្មកំពុងមានការរីកចំរើនក្នុងរាជធានីភ្នំពេញ។ រូបភាព៖ ស៊ីអេសស៊ី*

*អត្ថបទ៖ ផល សុផានិត*

សេដ្ឋកិច្ចរបស់កម្ពុជា កំពុងរើបឡើងវិញបន្តិចម្តងៗហើយ ជាមួយការព្យាករណ៍ទុកថាវានឹងទទួលបានកំណើនជិត៤ភាគរយក្នុងឆ្នាំ២០២១ បន្ទាប់ពីរួញទំហំអស់៣.១ភាគរយ ក្នុងឆ្នាំ២០២០។ នេះបើតាមសេចក្តីប្រកាសព័ត៌មានរបស់ World Bank ប្រចាំកម្ពុជា នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១នេះ។

ក្នុងសេចក្តីប្រកាសព័ត៌មានបានបន្ថែមទៀតថា យ៉ាងណាក្តីការរើបឡើងវិញនេះ មានលក្ខណៈមិនដូចគ្នាទេ នៅតាមផ្នែកនានានៃសេដ្ឋកិច្ច ហើយវាក៏ស្ថិតនៅក្នុងសភាពផុយស្រួយនៅឡើយ ដែលមួយផ្នែកដោយសារតែវិធានការបិទខ្ទប់ ត្រូវបានដាក់អនុវត្តម្តងទៀត ដើម្បីទប់ស្កាត់ការរាលដាលនៃការឆ្លងវីរុសកូវីដ-១៩។

ធនាគារពិភពលោក (World Bank) បានបញ្ជាក់ដូច្នេះ នៅក្នុងរបាយការណ៍ បច្ចុប្បន្នភាពសេដ្ឋកិច្ចរបស់កម្ពុជា ក្រោមចំណងជើងថា «ដំណើរឆ្ពោះទៅការរើបឡើងវិញ»។ ខណៈដែលវិស័យមួយចំនួន មានការរីកចម្រើន ផ្នែកដទៃទៀតនៅគាំងទ្រឹង ដោយសារតែការរាតត្បាតនៃជំងឺ។

វិស័យកសិកម្ម នៅរក្សាភាពធន់បានគួរសម ដោយសារតែមានតម្រូវការខ្លាំង អមដោយការនាំចេញក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលកម្ពុជានិងចិន បានចុះហត្ថលេខាជាមួយគ្នា។ ផ្នែកឧស្សាហកម្មផលិតក៏បានរើបឡើងវិញជាបណ្តើរៗដែរ ដោយត្រូវសម្របខ្លួនទៅតាមលក្ខខណ្ឌប្រែប្រួលនៅខាងក្រៅ។

អាជីវកម្មបោះដុំ និងលក់រាយបានប្រឹងរើបឡើងវិញយឺតៗដែរ នៅពេលដែលសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកងើបឡើងវិញបន្តិចម្តង។ ផ្ទុយទៅវិញផ្នែកនានា នៃវិស័យសេវា ដូចជាផ្នែកស្នាក់នៅ, ភោជនីយដ្ឋាន និងផ្នែកដឹកជញ្ជូន នៅតែបន្តរងការប៉ះទង្គិចខ្លាំង ពីការធ្លាក់ចុះនៃទេសចរណ៍ក្នុងស្រុក និងអន្តរជាតិ។

ការវិនិយោគផ្ទាល់ពីបរទេស នៅតែហូរចូលឥតដាច់ ព្រមទាំងជួយទ្រទ្រង់ដល់វិស័យក្រៅប្រទេសផងដែរ។ ទៅមុខទៀត ចក្ខុវិស័យសម្រាប់កំណើនរបស់កម្ពុជា នៅតែប្រឈមនឹងភាពមិនប្រាកដប្រជាខ្លាំង ក្នុងនោះទ្រង់ទ្រាយ និង ល្បឿននៃដំណើររើបឡើងវិញនេះ អាស្រ័យស្ទើរតែទាំងស្រុងទៅលើសភាពរបស់វីរុស និងទៅលើល្បឿននៃការចាក់វ៉ាក់សាំងការពារ។

> កម្ពុជាបានរងការ ប៉ះទង្គិចខ្លាំង ពីការធ្លាក់ចុះនៃតម្រូវការលើសកលលោកដោយសារតែកូវីដ-១៩ ។ ប៉ុន្តែដំណឹងល្អនៅត្រង់ថា កម្ពុជាបានចាក់វ៉ាក់សាំង ឲ្យមនុស្សក្នុងប្រទេសបានជាង ៣លាននាក់រួចហើយ ដែលជាអត្រាខ្ពស់មួយនៅក្នុងតំបន់

របាយការណ៍ ក៏បានពិនិត្យមើលសេណារីយោអវិជ្ជមានដែរ ដែលក្នុងនោះអាចថា កម្មវិធីចាក់វ៉ាក់សាំងមានភាពយឺតយ៉ាវ ហើយវិធានការបិទខ្ទប់ ទូទាំងប្រទេស នៅតែមានញឹកញាប់និងអូសបន្លាយយូរ។ ក្រោមលក្ខខណ្ឌបែបនេះ សេដ្ឋកិច្ចតាមការព្យាករណ៍ នឹងមានកំណើនតែ ១ភាគរយប៉ុណ្ណោះ ក្នុងឆ្នាំ២០២១ ។

របាយការណ៍បច្ចុប្បន្នភាពនេះផ្តល់អនុសាសន៍ថា កម្ពុជាគួរតែចាត់វិធានការភ្លាមៗ ដើម្បីលើកកម្ពស់ភាពជឿជាក់របស់ទីផ្សារ តាមរយៈការពន្លឿនកម្មវិធីចាក់វ៉ាក់សាំង ទន្ទឹមគ្នានឹងការប្រឹងប្រែងទប់ស្កាត់ការឆ្លងវីរុស និង ការស្លាប់ឲ្យមានប្រសិទ្ធភាពបន្តទៀត។

ដោយសារតែកម្ពុជា នៅមានសមត្ថភាពហិរញ្ញវត្ថុល្មមដែរ រដ្ឋាភិបាលអាចបន្តការគាំទ្រដល់កម្មវិធីសង្គ្រោះ, ស្តារឡើងវិញ និងកំណើនដោយធ្វើការកែលម្អបរិយាកាស ធុរកិច្ចនិងវិនិយោគ, ផ្តល់កម្មវិធីគាំពារសង្គម និងជំរុញការវិនិយោគសាធារណៈ និងកំណើនសេដ្ឋកិច្ចដែលគិតគូរដល់អ្នកក្រីក្រ។

ដើម្បីរក្សាបានស្ថិរភាពនៃវិស័យហិរញ្ញវត្ថុ ជារឿងសំខាន់មួយដែរដែលអាជ្ញាធររដ្ឋាភិបាលត្រូវបន្តតាមដាន ឲ្យបានដិតដល់លើភាពងាយរងគ្រោះដែលអាចបណ្តាលមកពី ការពុះកញ្ជ្រោលយូរពេករបស់វិស័យអចលនទ្រព្យ និង ការផ្តល់ឥណទានកាន់តែច្រើនឡើងចំពោះវិស័យសំណង់។

លោកស្រី អ៊ិនហ្គ្លណា ដូប្រាចា ប្រធានគ្រប់គ្រងការិយាល័យធនាគាពិភពលោកប្រចាំកម្ពុជា បានថ្លែងថា «ដូចប្រទេសជាច្រើនទៀត នៅក្នុងតំបន់ដែរ កម្ពុជាបានរងការ ប៉ះទង្គិចខ្លាំង ពីការធ្លាក់ចុះនៃតម្រូវការលើសកលលោកដោយសារតែកូវីដ-១៩ ។ ប៉ុន្តែដំណឹងល្អនៅត្រង់ថា កម្ពុជាបានចាក់វ៉ាក់សាំងឲ្យមនុស្សក្នុងប្រទេសបានជាង ៣លាននាក់ រួចហើយ ដែលជាអត្រាខ្ពស់មួយនៅក្នុងតំបន់»។

លោកស្រីបានបន្ថែមទៀតថា «ធនាគារពិភពលោក នៅតែបន្តធ្វើការជាមួយកម្ពុជា ដើម្បីជួយប្រទេសនេះបន្ថែមទៀត ក្នុងការប្រយុទ្ធនឹងការឆ្លងរាតត្បាតនៃវីរុសកូវីដ-១៩ និងជួយស្តារសេដ្ឋកិច្ច និងសង្គមឲ្យមានភាពធន់រឹងមាំឡើងវិញ»។

សូមរំលឹកថា មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) កាលពីខែឧសភាកន្លងទៅនេះ បានព្យាករថា សេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ២០២១ នឹងកើនឡើងដល់៤,២%និងកើន ៦%នៅ២០២២ ។ ដោយឡែក ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)វិញ ក៏បានព្យាករកាលពីពេលថ្មីៗនេះដែរថាសេដ្ឋកិច្ចកម្ពុជានឹងមានកំណើន៤% នៅឆ្នាំ២០២១ និង៥,៥% ក្នុងឆ្នាំ២០២២ខាងមុខ៕

## កម្ពុជាទទួលចំណូលជាមធ្យម៤លានដុល្លារអាមេរិកពីការនាំចេញដំឡូងមីក្នុងមួយឆ្នាំៗ

*អត្ថបទ៖ ផល សុផានិត*

ប្រទេសកម្ពុជាទទួលបានចំណូលជាមធ្យមប្រមាញចន្លោះពី ៣,៥ ទៅ ៤លានដុល្លារអាមេរិក ពីការនាំចេញដំឡូងមីស្រស់ និងម្សៅដំឡូងមីស្ងួត ក្នុងមួយឆ្នាំ។ នេះបើតាមការបញ្ជាក់របស់លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

បើតាមការពន្យល់របស់ លោក វេង សាខុន បានបញ្ជាក់ថា៖ «បច្ចុប្បន្ន កម្ពុជាបានចាត់ទុកដំឡូងមីគឺជាដំណាំសំខាន់ទី២ បន្ទាប់ពីដំណាំស្រូវសម្រាប់ផ្គត់ផ្គង់ឲ្យទីផ្សារក្នុងស្រុក (ផលិតអាហារមនុស្ស និងសត្វ) និងនាំចេញ (ស្រស់ ចំណិតក្រៀម និងជាម្សៅ)។ យោងលើរបាយការណ៍របស់អគ្គនាយកដ្ឋានកសិកម្ម (១៦/៦/២០២១) បានឲ្យដឹងថា នៅឆ្នាំ២០២០ កម្ពុជាមានផ្ទៃដីដាំដុះដំឡូងមីសរុបចំនួន ៦៦៣ ៩២៩ហត បរិមាណផលសរុបចំនួន ១២ ៦៨០ ៩៨៧តោន និងទទួលបានទិន្នផលជាមធ្យមចំនួន ២០,៥៥តោនក្នុង១ហិកតា។ ក្រៅពីការ ប្រើប្រាស់ក្នុងស្រុក កម្ពុជាបាននាំចេញដំឡូងមីស្រស់ ម្សៅដំឡូងមី ចំណិតដំឡូងមីស្ងួតគិតជាទឹកប្រាក់ប្រមាណពី ៣,៥០ ទៅ ៤ លានដុល្លារក្នុងមួយឆ្នាំ»។

លោករដ្ឋមន្ត្រីបន្ថែមថា ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ផលិតកម្មដំឡូងមីមានការកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងតំបន់ ធ្វើឲ្យផ្ទៃដីដាំដុះនៅក្នុងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ក៏មានការកើនឡើងគួរឲ្យកត់សម្គាល់ផងដែរ។



ថ្មីៗនេះគោលនយោបាយ ដំឡូងមីជាតិថ្មី ត្រូវបានកំណត់ ដើម្បីជំរុញផលិតកម្ម និងនាំចេញដំឡូងមីកម្ពុជា។ ដាក់ចេញដោយក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP)គាំទ្រ គោលនយោបាយជាតិសំខាន់រហូតដល់ឆ្នាំ២០២៥។

គោលនយោបាយជាតិថ្មី ត្រូវបានបង្កើតឡើងដោយក្រុមការងារដំឡូងមីរបស់រដ្ឋាភិបាល និងត្រូវបានអនុម័តដោយ រាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី ១៤ ខែសីហាឆ្នាំ ២០២០។

ការដាក់ចេញនូវគោលនយោបាយនេះ បង្ហាញពីការចាប់ផ្តើម នៃដំណើរថ្មីមួយនៅក្នុងការអភិវឌ្ឍវិស័យកសិពាណិជ្ជកម្ម ក្នុងប្រទេសកម្ពុជាសម្រាប់កំណើនបញ្ចូលគ្នា ការកាត់បន្ថយភាពក្រីក្រ និង ការសំរេចបាននូវគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ២០១៥-២០២៥៕

# ក្រសួងទេសចរណ៍ និងដៃគូអភិវឌ្ឍន៍បណ្តុះបណ្តាលគ្រូបង្គោល សេវាកម្មម្ហូបអាហារ និងភេសជ្ជៈ សម្រាប់ខេត្តភាគឦសាន

*អត្ថបទ៖ ផល សុផានិត*

ក្រសួងទេសចរណ៍ តាមរយៈគណៈកម្មការគ្រប់គ្រងគម្រោង ហូកា (គ.គ.ហ.) បានសហការជាមួយអង្គការស្វីសខន់ថាក់ បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ សម្រាប់ខេត្តនៅភាគឦសាន តាមប្រព័ន្ធវីដេអូអនឡាញ។ កាបណ្តុះបណ្តាលនេះមានរយៈពេល ៦ ថ្ងៃ ចាប់ពីថ្ងៃទី៧-១២ ខែមិថុនា ឆ្នាំ២០២១ ។




ពិធីបើកវគ្គបណ្តុះបណ្តាលខាងលើ ធ្វើឡើងក្រោមវត្តមានលោក ប៉ាក់ សុខុម រដ្ឋលេខាធិការក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មការគ្រប់គ្រងគម្រោង ហូកា (គ.គ.ហ.) លោក Christian Volker Ide ប្រធានកម្មវិធីអភិវឌ្ឍន៍ជំនាញ នៃអង្គការស្វីសខន់ថាក់ លោក ជួប រតនា ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រងគម្រោង ហូកា លោកប្រធានមន្ទីរទេសចរណ៍ខេត្តរនតគិរី ក្រចេះ ស្ទឹងត្រែង ព្រះវិហា និងមណ្ឌលគិរី និងលោក ស្រូ រិទ្ធី គ្រូបង្គោលអាស៊ាន។

លោក ប៉ាក់ សុខុម បានឱ្យដឹងថា ដើម្បីធ្វើឱ្យវិស័យទេសចរណ៍កាន់តែមានភាពធន់នឹងវិបត្តិ (Resilient) រាជរដ្ឋាភិបាលបានអនុម័តនូវផែនទីចង្អុលផ្លូវ (Roadmap) ស្តីពីការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ២០២០-២០២៥ ដែលនឹងក្លាយជាត្រីវិស័យ និងជាផែនការយុទ្ធសាស្ត្រមួយដ៏សំខាន់ ដើម្បីធានាដាក់ចេញធានការអន្តរាគមន៍ទាន់ពេលវេលា សំដៅប្រែក្លាយវិបត្តិជំងឺកូវីដ-១៩ ទៅជាកាលានុវត្តភាពសម្រាប់កែទម្រង់ក្នុងវិស័យទេសចរណ៍កម្ពុជា ឲ្យក្លាយជាគោលដៅទេសចរណ៍គុណភាព សុវត្ថិភាព និងនិរន្តរភាព ដោយទាញមកវិញនូវចំនួនភ្ញៀវទេសចរអន្តរជាតិ និងជំរុញសកម្មភាពទេសចរណ៍ក្នុងស្រុក។

លោករដ្ឋលេខាធិការបានបន្តថា ការបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ គឺជាធាតុដ៏សំខាន់មួយរបស់ផែនទីចង្អុលផ្លូវស្តីពីការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ឆ្នាំ២០២០-២០២៥ ក្នុងនោះសកម្មភាពសំខាន់នៅក្នុងមុំបណ្តុះបណ្តាវិជ្ជាជីវៈទេសចរណ៍

នេះជាដំណាក់កាលទី២ហើយ (ឆ្នាំ២០២០-២០២៤) ដែលក្រសួងទេសចរណ៍ និងអង្គការស្វីសខន់ថាក់ បានសហការគ្នាបណ្តុះបណ្តាលដល់ខេត្តគោលដៅចម្បងចំនួន ២ ទៀត នៅភូមិភាគឦសាន រួមមានខេត្តរតនគិរី និងមណ្ឌលគិរី ដែលបច្ចុប្បន្នជាគោលដៅអេកូទេសចរណ៍ដ៏មានសក្តានុពល ជាពិសេសក្នុងបរិទនៃការអភិវឌ្ឍន៍ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី និងផែនការអភិវឌ្ឍន៍ទេសចរណ៍ តំបន់ត្រីកោណអភិវឌ្ឍន៍ (CLV DTA) ដែលថ្នាក់ដឹកនាំកំពូលនៃប្រទេសកម្ពុជា ឡាវ និងវៀតណាម ទើបបានអនុម័តនៅអំឡុងខែធ្នូ ឆ្នាំ២០២០ ថ្មីៗនេះ ក្នុងនោះក្រសួងបានព្យាករណ៍ថា នឹងមានកំណើនវិនិយោគលើសម្បទាទេសចរណ៍នានាកាន់តែច្រើន ដែលធ្វើឲ្យតម្រូវការអ្នកជំនាញក៏នឹងមានការកើនឡើងផងដែរ។



លោក ប៉ាក់ សុខុម បានបន្តទៀតថា តាមរយៈយន្តការគណៈកម្មការគ្រប់គ្រងគម្រោង ហូកា ដែលជាយន្តការស្នូលនៃកិច្ចសហប្រតិបត្តិការ និងការពង្រឹងយន្តការការងារទាំងថ្នាក់ជាតិ និងក្រោមជាតិក្នុងការអនុវត្តគម្រោងបណ្តុះបណ្តាលបដិសណ្ឋារកិច្ចកម្ពុជា (HoKa) កម្ពុជានឹងសម្រេចបានលទ្ធផលល្អប្រសើរបន្ថែមទៀត ដែលចូលរួមចំណែកដល់វិស័យទេសចរណ៍កម្ពុជា និងការពង្រឹងជំនាញវិជ្ជាជីវៈទេសចរណ៍ ដូចដែលលោក ថោង ខុង រដ្ឋមន្ត្រីក្រសួងទេសចរណ៍ តែងលើកឡើងថា «ជំនាញវិជ្ជាជីវៈទេសចរណ៍ ជាអាយុជីវិតរបស់អ្នក (Tourism Skills Is your Life)»៕












# វិបត្តិកូវីដ-១៩៖

# ស្ត្រីជាកម្មករសំណង់ នៅទ្រឹង និងខ្វះខាត





*អត្ថបទ៖ ផល សុផានិត*

ស្របពេលដែលអគារខ្ពស់ៗ ផ្សារទំនើប សណ្ឋាគារ ផ្ទះល្វែង វីឡា ឬក៏ខុនដូជាដើម ត្រូវបាននៅទ្រឹង មិនមានសកម្មភាពក្នុងដំណើរការសាងសង់ ជារៀងរាល់ថ្ងៃដូចមុនពេកមានព្រឹត្តិការណ៍សហគមន៍២០កុម្ភៈកើតឡើង កំណើននេះក៏បានបង្ហាញឱ្យឃើញថាវិស័យសំណង់នៅកម្ពុជាហាក់នៅស្ងៀមស្ងាត់គួរឱ្យកត់សម្គាល់។ ដែលនេះជាកត្តាមួយដែលធ្វើឱ្យសេដ្ឋកិច្ចកម្ពុជានៅទ្រឹង។

កាលពីពេលកន្លងទៅនេះ ធនាគារពិភពលោកបានព្យាករណ៍ទុកថា កំណើនសេដ្ឋកិច្ចកម្ពុជាមានការកើនឡើងក្នុងរង្វង់ ៤% ក្នុងឆ្នាំ ២០២១ នេះ។

ត្បិតមានការសាងសង់សំណង់ជាច្រើននៅកម្ពុជា ពិសេសនៅរាជធានីភ្នំពេញក៏ពិតមែន ប៉ុន្តែបើមើលពីជីវភាពប្រជាជនមួយចំនួនវិញ ហាក់នៅតែមានការខ្វះខាតច្រើននៅឡើយ។ កម្លាំងស្នូលដែលមិនអាចខ្វះបានក្នុងវិស័យសំណង់ដែរនោះ គឺកម្មករនេះឯង ហើយក្នុងចំណោមអ្នកទាំងនោះ ក៏មានស្ត្រីផងដែរ។



ជាក់ស្តែងអ្នកស្រី ភំ សំផេន ដែលសព្វថ្ងៃជាកម្មការិនីសំណង់ មកធ្វើការជាមួយប្តីនៅភ្នំពេញ បានរៀបរាប់ពីជីវភាពរបស់គ្រួសារគាត់ថា គាត់មិនមានមុខរបរអ្វីផ្សេងធ្វើទេ ហើយគាត់បានត្រឹមតែមកធ្វើការសំណង់ជាមួយប្តីតែប៉ុណ្ណោះ។

ដោយសារតែនៅឯស្រុកកំណើតអ្នកស្រីមិនដឹងថាមានមុខរបរអ្វីធ្វើ ហើយបើទោះជារកបានក៏វាមិនអាចសល់ និងល្មមគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារដែរ ដូច្នេះស្រីក៏សម្រេចចិត្តមកធ្វើ





ការងារសំណង់ជាមួយប្ដីនៅឯទីក្រុង។

អ្នកស្រីបានបញ្ជាក់ថា៖ «គ្រួសារពិបាក គ្រួសារយើងដូចថាខ្វះខាតអីចឹង មុខរបរមិនសូវមាន ចេះតែដើរតាមប្ដីមករកស៊ីជាមួយគាត់ចឹងទៅ។ ដល់ពេលជួនកាលមានលុយមានកាក់ ក៏ផ្ញើឱ្យកូន និងទៅម៉ែអ្នកនៅឯស្រុកដែលគាត់នៅជួយមើលថែថៅនៅផ្ទះបានខ្លះៗដែរ»។

នៅពេលដែលទំនិញក៏ថ្លៃ ប៉ុន្តែប្រាក់កម្រៃក៏បានត្រឹមតែ ៣០០០០៛ ហើយប្ដីរបស់គាត់ក៏បានតែជាង ៣ ម៉ឺនដែរ ក្នុងមួយថ្ងៃប៉ុណ្ណោះ ដែលនេះធ្វើឱ្យអ្នកស្រី ត្រូវការចំណាយច្រើន ហើយប្រាក់កាក់របស់ប្ដីគាត់គឺទុកសម្រាប់សន្សំទើបអាចសល់បានខ្លះសម្រាប់ផ្ញើទៅស្រុក។

បើយើងក្រឡេកមើលទៅស្ថានភាពធ្វើការរបស់ពលករនៅការដ្ឋានសំណង់វិញ ពួកគាត់លើកឡើងថា មានការលំបាកមួយចំនួនដោយខ្លួនត្រូវធ្វើការទាំងឈឺ។ កម្មការិនី វ័យជាង៣០ឆ្នាំនេះ បានរៀបរាប់ពីការតស៊ូរបស់ខ្លួនថា៖ «ខ្ញុំក្នុងចិត្តតស៊ូក្នុងការងារសំណង់ហ្នឹង បើសិនជាអត់ពីការងារសំណង់ហ្នឹង ខ្ញុំទៅកន្លែងការងារផ្សេងប្រហែលជាអត់បានធ្វើទេ គេអត់ឱ្យធ្វើដែរ ឥឡូវគេរើសយកតែអ្នកជើងល្អអ្នករូបរាងស្អាត»។

> គ្រួសារពិបាក គ្រួសារយើងដូចថាខ្វះខាតអីចឹង មុខរបរមិនសូវមាន ចេះតែដើរតាមប្ដីមករកស៊ីជាមួយគាត់ចឹងទៅ។ ដល់ពេលជួនកាលមានលុយមាន កាក់ ក៏ផ្ញើឱ្យកូន និងទៅម៉ែអ្នកនៅឯស្រុកដែលគាត់នៅជួយមើលថែថៅនៅផ្ទះបានខ្លះៗដែរ

អ្នកស្រី ភំ សំផេន បានរៀបរាប់ថា បើទោះជាគាត់ធ្វើសំណង់ ក៏នេះជាការងារមួយដែលមានតម្លៃដែរ ហើយអ្នករាល់គ្នាក៏មិនបានមើលងាយអ្វីដល់កម្មករសំណង់ឬចំពោះអ្នកស្រីដែរ។

អ្នកស្រី បញ្ជាក់ថា៖ «គេឱ្យតម្លៃតើ មិនមែនថាគេមិនឱ្យណាំ! គេមិនមកជិះជាន់យើងផងហ្នឹង! គេប្រើយើង គេឱ្យយើងសម្រាកដែរតើ»។

ការងារប្រចាំថ្ងៃរបស់គាត់គឺមាន យួរឥដ្ឋ យួរកំបោរទៅឱ្យគេ លាយកំបោរទៅឱ្យគេ ពេលខ្លះយួរឬលើករបស់ធ្ងន់ៗមួយចំនួនដែរ និងធ្វើកិច្ចការសំណង់ផ្សេងៗទៀតដែលគាត់អាចធ្វើបាន។ ក្រោយពីចប់ការងារសំណង់ លោកស្រីក៏នៅមាននាទីធ្វើបាយម្ហូបសម្រាប់ទទួលទានពីរនាក់ប្ដីប្រពន្ធនៅកន្លែងធ្វើសំណង់នោះផ្ទាល់ទៀតផង។

ជាទូទៅការងារសំណង់ គេឃើញភាគច្រើនបុរសជាអ្នកធ្វើ ប៉ុន្តែចំនួនស្ត្រីវិញគឺមិនសូវមានច្រើននោះទេ ព្រោះការងារសំណង់ត្រូវការទ្បើងខ្ពស់ៗ ដែលកម្លាំងមនុស្សស្រីមិនដូចកម្លាំងមនុស្សប្រុសទេ ប៉ុន្តែដោយគេអាណិត គេឃើញមកតាមប្ដី ហើយគេក៏ផ្ដល់ការងារឱ្យគាត់ធ្វើទៅ។

ស្ថិតក្នុងស្ថានភាពរស់នៅផ្លាស់ប្ដូរពីមួយកន្លែងទៅមួយកន្លែងតាមតែទីតាំងសំណង់ដែលពួកគាត់ធ្វើរាល់ថ្ងៃ ជីវិតជាកម្មករក៏បានបង្ហាញពីការយល់ឃើញចំពោះការងាររបស់គាត់ថា ត្បិតបើគាត់ជាស្ត្រីមកធ្វើការសំណង់ តែមានពេលខ្លះក៏មិនពិបាកខ្លាំងពេកដែរ។

លោកស្រី ភំ សំផេន ថា៖ «វាមិនពិបាកអីដែរទេ ហើយក៏វាមិនធ្ងន់ធ្ងរអីដែរ តែបើគាត់ចង់មកធ្វើ ក៏មកទៅបានពីរនាក់ រួចហើយវាបានលុយផ្ញើទៅផ្ទះផង»។

កំពុងធ្វើការងារជញ្ជូនឥដ្ឋបណ្ដើរអ្នកស្រី សំផេនក៏បាននិយាយពីការលំបាករបស់គាត់បណ្ដើរថា ៖«ការលំបាកហ្នឹង ចុកដៃចុកជើង រសេសរសោះ ជួនកាលឈឺក្បាលអីចឹងទៅ តែទ្រាំទៅណាំ! លេបថ្នាំអីខ្លះចឹងទៅឱ្យបាត់ឈឺក្បាលបានមានកម្លាំងធ្វើឱ្យគេទៀត បើយើងអត់ធ្វើយើងអត់បានលុយទេ»។

បើទោះជាយ៉ាងណាការងារអ្នកស្រី ត្រូវធ្វើការរយៈពេល ៨ ម៉ោងក្នុង១ថ្ងៃ ហើយគាត់ថាពេលឥឡូវថៅកែក៏ឱ្យឈប់សម្រាកថ្ងៃអាទិត្យមួយថ្ងៃដែរ។ ក្នុងការងារប្រចាំថ្ងៃរបស់គាត់ គាត់ធ្វើការផងក្នុងពេលដែលគាត់មានបញ្ហាជើងគាត់ផងដោយពេលដើរគឺគាត់ដូចរាងលើកជើងបោះៗដើរទៅខ្ញើតៗ អូសជើងម្ខាង។

ស្របពេលដែលខ្លួនមកធ្វើការសំណង់ជាមួយប្ដីនៅភ្នំពេញប្រមាណជាង ១០ ឆ្នាំដែលសព្វថ្ងៃបានទុកកូនអាយុ៧ឆ្នាំ និង៩ឆ្នាំ ឱ្យម្ដាយមើលថែទាំ និងទៅរៀនទៅសូត្រនៅឯស្រុកកំណើត ដោយក្នុង១ខែ គាត់អាចផ្ញើទៅផ្ទះបានប្រមាណ៥ម៉ឺនឬ១០ម៉ឺនប៉ុណ្ណោះ។

អ្នកស្រី ភំ សំផេន ប្រាប់ថា៖ «ចាយទិញម្ហូបហូបរាល់ថ្ងៃហ្នឹងមិនសូវជាឆ្ងាញ់ប៉ុន្មានទេ ត្បិតត្បៀត ព្រោះបានសល់លុយផ្ញើទៅឱ្យកូនចាយខ្លះ ឱ្យកូនរៀនផងអីផង»។

ថ្លែងកាលពីពេលកន្លងទៅ លោក ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់ បានមានប្រសាសន៍ថា៖ «ការអភិវឌ្ឍអចលនទ្រព្យ និងសំណង់ បានក្លាយជាសសរស្ដម្ភស្នូល ដែលជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា»។

លោកថា ជាក់ស្ដែង ទុនវិនិយោគក្នុងវិស័យសំណង់ក្នុងរយៈពេល ១០ ឆ្នាំ ពី២០១០ ដល់ ២០១៩ មានប្រមាណ ៤៣ ៨៩៦ លានដុល្លារសហរដ្ឋអាមេរិក។ នៅខែមករា ឆ្នាំ២០១៩ ទុនវិនិយោគក្នុងវិស័យនេះ មានប្រមាណ ៨២៩ លានដុល្លារ កើនឡើង ១៧៨% ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ ២០១៨ ។

លោក ជា សុផារ៉ា បានបន្តទៀតថា ក្រុមហ៊ុនសាងសង់និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណ មានចំនួន ២ ៣០៧ ក្រុមហ៊ុន មានស្ថាបត្យករប្រមាណជាង ២ ៥០០ នាក់ និងមានវិស្វករប្រមាណជាង ៣០ ០០០ នាក់។

ជាមួយនឹងការរីកចម្រើនដែលកំពុងមានសន្ទុះដ៏លឿននេះ លោកក៏មើលឃើញពីតម្រូវការវិនិយោគជាច្រើន មានជាអាទិ៍ ការអភិវឌ្ឍសំណង់លំនៅឋាន សំណង់ពាណិជ្ជកម្ម សំណង់សេវាកម្ម សំណង់ឧស្សាហកម្ម សំណង់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងបរិស្ថាន សេដ្ឋកិច្ច សង្គម ពិសេសការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ បណ្ដាញផ្លូវ ការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី ប្រព័ន្ធលូនិងប្រព័ន្ធការពារទឹកជំនន់ ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ការគ្រប់គ្រងសំណល់រឹងនិងរាវ លំហសាធារណៈ និងផ្ទៃបៃតង បរិក្ខាទីក្រុង ជាដើម៕

# កម្ពុជាចម្រាញ់មាសជាលើកដំបូងនៅក្នុងប្រវត្តិសាស្រ្ត





*អត្ថបទ៖ អរិយបុត្រ*

រ៉ែមាសបានត្រូវកត់ត្រានៅក្នុងកំណត់ត្រា និងមេរៀនសម្រាប់កូនខ្មែរជាច្រើនជំនាន់រួចមកហើយ ប៉ុន្តែវាបានលេចរូបរាងពិតប្រាកដចាប់ពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ តទៅ ដោយរោងចក្រ ចម្រាញ់មាសលើកដំបូងរបស់កម្ពុជាបានបើកដំណើរការជាផ្លូវការ នៅតំបន់អូរខ្វាវ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។

ពិធីប្រកាសចម្រាញ់រ៉ែមាសលើកដំបូងនេះត្រូវបានសម្ពោធនិងដំណើរការដោយ លោក ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល និងមន្ត្រីអន្តរក្រសួងជាច្រើនរូប។

លោក ស៊ុយ សែម បានមានប្រសាសន៍នៅក្នុងពេលនោះថា នៅពេលដំណើរការ ការដ្ឋានអាជីវកម្ម និងរោងចក្រចម្រាញ់រ៉ែមាសនេះ មានសមត្ថភាពជីកយករ៉ែឆៅប្រមាណជិត ២ លានតោន ក្នុង ១ ឆ្នាំ និងចម្រាញ់ចេញជាដុំមាសកម្រិត ៩០ភាគរយ មាសនេះ នឹងស្រូបទាញកម្លាំងពលកម្មសរុបប្រមាណ ៤៦២ នាក់ ក្នុងនោះជនជាតិខ្មែរប្រមាណ ៤២៧ នាក់ និងបរទេស ៣៥ នាក់ ហើយអាចទាញចំណូលប្រមាណ ១៨៥ លានដុល្លារសហរដ្ឋអាមេរិកក្នុង ១ ឆ្នាំ ដែលក្នុងនោះចំណូលថវិកាជាតិពីសួយសារ និងសារពើពន្ធផ្ទាល់មានប្រមាណ ៤០ លានដុល្លារសហរដ្ឋអាមេរិក។

លោករដ្ឋមន្ត្រី បានបញ្ជាក់ថា ៖ «នេះគឺជាសមិទ្ធផលថ្មីស្រឡាងមួយទៀត ដែលកើតចេញពីនយោបាយឈ្នះឈ្នះរបស់ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបាននាំមកនូវសន្តិភាព ស្ថិរភាពនយោបាយ និងឯកភាពជាតិ ដែលជាកត្តាចាំបាច់បំផុត និងមិនអាចខ្វះបាន ក្នុងការអនុញ្ញាតឱ្យមានការវិនិយោគទ្រង់ទ្រាយធំនៅក្នុងវិស័យធនធានរ៉ែនេះ»។

សូមជម្រាបថា បន្ទាប់ពីបានចំណាយពេលអស់រយៈពេលជិត ១៤ ឆ្នាំ ក្នុងការសិក្សាស្វែងរុករក ការសិក្សាវាយតម្លៃសមិទ្ធិភាពសេដ្ឋកិច្ចនៃជម្រកធនធានរ៉ែ កម្ពុជាបានប្រកាសពីការរកឃើញជម្រកធនធានរ៉ែមាស ដែលមានលក្ខណៈឧស្សាហកម្ម នៅតំបន់អូរខ្វាវ ស្រុកកែវសីមាខេត្តមណ្ឌលគិរី ជាលើកដំបូងនៅកម្ពុជា។ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ នៃការដ្ឋានអាជីវកម្មនិងរោងចក្រចម្រាញ់រ៉ែមាស ត្រូវបានចាប់ផ្តើមពីពាក់កណ្តាលឆ្នាំ ២០២០ ដោយប្រើប្រាស់ទុនវិនិយោគសរុបប្រមាណ ១២០លានដុល្លាសហរដ្ឋអាមេរិក ហើយត្រូវបានបញ្ចប់និងប្រកាសដាក់ឲ្យដំណើរការជាផ្លូវការ នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០២១ នេះ ។

ទាក់ទងនឹងសមិទ្ធផលជាប្រវត្តិសាស្រ្តនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន បានចេញនូវសារជូនជនរួមជាតិអំពីការប្រកាសដាក់ឲ្យដំណើរការការដ្ឋានអាជីវកម្មនិងរោងចក្រចម្រាញ់រ៉ែមាសកាលពីថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២១ កន្លងទៅ ដោយខ្លឹមសារបានបញ្ជាក់ថា ៖ «អាជីវកម្មរ៉ែមាស គឺជាអាជីវកម្មដែលត្រូវការវិនិយោគប្រកបដោយវិជ្ជាជីវៈ មិនមែនគ្រប់គ្នាចេះតែអាចធ្វើការអភិវឌ្ឍបាននោះទេ។ ការដាក់ឱ្យដំណើរការឧស្សាហកម្មរ៉ែមាសថ្ងៃនេះ មិនមែនជាការប្រកាសលើកទឹកចិត្តឲ្យសាធារណជនទាំងឡាយចាប់យករបរអាជីវកម្មរ៉ែមាសនេះឡើយ ព្រោះថា វាជាអាជីវកម្មមានគ្រោះហានិភ័យខ្លាំងត្រូវការដើមទុនច្រើន និងជំនាញពិតប្រាកដ»៕

# ក្រសួងកសិកម្មទទួលស្គាល់ថាតម្រូវការនិងការផ្គត់ផ្គង់ត្រីនៅកម្ពុជា នៅតែជួបបញ្ហាមិនទាន់ដោះស្រាយបាន



*អត្ថបទ៖ កែវ កញ្ញា*

ព្រឹត្តិការណ៍នៃរុះរើ និងចល័តបែចញ្ចឹមត្រី និងផ្ទះបណ្តែតទឹកនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដែលបានជូនដំណឹង និងអនុវត្ត ជាស្ថាពរ កាលពីដើមខែមិថុនានេះ បានបង្កឲ្យមានសំណួរ និងមតិជាច្រើន បានលើកឡើងអំពីបញ្ហានៃការខ្វះខាតផលត្រី សម្រាប់ផ្គត់ផ្គង់នៅលើទីផ្សារកម្ពុជា នៅពេលដែលបែជាច្រើនត្រូវរុះរើនោះ។

នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានទទួលស្គាល់ថា តម្រូវការ និងការផ្គត់ផ្គង់ត្រីនៅកម្ពុជា គឺនៅតែខ្វះខាត ដែលត្រូវការដើមទុន និងបច្ចេកទេសជាច្រើនទៀត ដើម្បីសម្របតាមចំនួននៃអ្នកបរិភោគ។

តាមរបាយការណ៍របស់ក្រសួងឲ្យដឹងថា បច្ចុប្បន្នប្រជាជនយើងមានការកើនឡើង ជារៀងរាល់ឆ្នាំ ផ្អែកតាមតួលេខបណ្តោះអាសន្ន នៃជំរឿនទូទៅប្រជាជនសរុបតាមវិធីសាស្ត្រឃើញរាប់ (de-facto) នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៩ មានចំនួន ១៥ ២៨៨ ៤៨៩នាក់ ដែលកើនឡើងចំនួន ១៤,១% រយៈពេល១១ឆ្នាំ រវាងឆ្នាំ២០០៨ និងឆ្នាំ២០១៩ ដែលធ្វើឱ្យតម្រូវការត្រីសាច់សម្រាប់បរិភោគមានការកើនឡើងផងដែរ។

ជាមួយគ្នានេះដែរ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបញ្ជាក់បន្ថែមថា មានកត្តាសំខាន់ៗមួយចំនួនដែលធ្វើឲ្យការផ្គត់ផ្គង់ និងតម្រូវការមិនសតុល្យគ្នា ក្នុងនោះមានដូចជា «ការថមថយផលត្រីពីធម្មជាតិ ដោយសារ កំណើនប្រជានេសាទ។ បច្ចេកទេសខ្ពស់នៃការនេសាទ និងជនប្រព្រឹត្តបទល្មើសមានល្បិចកលក្នុងការធ្វើនេសាទខ្ពស់។ ការរេចរិលបរិស្ថាន និងការបាត់បង់ជម្រកត្រីសម្រាប់ពងកូន។ការប្រែប្រួលអាកាសធាតុការប្រែប្រួលរបបទឹកទន្លេមេគង្គ និងការប្រើប្រាស់ដីធ្លី។ កិច្ចសហការ និងសមត្ថកិច្ចទទួលខុសត្រូវ ក្នុងការបង្ក្រាបបទល្មើសជលផលនៅមានកម្រិតក្រោយពីប្រមុខ រាជរដ្ឋាភិបាល បានដាក់ចេញនូវគោលនយោបាយកំណែទម្រង់នៃការផ្ទេរសិទ្ធិអំណាចទៅថ្នាក់ក្រោមជាតិ»។

ក្រសួងបានឲ្យដឹងបន្ថែមថា ការគ្រប់គ្រងទីផ្សារត្រីនៅកម្ពុជាគឺ មិនមានការព្រមព្រៀងរវាងអ្នកចិញ្ចឹមត្រីក្នុងស្រុក និងអ្នកគាំទ្រការនាំចូល។ ក្នុងនិន្នាការពាណិជ្ជកម្មសេរី និងគាំទ្រផលិតផលដែលមានតម្លៃទាប ដើម្បីចែកចាយនៅលើទីផ្សារ សម្រាប់ប្រជាជនកម្ពុជាដែលទទួលបាន ប្រាក់ចំណូលទាប ក៏ជាហេតុផលដែលនាំឲ្យការផលិតផលត្រីធ្លាក់ចុះ ដែលជាហេតុផល វារីវប្បករមិនអាចផលិត និងផ្គត់ផ្គង់ទីផ្សារក្នុងស្រុកក្នុងតម្លៃប្រកួតប្រជែងជាមួយផលិតផលនាំចូលបានទេ។

ប្រភពដដែលបានបន្តទៀតថា ក្នុងនោះមានកត្តាមួយចំនួនគួបផ្សំផងដែរ ដូចជា ១) ការជ្រើសរើសទីតាំងចិញ្ចឹមមានលក្ខណៈភូមិសាស្ត្រមិនសមស្រប (ខ្វះប្រភពទឹក, បរិស្ថាន ជុំវិញមិនគាប់ប្រសើរ)។ ២).ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ការងារប្រតិបត្តិការ និងចំណីក្នុងការចិញ្ចឹមមានតម្លៃខ្ពស់។ ៣) បណ្តាញហេដ្ឋារចនាសម្ព័ន្ធទីផ្សារ និងការចែកចាយភាគច្រើនគ្រប់គ្រងដោយបណ្តាញអាជីវករនាំចូលត្រី។

រីឯចំណុចមួយទៀតដែលធ្វើឲ្យការផ្គត់ផ្គង់ត្រីមិនគ្រប់តាមតម្រូវការនោះគឺ «យន្តការត្រួតពិនិត្យនៃការនាំចូលមានភាពស្មុគស្មាញទាំងបរិមាណ គុណភាព និងកាតព្វកិច្ចនានាសម្រាប់អ្នកនាំចូល និងមានសមត្ថកិច្ចទទួលខុសត្រូវជាច្រើន»។

ក្រសួងបន្តថា៖«វិស័យវិនិយោគឯកជនលើការធ្វើវារីវប្បកម្មនៅខ្វះទុន និងខ្វះចំណេះដឹងក្នុងការសិក្សាពីតម្រូវការទីផ្សារក្នុង និងក្រៅប្រទេស គួបផ្សំជាមួយតម្លៃនៃការដឹកជញ្ជូន ក្នុងស្រុក និងការនាំចេញ តម្លៃសេវាក្នុងការផលិត កែច្នៃ និងស្តុក នៅមានតម្លៃខ្ពស់»។

ក្នុងបរិការណ៍នេះ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបាននិងកំពុងខិតខំប្រឹងប្រែងយ៉ាងសកម្ម តាមអភិក្រម «រដ្ឋ ឯកជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍» ដើម្បីរួមចំណែកដោះស្រាយនូវបញ្ហាប្រឈមទាំងឡាយ ដូចបាន រៀបរាប់ខាងលើ។

ប្រភពដដែលបញ្ជាក់ថា អនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វារីវប្បកម្មឆ្នាំ២០១៦-២០៣០ជាលទ្ធផលជាក់ស្តែងផលិតកម្មវារីវប្បកម្មក្នុងឆ្នាំ២០២០នេះបានកើនឡើងរហូតដល់ជាង ៣០% បើប្រៀបធៀបនឹងឆ្នាំ២០១។ ជាការពិត ធនធានមនុស្សពាក់ព័ន្ធនឹងការងារវារីវប្បកម្មមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការធ្វើវារីវប្បកម្មនៅកម្ពុជា។ ជាក់ស្តែងមន្ត្រីជំនាញវារីវប្បកម្មត្រូវបានទទួលការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស និងបានយកចំណេះជំនាញនេះទៅបណ្តុះបណ្តាលដល់កសិករឱ្យចេះចិញ្ចឹមត្រីនៅស្ទើរតែគ្រប់រាជធានី ខេត្ត ដែលមានសក្តានុពលផលិត។

កន្លងមកនេះក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តគម្រោងវារីវប្បកម្ម ពិសេសការចិញ្ចឹមត្រីអណ្តែង និងកង្កែបក្នុងតង់ប្លាស្ទិក ដោយប្រើរយៈពេលខ្លី ចំណាយដើមទុនតិច និងទទួលបានប្រាក់ចំណូលខ្ពស់ នៅតាមខេត្តគោលដៅចំនួន១១ និង ខេត្តទទួលរងគ្រោះជំនន់ទឹកភ្លៀងចំនួន៤នាពេលកន្លងមក។ លើសពីនេះ ក្រសួងបានសហការយ៉ាងល្អប្រសើរជាមួយសមាគមវារីវប្បករនៅកម្ពុជាផងដែរ៕

# អាមេរិកបង្វែរគម្រោងព្រៃឡង់បៃតងទៅជួយវិស័យឯកជន សង្គមស៊ីវិល និងការងារសហគមន៍មូលដ្ឋាន

*អត្ថបទ៖ ផល សុផានិត*

ស្ថានទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា នៅព្រឹកថ្ងៃទី ១៧ ខែមិថុនា បានចេញសេចក្តីថ្លែងការណ៍ ស្តីពីស្តីពីការបង្វែរថវិកានៃគម្រោងព្រៃឡង់បៃតង របស់ទីភ្នាក់ងារជំនួយអាមេរិក USAID បង្វែរទៅជួយវិស័យឯកជន សង្គមស៊ីវិល និងការងាររបស់សហគមន៍មូលដ្ឋាន ដើម្បីកែលម្អមុខរបរប្រកបជីវភាពរស់នៅ និងពង្រីកកសិកម្មដែលមិនប៉ះពាល់បរិស្ថាន។



យោងសេចក្តីថ្លែងការណ៍ បានឱ្យដឹងថា ៖«ប្រជាជនអាមេរិកនិងកម្ពុជា មានបំណងដូចគ្នា ក្នុងការការពារ ធនធានធម្មជាតិ ដ៏មានតម្លៃនៅលើផែនដី ដើម្បីធ្វើឲ្យមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព បង្វែរនិន្នាការនៃបម្រែបម្រួលអាកាសធាតុ និង អភិរក្សសត្វព្រៃ និងជីវសាស្ត្រចម្រុះ សម្រាប់មនុស្សជំនាន់ក្រោយ។ សហរដ្ឋអាមេរិកបានធ្វើការចំណាយថវិកាចំនួនជាង ១០០ លានដុល្លារ លើកម្មវិធីមួយចំនួន សម្រាប់ប្រយុទ្ធប្រឆាំងនឹងបញ្ហាទាំងនេះ នៅកម្ពុជា តាមរយៈទីភ្នាក់ងារផ្តល់ជំនួយអាមេរិក USAID» ។



សេចក្តីថ្លែងការណ៍ បន្ថែមថា ថ្វីបើប្រទេសកម្ពុជាសម្រេចបាននូវដំណើរចម្រើនទៅមុខខ្លះ នៅក្នុងការការពារបរិស្ថានក្តី តែសហរដ្ឋអាមេរិកបាន សម្តែងនូវកង្វល់ម្តងហើយម្តងទៀតលើការកាប់បំផ្លាញព្រៃឈើ ដែលនៅតែមានច្រើន នៅក្នុងតំបន់ការពារ ពិសេសនៅដែនជម្រកសត្វព្រៃនៅព្រៃឡង់ ជាទីដែលទីភ្នាក់ងារ USAID បានចំណាយធនធានជាច្រើន។ យើងបានអំពាវនាវឲ្យមានកិច្ចសហប្រតិបត្តិការច្រើនថែមទៀត រវាងរដ្ឋាភិបាលកម្ពុជា សហគមន៍មូលដ្ឋាន និងសង្គមស៊ីវិល ដើម្បីរកដំណោះស្រាយដើម្បីការពារព្រៃឡង់ និងបេតិកភណ្ឌធម្មជាតិនៃកម្ពុជា ដើម្បីជាប្រយោជន៍របស់ប្រជាជនកម្ពុជាទាំងអស់ និងពិភពលោក។

តាំងពីឆ្នាំ ២០១៦ មក ទោះបីជាមានការគាំទ្ររបស់ទីភ្នាក់ងារ USAID ដើម្បីឲ្យមានការដើរល្បាត ការបណ្តុះបណ្តាលដល់ផ្នែកអនុវត្តច្បាប់ច្រើនថែមទៀត និងការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងតំបន់ការពារថ្នាក់ជាតិក៏ដោយ ក៏តំបន់ដែនជម្រកសត្វព្រៃនៅព្រៃឡង់ នៅតែបានបាត់បង់ដដែល នូវផ្ទៃដីព្រៃប្រមាណ ៣៨ ០០០ ហិកតា គឺជិត ៩% នៃគម្របព្រៃឈើនៅទីនោះ។ ការកាប់ឈើខុសច្បាប់ដែលត្រូវបានបញ្ជាក់ច្បាស់ នៅតែបន្តមាននៅក្នុងនិងជុំវិញដែនជម្រកសត្វព្រៃនៅព្រៃឡង់ ហើយអាជ្ញាធរ កម្ពុជាមិនបានធ្វើការកាត់ទោសបានសមល្មម ចំពោះបទល្មើសសត្វព្រៃ ឬបញ្ឈប់សកម្មភាពខុសច្បាប់ទាំងនេះឡើយ។ លើសពីនេះទៀត អាជ្ញាធរបានបន្តបំបិទសម្លេង ហើយធ្វើទុក្ខសហគមន៍មូលដ្ឋាន និងសង្គមស៊ីវិល ដែលជាដៃគូរបស់គេ ដែលបង្ហាញកង្វល់ដ៏សមហេតុផល លើការបាត់បង់ធនធានធម្មជាតិរបស់គេ។

សហរដ្ឋអាមេរិកនឹងបន្តធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា លើបញ្ហាបរិស្ថាន និងបម្រែបម្រួលអាកាសធាតុ ដែលជាកង្វល់រួមរបស់យើង និងរបស់ពិភពលោក ដោយរួមទាំងការធ្វើការតាមរយៈកិច្ចសហការជាដៃគូរវាងសហរដ្ឋអាមេរិក និងតំបន់ទន្លេមេគង្គ។

លោក នេត្រ ភក្ត្រា អ្នកនាំពាក្យក្រសួងបរិស្ថាន បានលើកឡើងថា កម្ពុជាគោរពចំពោះការសម្រេចចិត្តរបស់ដៃគូអភិវឌ្ឍន៍ និងអរគុណចំពោះការចូលរួមចំណែកជាមួយកម្ពុជា ផ្តល់ជំនួយបច្ចេកទេសនាពេលកន្លងមកក្នុងកិច្ចការពារនិងអភិរក្សធនធានធម្មជាតិនៅតំបន់ព្រៃឡង់។

លោកថា ៖ «ភាគីទាំងពីរបានឯកភាពគ្នាបង្វែរលើកិច្ចសហប្រតិបត្តិការផ្សេងទៀតដែលបន្តបម្រើឱ្យឧត្តមប្រយោជន៍របស់ប្រជាជនកម្ពុជា»។

ក្រសួងបរិស្ថានបានគូសបញ្ជាក់ថា បទល្មើសធនធានធម្មជាតិទ្រង់ទ្រាយធំនៅក្នុងតំបន់ដែនជម្រកសត្វព្រៃព្រៃឡង់និងនៅតំបន់ការពារធម្មជាតិផ្សេងទៀតលែងកើតមានទៀតហើយ តែនៅមានបទល្មើសទ្រុងទ្រាយតូចៗកើតឡើង។ នេះគឺជាក្តីព្រួយបារម្ភដែលនៅសេសសល់តិចតួចដែលក្រសួងបរិស្ថាន និងសមត្ថកិច្ចពាក់ព័ន្ធបាននិងកំពុងបន្តអនុវត្តច្បាប់ដោយការទទួលខុសត្រូវ។ លោក នេត្រ ភក្ត្រា បានបន្ថែម។

អ្នកនាំពាក្យរូបនេះបានបន្ថែមថា ការបញ្ចប់គម្រោងព្រៃឡង់បៃតងដែលជាកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងសហរដ្ឋមេរិកនៅតំបន់ដែនជម្រកសត្វព្រៃព្រៃឡង់នៅពេលនេះ បានបង្ហាញថា ក្រសួងបរិស្ថានក្នុងនាមសេនាធិការនៃរាជរដ្ឋាភិបាលនិងមន្ត្រីរបស់ខ្លួនមានការទទួលខុសត្រូវ និងមានភាពរឹងមាំគ្រប់គ្រាន់ក្នុងភាពជាម្ចាស់ក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួនលើការការពារនិងអភិរក្សធនធានធម្មជាតិដោយឈរនៅលើមូលដ្ឋានច្បាប់ជាធរមាន។

ក្រសួងបរិស្ថាននឹងបន្តបេសកកម្មរបស់ខ្លួនប្រកប ដោយការទទួលខុសត្រូវខ្ពស់និងវិជ្ជាជីវៈក្នុងការគ្រប់គ្រង និងអភិរក្សតំបន់ដែនជម្រកសត្វព្រៃព្រៃឡង់ ក៏ដូចជាតំបន់ការពារធម្មជាតិនៅក្នុងប្រទេសកម្ពុជាសម្រាប់មនុស្សជំនាន់ទៅមុខទៀត។

លោក នេត្រ ភក្ត្រាបានបន្តថា ៖ «ក្រោមសុខសន្តិភាពពេញលេញ កម្ពុជាមានឱកាសពេញលេញក្នុងការគិតគូររៀបចំការអភិរក្សធនធានធម្មជាតិរបស់ខ្លួន។ ដោយសារតែការការពារ និងអភិរក្សមានភាពល្អប្រសើរ កម្ពុជាបានទទួលជោគជ័យលើការលក់ឥណទានកាបូននៅលើទីផ្សារស្ម័គ្រចិត្តអន្តរជាតិ ស្ថានភាពជីវភាពពលរដ្ឋនៅតាមសហគមន៍តំបន់ការពារធម្មជាតិចាប់ផ្តើមមានភាពល្អប្រសើរផ្សារភ្ជាប់នឹងទេសចរណ៍ធម្មជាតិ និងជម្រើសថ្មីក្នុងមុខរបររបស់ខ្លួន»៕

# គ្រូបង្រៀនជាច្រើននៅតែបន្តបង្រៀន និងតាមដានការសិក្សារបស់សិស្សតាមប្រព័ន្ធអនឡាញ

*អត្ថបទ៖ ផល សុផានិត*

យើងមកមើលពីការសិក្សារបស់សិស្សានុសិស្សនៅក្នុងបរិបទកូវីដ១៩នេះ តាមរយៈប្រព័ន្ធអនឡាញ មើលឃើញថាស្ថានភាពកូវីដ-១៩ មិនទាន់បានបញ្ចប់សាលារៀនមិនទាន់អាចបើកដំណើរការបាន ដូច្នេះហើយលោកគ្រូ អ្នកគ្រូ កំពុងតែរៀបចំការបង្រៀន និងតាមដានការសិក្សារបស់សិស្សបន្តទៀត តាមប្រព័ន្ធអនឡាញ។

ក្នុងនោះសាលារៀននៅទូទាំងប្រទេស សាលារៀនបានបន្តផ្អាក ហើយគ្រូបង្រៀននៅតាមសាលារៀននីមួយៗ នៅតាមដានសកម្មភាពសិស្សជាប្រចាំ តាមរយៈប្រព័ន្ធអនឡាញផ្សេង។ សាលាបឋមសិក្សាចតុមុខ រាជធានីភ្នំពេញ តាមការលើកឡើងរបស់លោក សូ ធី នាយកសាលា បានលើកឡើងថា សាលារបស់លោក តែងតែមានការប្រជុំជាប្រចាំ ជាមួយគ្រូបង្រៀនស្វែងយល់ ពីប្រព័ន្ធអនឡាញនៅពេលនេះ។

នៅក្នុងសាលារៀនទាំងអស់ គឺមានកិច្ចការបង្រៀនសិស្សទាំងអស់ និងដាក់កិច្ចការឱ្យសិស្សជាប្រចាំ តាមប្រព័ន្ធទំនាក់ទំនងគ្រូ ជាមួយសិស្ស ដើម្បីប្រមូលពិន្ទុ សម្រាប់ការឡើងថ្នាក់។ «សាលានៅពេលដែលទទួលបានមេរៀន ទទួលបានព័ត៌មានអ្វីពីក្រសួង គឺសាលាបានដាក់បញ្ចូលទៅក្នុងក្រុមសាលា ហើយក្រុមថ្នាក់នីមួយក៏យកទៅបន្ត។ ដូច្នេះបន្ទាប់ពីយើងផ្សព្វផ្សាយព័ត៌មាន លោកគ្រូអ្នកគ្រូ គាត់បង្រៀនទៅតាមអនឡាញ ដោយមានការថតជាវីដេអូឃ្លីប ក្នុងការពន្យល់មេរៀនសិស្ស រួមនិងកិច្ចការជាប្រចាំថ្ងៃ ក្រៅពីវីដេអូ ក៏លោកគ្រូអ្នកគ្រូ បានបញ្ចូលមេរៀនរបស់ក្រសួង»។

លោកនាយកសាលា បានវាយតម្លៃថា សម្រាប់ការបង្រៀនតាមប្រព័ន្ធអនឡាញ សម្រាប់សាលាបឋមសិក្សាចតុមុខ គឺអនុវត្តបានល្អប្រសើរ ដោយមានតែសិស្សមួយចំនួនតូចប៉ុណ្ណោះដែលមិនមាន ទូរស័ព្ទដៃសម្រាប់ការប្រើប្រាស់។ ក្នុងករណីនេះ លោកនាយក លើកទឹកចិត្ត ឱ្យសិស្សសិក្សាតាមទូរទស្សន៍ និងមានការណាត់ជាមួយគ្រូ ដើម្បីបង្រៀនបន្ថែម។

ជុំវិញការបង្រៀននិងការតាមដានសិស្សក្នុងការសិក្សាតាមប្រព័ន្ធអនឡាញនេះ គឺមិនអនុវត្តក្នុងរាជធានីភ្នំពេញទេ សាលារៀននៅតាមបណ្តាខេត្តក៏មានការពិនិត្យមើល លើការបង្រៀន និងការតាមដានសិស្ស តាមប្រព័ន្ធអនឡាញនេះដែរ។

អ្នកគ្រូ ខាត់ សុវណ្ណ បានបង្រៀននិងការដាក់កិច្ចការ នៅតាមប្រព័ន្ធអនឡាញ នៅតែបន្តធ្វើជាប្រចាំ ទោះមានបញ្ហាប្រឈមមួយចំនួនក្តី។ អ្នកគ្រូ បញ្ជាក់ថា បញ្ហាធំគឺសិស្សមិនមានទូរស័ព្ទ៖ «ចំពោះការបង្រៀន និងការតាមដានសិស្ស របស់នាងខ្ញុំគឺធ្វើតាមរយៈប្រព័ន្ធអនឡាញការចែកសន្លឹកកិច្ចការ។ ចំពោះការប្រើប្រាស់កម្មវិធីទាំងនេះ មានផលលំបាកមួយចំនួនផងដែរ ដូចជាពេលដែលនាងខ្ញុំទម្លាក់ Link ឱ្យសិស្ស គឺពួកគាត់មិនចេះក្នុងការចូលរៀន»។

គិតដល់ពេលនេះ ក្រសួងអប់រំ យុវជន និងកីឡា មិនទាន់អាចបញ្ជាក់ កាលបរិច្ឆេទ ការបើកដំណើរការសាលារៀនវិញបាននៅឡើយនោះទេ ស្របពេលដែលព្រឹត្តិការសហគមន៍២០កុម្ភៈ មិនទាន់បិទបញ្ចប់នៅឡើយ។ យ៉ាងណាមិញ លោក រស់ សុវ៉ាចា អ្នកនាំពាក្យក្រសួងអប់រំ យុវជន និងកីឡា បានបញ្ជាក់ថា ក្រសួងអប់រំ យុវជន និងកីឡា បានប្រជុំកំណត់យុទ្ធសាស្ត្រការបើកសាលារៀនឡើងវិញ ក្រោយបិទបញ្ចប់ព្រឹត្តិការសហគមន៍ ២០កុម្ភៈ ដើម្បីសុវត្ថិភាព៕

# ក្រសួងសាធារណការ ប្រើប្រាស់បច្ចេកវិទ្យាទំនើប ដើម្បីផ្តល់សេវាជូនពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព

*អត្ថបទ៖ ផល សុផានិត*

លោក ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន បានថ្លែងថា កម្ពុជាសព្វថ្ងៃនេះ កំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាសម័យទំនើប ដើម្បីគាំទ្រដល់ផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ចំណេញពេលវេលា និងកាត់ចំណាយក្រៅផ្លូវការ បានយ៉ាងច្រើនជូនប្រជាពលរដ្ឋ។



លោកទេសរដ្ឋមន្ត្រី បានលើកឡើងបែបនេះ នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ ក្នុងឱកាសទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូសភាពាណិជ្ជកម្មសហរដ្ឋអាមេរិកនៅកម្ពុជា ដឹកនាំដោយលោក Anthony Galliano ប្រធាន AmCham និងជានាយកប្រតិបត្តិនៃក្រុមហ៊ុន Cambodia Investment Management

លោកទេសរដ្ឋមន្ត្រី បានបន្ថែមថា ប្រព័ន្ធបច្ចេកវិទ្យាសម័យទំនើបនេះ មានដូចជា ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ ប្រព័ន្ធស្វ័យប្រវត្តិកម្មលក់លេខពិសេសផ្ទាល់ខ្លួន ការបើកដំណើរការមណ្ឌលប្តូរ និងពន្យារបណ្ណបើកបរនៅផ្សារទំនើបអ៊ីអនម៉ល១ អ៊ីអនម៉ល២ និងផ្សារទំនើបជីបម៉ុង និងការបង្កើតទីតាំងត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត និងការប្រើប្រាស់កម្មវិធីថែទាំផ្លូវ (ROAD CARE Mobile App) ដើម្បីឱ្យប្រជាពលរដ្ឋចូលរួមរាយការណ៍អំពីផ្លូវខូចសំដៅថែទាំផ្លូវឱ្យបានយូរអង្វែង។





ជាមួយគ្នានោះដែរ លោកទេសរដ្ឋមន្ត្រី បានបញ្ជាក់ដែរថា ក្រសួងក៏បានធ្វើបច្ចុប្បន្នភាព អំពីវឌ្ឍនភាពនៃគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលសម្រេចបាន គម្រោងកំពុងអនុវត្តបន្ត និងគម្រោងសាងសង់នាពេលអនាគត ដែលក្នុងនោះរួមមានគម្រោងធ្វើឱ្យប្រសើរឡើងផ្លូវជាតិលេខ១ លេខ២ លេខ២២ លេខ៣ លេខ៤ លេខ៥ ផ្លូវជាតិលេខ៦ លេខ៧ លេខ៨ លេខ៤៨ លេខ១០ លេខ១១ លេខ៥៦ លេខ៥៨ និងផ្លូវជាតិលេខ៧៦ ដែលត្រូវបានបញ្ចប់ការសាងសង់រួចរាល់ និងគម្រោងលើកកម្ពស់ផ្លូវជាតិលេខ៣១, ៣៣, ៤១, ពីផ្លូវកៅស៊ូ២ស្រទាប់ស្តើង (DBST) ទៅជាផ្លូវបេតុងកៅស៊ូ (AC) គម្រោងសាងសង់ផ្លូវជាតិលេខ៧១c កំពង់ចាម-ត្បូងឃ្មុំ និងគម្រោងសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គ ខេត្តក្រចេះផងដែរ។

លោក ស៊ុន ចាន់ថុល ក៏បានសង្កត់ធ្ងន់ថា ទោះបីជាមានការរាតត្បាតពីជំងឺកូវីដ-១៩ នៅកម្ពុជា ក៏ដូចជានៅទូទាំងពិភពលោកក៏ដោយ ក៏គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា នៅតែបន្តដំណើរការរបស់ខ្លួនឥតឈប់ឈរ ដោយមិនទាន់ឃើញមានគម្រោងណាមួយ ត្រូវបានរងផលប៉ះពាល់ដោយការរាតត្បាតពីជំងឺដ៏កាចសាហាវនេះនៅឡើយទេ។ ជាងនេះទៅទៀតគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក (NRSC) កំពុងអភិវឌ្ឍគម្រោងដ៏ថ្មីស្រឡាងមួយទៀត គឺកម្មវិធីកាត់ពិន្ទុបណ្ណបើកបរ ដែលអនុញ្ញាតឱ្យសមត្ថកិច្ចនគរបាលចរាចរណ៍ធ្វើការដកពិន្ទុបណ្ណបើកបរដោយស្វ័យប្រវត្តិ និងជូនដំណឹងទៅកាន់ស្ថាប័នចេញបណ្ណបើកបរ និងម្ចាស់បណ្ណដែលប្រព្រឹត្តខុសនឹងច្បាប់ចរាចរណ៍ផ្លូវគោក និងកម្មវិធីព័ត៌មានវិទ្យាជាច្រើនទៀត ដើម្បីផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានលឿនប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។



លោកទេសរដ្ឋមន្ត្រី ក៏បានធ្វើកត់សម្គាល់ដែរថា កម្ពុជាកំពុងគិតគូរអំពីគោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ការដឹកជញ្ជូនបៃតង ដើម្បីសម្របខ្លួនទៅតាមការរីកចម្រើននៃសាកលភាវូបនីយកម្ម ជាពិសេសការប្រើប្រាស់យានយន្តដែលដើរដោយថាមពលអគ្គិសនីជំនួសវិញ ដើម្បីអាចកាត់បន្ថយថ្លៃដើមប្រតិបត្តិការ និងចៀសវាងការបំភាយឧស្ម័នផ្ទះកញ្ចក់នៅពេលដែលយានយន្តអគ្គិសនីសាកភ្លើងដោយថាមពលកកើតឡើងវិញ។

នៅក្នុងជំនួបនោះគណៈប្រតិភូសភាពាណិជ្ជកម្មសហរដ្ឋអាមេរិកនៅកម្ពុជា បានសម្តែងនូវការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ក៏ដូចជារាជរដ្ឋាភិបាលកម្ពុចា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ក្នុងការប្តេជ្ញាចិត្តខ្ពស់ប្រកបដោយការទទួលខុស ត្រូវដើម្បីបន្តជំរុញអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួន ឱ្យមានការរីកចម្រើនយ៉ាងរហ័ស៕

# លោក ទៀ បាញ់៖ «ចិនដើរតួនាទីសំខាន់ សម្រាប់តំបន់អាស៊ាន»

*អត្ថបទ៖ ផល សុផានិត*

ប្រមុខការពារជាតិកម្ពុជា បានថ្លែងថា ប្រទេសចិនបានដើរតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សាសន្តិភាព ស្ថិរភាព វិបុលភាព និងនិរន្តភាពតំបន់ ហើយមួយវិញទៀតប្រទេសចិនបានប្តេជ្ញាចិត្តដើម្បីកសាងទំនុកចិត្ត និងពង្រឹងចំណងទំនាក់ទំនងជាមួយអាស៊ាន ជាពិសេសលើវិស័យសន្តិសុខលម្ហសមុទ្រនេះតែម្តង។

ថ្លែងនៅក្នុងកិច្ចប្រជុំ ក្រៅផ្លូវការរដ្ឋមន្ត្រីការពារ ជាតិអាស៊ាន-ចិន តាមប្រព័ន្ធអនឡាញ (online ) នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ នេះ លោក ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិកម្ពុជា បានសំដែងចូលរួមអបអរសាទរ ចំពោះខួបលើកទី៣០ នៃទំនាក់ទំនងសន្ទនាអាស៊ាន - ចិន។




លោកបានបន្តថា នេះជាឱកាសមួយដ៏ល្អប្រសើរក្នុងការបង្កើនទំនាក់ទំនងអាស៊ាន-ចិនឈានដល់កម្រិតខ្ពស់បន្ថែមទៀត ដើម្បីកសាងសហគមន៍មួយដែលមានអនាគតរួមគ្នាក្នុងការបើកទំព័រថ្មីឆ្ពោះទៅរកវិបុលភាពរួម អាស៊ាន-ចិន។

ប្រមុខការពារជាតិកម្ពុជារូបនេះបានសង្កត់ធ្ងន់ថា ៖ « បីទសវត្សរ៍កន្លងមកនេះ យើងឃើញថាទំនាក់ទំនងអាស៊ាន-ចិន បានរីកដុះដាល់កាន់តែជិតស្និទ្ធ និងរឹងមាំឡើងហើយប្រទេសចិនបានដើរតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សាសន្តិភាព ស្ថិរភាព វិបុលភាព និងនិរន្តភាពតំបន់»។



លោកបានបន្តថា ចាប់តាំងពីក្លាយជាដៃគូសន្ទនារបស់ អាស៊ានក្នុងឆ្នាំ១៩៩១ មក ប្រទេសចិនបានបន្តចូលរួមចំណែកការធ្វើឲ្យប្រសើរឡើងនៃកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការនយោបាយសន្តិសុខ និងតាមរយៈក្របខ័ណ្ឌផ្សេងៗដែលដឹកនាំដោយអាស៊ាន រួមមាន ៖ កិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) អាស៊ានបូកបី(API) វេទិកាតំបន់អាស៊ាន (ARF) និងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន- បូក (ADMM-Plus) ជាដើមនោះ។

លោក ទៀ បាញ់ បានបន្ថែមទៀតថា ចិនបានប្តេជ្ញាចិត្តដើម្បីកសាងទំនុកចិត្ត និងពង្រឹងចំណងទំនាក់ទំនងជាមួយ អាស៊ាន ជាពិសេស លើវិស័យសន្តិសុខលម្ហសមុទ្រ។ ក្នុងន័យនេះ សម្តេចពិជ័យសេនា បានវាយតម្លៃខ្ពស់លើជោគជ័យនៃលំហាត់លម្ហសមុទ្រអាស៊ាន -ចិន ដែលអនុវត្តកាលខែសីហា ឆ្នាំ២០១៨ ដែលជួយពង្រឹងអន្តរប្រតិបត្តិការកងទ័ពជើងទឹករបស់យើង និងសំខាន់ជាងនេះទៅទៀត ដើម្បីកសាងទំនុកចិត្ត និងការជឿជាក់ក្នុងការធ្វើការជាមួយគ្នា ដើម្បីដោះស្រាយឧប្បត្តិហេតុនៅសមុទ្រជាដើម។

ថ្លែងនៅក្នុងកិច្ចប្រជុំក្រៅផ្លូវការរវាងរដ្ឋមន្ត្រីក្រសួងការពារជាតិអាស៊ាន និងចិននេះដែរ លោកវេ ហ្វ៊ុងហឺ ( Wei Fenghe ) សមាជិកក្រុមប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីការពារជាតិចិន បានលើកឡើងថា អាស៊ាន និងចិន បានក្លាយទៅជាទំនាក់ទំនងមួយដែលមានថាមពល និងប្រសិទ្ធភាពបំផុតក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

នៅឆ្នាំនេះ គឺជាខួបលើកទី៣០ នៃកិច្ចទំនាក់ទំនងរវាងអាស៊ាន និងចិន ដូច្នេះ៣០ឆ្នាំកន្លងមកនេះ គឺប្រទេសអាស៊ាន និងប្រទេសចិនបានកសាងទំនាក់ទំនងនៅពេលសង្គ្រាមត្រជាក់ត្រូវបានបញ្ចប់ ជាពិសេសនៅពេលពិភពលោកបានក្លាយជាពហុប៉ូលក៏ដូចជាកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាដើម។

លោក វេ បានបន្តទៀតថា ជាច្រើនឆ្នាំកន្លងមកប្រទេសចិន និងអាស៊ានបានធ្វើកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខនេះ និងបានចូលរួមក្នុងវិស័យជាច្រើន ក្នុងនោះបានជំរុញអោយមានកិច្ចសហប្រតិបត្តិការដែលមានខ្លឹមសារជាច្រើនក្នុងការរក្សាសន្តិភាព និងស្ថិរភាពទាំងលើឆាកអន្តរជាតិ និងតំបន់។ នេះបានបង្ហាញអំពីភាពជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងក្នុងកសាងសហគមន៍របស់យើងដែលមានវាសនារួមគ្នារវាងអាស៊ាន និងចិន យើងការជឿទុកចិត្តគ្នាទៅវិញទៅមកត្រូវបានពង្រឹង យើងជាអ្នកធ្វើការក្នុងវិស័យការពារជាតិក៏បានពង្រឹងកិច្ចសហប្រតិបត្តិការជិតស្និទ្ធគ្នាទៅវិញទៅមក ក៏ដូចជាវិស័យពហុភាគី និងការធ្វើទស្សនកិច្ចទៅវិញទៅមក។

ខណ:នោះដែរ អនុរដ្ឋមន្ត្រីក្រសួងការពារជាតិនៃប្រទេសព្រុយណេ បានសំដែងការអបអរសាទរខួបលើកទី ៣០ឆ្នាំ នៃកិច្ចសហប្រតិបត្តិការរវាងអាស៊ាន ចិន ។ លោកអនុរដ្ឋមន្ត្រី បានថ្លែងអំណរគុណ ដល់បណ្តារដ្ឋមន្ត្រីការពារជាតិអាស៊ានទាំងអស់ ដែលបានចូលរួមប្រជុំក្រៅផ្លូវការ រដ្ឋមន្ត្រីការពារជាតិ នៃសាធារណរដ្ឋចិន ដែលជាដៃគូដ៏មានសារសំខាន់ ជាដៃគូមិត្តភាពដ៏ល្អបំផុតរបស់អាស៊ាន៕





ប្រចាំខែ មិថុនា ឆ្នាំ ២០២១ | អ្នកនាំសារ the messenger

# ឈ្លូសយក្សត្រូវបានរកឃើញក្នុងព្រៃកម្ពុជា

*អត្ថបទ៖ ព្រះសហគមន៍ភូមិភាគភ្នំពេញ*

សត្វ «ឈ្លូសយក្ស» ជាភាសាបច្ចេកទេស Large-antlered muntjac ឬ Giant muntjac (Muntiacus vuquangensis) ដែលជាប្រភេទសត្វរងគ្រោះជិតផុតពូជខ្លាំងលើពិភពលោកនៅក្នុងបញ្ជីក្រហមរបស់ IUCN ត្រូវបានរកឃើញជាលើកដំបូងនៅក្នុងតំបន់ការពារធម្មជាតិនៃប្រទេសកម្ពុជាក្នុងរយៈពេលជិត ៣០ ឆ្នាំ។

ការរកឃើញនេះ ចាប់តាំងពីពេលដែលអ្នកជំនាញបានរកឃើញលើកដំបូងនៅឆ្នាំ១៩៩៤ក្នុងប្រទេសវៀតណាម និងឡាវនៅតាមជួរភ្នំអាណាមដែលលាតសន្ធឹងដល់ឧទ្យានជាតិវីរៈជ័យ ភាគឦសានប្រទេសកម្ពុជា។

នេះគឺជា ការប្រកាសឱ្យដឹងរបស់លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការនិងជាមន្ត្រីនាំពាក្យក្រសួងបរិស្ថាននៅថ្ងៃទី២៤ ខែមិថុនា នេះដោយឈរលើទិន្នន័យរូបភាពប្រមូលបានពីម៉ាស៊ីនថតស្វ័យប្រវត្តិដាក់ដោយមន្ត្រីក្រសួងបរិស្ថាន ដើម្បីសិក្សាស្រាវជ្រាវសត្វព្រៃកម្រៗនៅក្នុងឧទ្យានជាតិវីរៈជ័យ ភូមិសាស្ត្រខេត្តរតនគិរី ចាប់ពីខែមីនាដល់ខែឧសភា ឆ្នាំ២០២១នេះ។

លោក នេត្រ ភក្ត្រា បានថ្លែងថា ៖ «នេះគឺជាដំណឹងដ៏រីករាយបំផុតសម្រាប់កម្ពុជា និងសម្រាប់ពិភពលោកទាំងមូលដែលប្រភេទសត្វកម្ររងគ្រោះជិតផុតពូជខ្លាំងបំផុតនេះ មានវត្តមាននៅ ក្នុងប្រទេសកម្ពុជា និងបានថ្លែងកោតសរសើរចំពោះក្រុមមន្ត្រីក្រសួងបរិស្ថាន ប្រជាសហគមន៍ដែលបានរួមគ្នាចុះសិក្សាស្រាវជ្រាវប្រភេទសត្វព្រៃនៅក្នុងឧទ្យានជាតិវីរៈជ័យដែលបានបានលះបង់កម្លាំងកាយចិត្តក្នុង ការធ្វើដំណើរដ៏លំបាកក្នុងព្រៃដើម្បីបំពេញការងាររបស់ខ្លួន»។

លោកបានថ្លែងថា លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះពិតជាមានតម្លៃបំផុតសម្រាប់ការអភិរក្សជីវៈចម្រុះ និងអ្នកបរិស្ថានហើយចាំបាច់





ទាំងអស់គ្នាត្រូវចូលរួមការពារនិងអភិរក្សប្រភេទសត្វដ៏កម្រនេះឱ្យបានគង់វង្សក្នុងព្រៃកម្ពុជា។

លោកនេត្រ ភក្ត្រាថា ៖ «ដោយការការពារ និងអភិរក្សធនធានធម្មជាតិបានល្អប្រសើរដែលជាទីជម្រក កន្លែងរកចំណី និងប្រភព ទឹកដែលជាតម្រូវការចាំបាច់សម្រាប់ការរស់នៅរបស់សត្វព្រៃ យើងឃើញមានវត្តមាន ប្រភេទសត្វកម្រៗជាច្រើនប្រភេទចាប់ផ្តើមមានវត្តមាននៅក្នុងព្រៃកម្ពុជាឡើងវិញ។ នេះគឺជាលទ្ធផលដ៏ជំរុញមួយនៃកិច្ចខិតខំប្រឹងប្រែងអភិរក្សធនធានធម្មជាតិរបស់រាជរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធទាំងអស់»។

ចំណែកឯ ប្រធានក្រុមការងារស្រាវជ្រាវនៃនាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គនៃក្រសួងបរិស្ថានដែលដឹកនាំការស្រាវជ្រាវឧបត្ថម្ភគាំទ្រដោយក្រសួងបរិស្ថាន និងការិយាល័យស្រាវជ្រាវអភិរក្សសត្វព្រៃ (WildCRU) នៃសាកលវិទ្យាល័យ Oxford ចក្រភពអង់គ្លេស លោក ពិន ច័ន្ទរតនា បានថ្លែងថា សត្វឈ្លូសយក្សចូលចិត្តរស់នៅក្នុងព្រៃស្រោងនិងព្រៃពាក់កណ្តាលស្រោងមានរយៈកម្ពស់ខ្ពស់ (រហូតដល់ជាង ១០០០ម៉ែត្រពីនីវ៉ូសមុទ្រ)។

លោកថា នៅកំឡុងទសវត្សឆ្នាំ៩០ ស្នែងឈ្លូសយក្សត្រូវបានឃើញដាក់លក់នៅក្នុងភូមិដាច់ស្រយាលមួយនៃខេត្តមណ្ឌលគិរី ប្រទេសកម្ពុជា ប៉ុន្តែមិនដែលមានការរាយការណ៍ពីការឃើញខ្លួនវាដោយផ្ទាល់នោះទេ។

លោកពិន ច័ន្ទរតនា បានថ្លែងថា ៖ «ឈ្លូសយក្សជាប្រភេទឈ្លូសដែលមានមាឌធំជាងគេអាចមានទម្ងន់លើសពី ៣០គីឡូក្រាមក្នុងមួយក្បាល និងស្ថិតក្នុងចំណោមឈ្លូសទាំង១២ប្រភេទ ហើយលក្ខណៈខុសគ្នារវាងសត្វឈ្លូសយក្សនិងសត្វឈ្លូសធម្មតា Northern red muntjact (Muntiacus vaginalis) ដែលមានវត្តមានស្ទើរតែនៅទូទាំងប្រទេសកម្ពុជាយើង»។

ភាពខុសគ្នាទាំងនោះគឺ ត្រង់ចំណុចបីសំខាន់៖ ទី១)ស្នែង៖ ស្នែងសត្វឈ្លូសយក្សមានទំហំធំជាងស្នែងសត្វឈ្លូសធម្មតា ខ្នែងស្នែងតូច ដុះស្រប ឬក៏ដុះបែកងាកចេញក្រៅពីខ្នែងមេ ហើយគល់ស្នែងរបស់ឈ្លូសយក្សខ្លីជាងគល់ស្នែងរបស់ឈ្លូសធម្មតា។ ទី២) កន្ទុយ៖ កន្ទុយរបស់សត្វឈ្លូសយក្សមានប្រវែងខ្លីជាង (ប្រហែល១/៣) កន្ទុយរបស់សត្វឈ្លូសធម្មតា ហើយកន្ទុយនោះមានរាងត្រីកោណ និងមានពណ៌សនៅផ្នែកខាងក្រោម និងទី៣) ថ្ពាល់របស់សត្វឈ្លូសយក្សញី មានពណ៌ក្រម៉ៅ (ស្ទើរតែខ្មៅតែម្តង) ជាងថ្ពាល់ឈ្លូសធម្មតា។

តាមរយៈការសិក្សារកឃើញវត្តមានសត្វឈ្លូសយក្សនេះ លោក នេត្រ ភក្ត្រា ថា ក្រសួងបរិស្ថាននឹងបញ្ចូលប្រភេទសត្វនេះទៅក្នុងបញ្ជីជីវៈចម្រុះដែលមាននៅក្នុងប្រទេសកម្ពុជា។

កម្ពុជាដែលតាមការបញ្ជាក់របស់រដ្ឋលេខាធិការក្រសួងបរិស្ថាន ត្រូវបានអ្នកជំនាញស្រាវជ្រាវឃើញថាជាប្រទេសសម្បូរទៅដោយជីវៈចម្រុះដែលបានបង្ហាញវត្តមានប្រភេទថនិកសត្វ ១២៣ ប្រភេទ សត្វស្លាប ៥៤៥ ប្រភេទ ឧរង្គសត្វ ៨៨ ប្រភេទ រុក្ខជាតិតូចៗ (vascular plants) ២៣០៨ប្រភេទ ត្រី ៨៧៤ ប្រភេទ ផ្កាថ្មរឹង២៤ប្រភេទ ផ្កាថ្មទន់ ១៤ ប្រភេទ ស្មៅសមុទ្រ ១០ ប្រភេទ និងថលជលិក ៦៣ ប្រភេទ។

នៅមានវត្តមានប្រភេទរុក្ខជាតិ និងសត្វមួយចំនួនទៀតដែលមិនទាន់សិក្សាស្រាវជ្រាវ និងកំណត់អត្តសញ្ញាណនៅឡើយ។ មានប្រភេទរុក្ខជាតិ និងសត្វដែលបានកំណត់ក្នុងបញ្ជីក្រហមរបស់អង្គការសហភាពអន្តរជាតិ ដើម្បីការអភិរក្សធម្មជាតិ (IUCN) ក្នុងតារាង១ ដូចជា៖ ថនិកសត្វ៣៩ប្រភេទ សត្វស្លាប៣៦ប្រភេទ ឧរង្គសត្វ១៣ប្រភេទ រុក្ខជាតិតូចៗ (vascular plants) ៣៨ប្រភេទ និង ថលជលិក១២ប្រភេទ ។

លោកបានអំពាវនាវប្រជាពលរដ្ឋចូលរួមការពារនិងអភិរក្សសត្វព្រៃដែល កម្ពុជាមានជាពិសេសប្រភេទសត្វពូជកម្រៗជិតផុតពូជនៅលើពិភពលោកឱ្យបានគង់វង្ស។ ប្រភេទសត្វឈ្លូសយក្សនេះ ត្រូវបានចាត់ជាប្រភេទរងគ្រោះជិតផុតពូជខ្លាំង (Critically Endangered) នៅក្នុងបញ្ជីក្រហមរបស់ IUCN ហើយកត្តាគំរាមកំហែងដល់សត្វឈ្លូសយក្ស គឺការបរបាញ់យកស្នែង និងសាច់។ ដូច្នេះយើងត្រូវនិយាយថាទេចំពោះសាច់សត្វព្រៃ និងសូមកុំបរិភោគសាច់សត្វព្រៃដើម្បីបញ្ឈប់ការបរបាញ់ និងការដាក់អន្ទាក់សម្លាប់សត្វដោយខុសច្បាប់៕

## WHO នៅកម្ពុជា៖ មិនចាំបាច់ ធ្វើតេស្តរកអង់ទីគ័រក្រោយចាក់វ៉ាក់សាំងឡើយ

*អត្ថបទ៖ ផល សុជានិត*

តំណាងអង្គការ សុខភាពពិភពលោកប្រចាំកម្ពុជា (WHO) ថ្លែងថា គ្មានការចាំបាច់ទេក្នុងការធ្វើតេស្តរកអង់ទីគ័រក្រោយពេលចាក់វ៉ាក់សាំងរួច ខណៈវ៉ាក់សាំងដែលកម្ពុជាកំពុងចាក់ជូនប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន ត្រូវបានអង្គការសុខភាពពិភពលោកទទួល ស្គាល់និងបាន ដាក់ចូលក្នុងបញ្ជីប្រើប្រាស់បន្ទាន់ក្នុងគ្រាអាសន្នរួចហើយ។

លោកស្រី លី អាយលែន តំណាងអង្គការសុខភាពពិភពលោកប្រចាំកម្ពុជាហៅកាត់ថា (WHO) មានប្រសាសន៍ឱ្យដឹងថា មានហេតុផល២យ៉ាង ដែលបុគ្គលចាក់វ៉ាក់សាំង មិនចាំបាច់ទៅរកការធ្វើតេស្តរកអង់ទីគ័រការពារជំងឺកូវីដ១៩នោះ គឺអង្គការ សុខភាពពិភពលោកមិនធ្លាប់បានផ្តល់អនុសាសន៍ដល់ប្រជាពលរដ្ឋឱ្យទៅទិញឧបករណ៍ធ្វើតេស្តរកអង់ទីគ័រនោះទេ ហើយឧបករណ៍ធ្វើតេស្តរកអង់ទីគ័រនេះ មិនទាន់បានទទួលស្គាល់ពីអង្គការ WHO ដែរ។



លោកស្រីបន្តថា ម្យ៉ាងវិញទៀត វ៉ាក់សាំងដែលកំពុងប្រើប្រាស់នៅកម្ពុជានាពេលនេះ គឺត្រូវបានអង្គការសុខភាពពិភពលោកទទួលស្គាល់គុណភាព និងដាក់បញ្ចូលទៅក្នុងបញ្ជីប្រើប្រាស់បន្ទាន់ក្នុងគ្រាអាសន្ន។ ដូច្នេះប្រជាពលរដ្ឋកុំចំណាយថវិកាដើម្បីទិញឧបករណ៍តេស្តរកអង់ទីគ័រនេះ ខណៈអ្វីដែលចាំបាច់ នៅក្នុងពេលនេះ គឺត្រូវទៅចាក់វ៉ាក់សាំង និងត្រូវអនុវត្តតាមវិធានការសុខាភិបាលដែលបានដាក់ចេញនាពេលកន្លងមក ដើម្បីការពារការចម្លងនៃជំងឺកាចសាហាវមួយនេះ។

អង្គការសុខភាពពិភពលោកគឺមិនបានផ្តល់អនុសាសន៍ទេរហូតមកដល់ពេលបច្ចុប្បន្ននេះ ក្នុងការប្រើប្រាស់នូវការធ្វើតេស្តរហ័សដើម្បីរុករកអង់ទីគ័រ ដែលបញ្ជាក់ ពីប្រព័ន្ធការពារនៅក្នុងរាងកាយបន្ទាប់ពីទទួលការចាក់វ៉ាក់សាំង។

មួយទៀតគឺថា រាល់វ៉ាក់សាំង ដែលកំពុងប្រើប្រាស់ក្នុងពេលបច្ចុប្បន្ននេះគឺសុទ្ធតែបានទទួល ស្គាល់ពីអង្គការសុខភាពពិភពលោកដែលហៅថាប្រើប្រាស់នៅក្នុងបញ្ជី នៃការ ប្រើប្រាស់ក្នុងគ្រាអាសន្ន ហើយសុទ្ធតែបានធ្វើការបញ្ជាក់តាមលក្ខណៈវិទ្យាសាស្ត្រ ហើយឆ្លងកាត់នូវការសិក្សាជាច្រើនទាក់ទងទៅនឹងសុវត្ថិភាព និងប្រសិទ្ធភាពនៃវ៉ាក់ សាំងបានន័យថារាល់វ៉ាក់សាំងដែល កំពុងប្រើប្រាស់គឺជាវ៉ាក់សាំងដែលមានគុណភាពនិងទទួលស្គាល់ពីអង្គការសុខភាពពិភពលោកផងដែរ។

កាលពីពេលថ្មីៗនេះ ក្រសួងសុខាភិបាលបានអំពាវនាវយ៉ាងទទូច ដល់ប្រជាពលរដ្ឋទាំងអស់ មិនត្រូវ នាំគ្នាទៅធ្វើតេស្តរកអង់ទីគ័រការពារជំងឺកូវីដ-១៩ ដោយប្រើប្រាស់ ឧបករណ៍តេស្តរហ័សខុសច្បាប់នេះជាដាច់ខាត និងត្រូវតែបន្តអនុវត្ត ឱ្យបានខ្ជាប់ខ្ជួននូវវិធានការការ ពារដែលបានដាក់ ចេញដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែននាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាគឺ ៣ការពារ (ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាព បុគ្គល ពីមួយម៉ែត្រកន្លះ ឡើង) និង ៣កុំ (កុំទៅកន្លែងមានមនុស្សកុះករច្រើន កុំទៅ កន្លែងបិទជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា) ដើម្បីការពារការចម្លងជំងឺកាចសាហាវកូវីដ-១៩ ៕

# លោកអភិបាលអូលីវីយេ៉ ផ្តល់ជំនួយជូនរដ្ឋបាលខេត្តតាកែវ






*អត្ថបទ៖ ព្រះសហគមន៍ភូមិភាគភ្នំពេញ*

នៅព្រឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ ព្រះសហគមន៍កាតូលិកកម្ពុជា ភូមិភាគភ្នំពេញដឹកនាំដោយលោក អូលីវីយេ៉ ជ្មិតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគភ្នំពេញ និងក្រុមការងារបាននាំយកជំនួយឧបត្ថម្ភជាអង្ករចំនួន២តោន ម៉ាសចំនួន២ម៉ឺនម៉ាស និង២០០កញ្ចប់ ជូនដល់រដ្ឋបាលក្រុងដូនកែវ សម្រាប់បែងចែកអំណោយទាំងនេះទៅតាមមណ្ឌលចត្តាឡីស័កនៅក្នុងក្រុងដូនកែវ ខេត្តតាកែវ។

ថ្លែងក្នុងជំនួបទទួលអំណោយជំនួយឧបត្ថម្ភពីលោកអភិបាលព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគភ្នំពេញ លោក កង អាណាន់ អភិបាលក្រុងដូនកែវ បានសម្តែងទឹកចិត្តសប្បាយចិត្តជាខ្លាំងចំពោះជំនួយឧបត្ថមដែលទទួលបាននេះ ព្រោះថា ការជួយជាជំនួយពីព្រះសហគមន៍កាតូលិកកម្ពុជា បិតក្នុងកាលៈទេសៈមួយដែលអាជ្ញាធរក្រុងកំពុងតែត្រូវការជាចាំបាច់ក្នុងការនាំយកអំណោយដែលទទួលបានពីខាងបងប្អូនសប្បុរសជន ក៏ដូចជាស្ថាប័នផ្សេងៗ យកចុះចែកជូនដល់បងប្អូនប្រជាពលរដ្ឋដែលកំពុងធ្វើចត្តាឡីស័កនៅតាមមណ្ឌលនីមួយនៅក្នុងក្រុងដូនកែវ។

ជាមួយគ្នានេះផងដែរ តាំងនាមឱ្យរដ្ឋបាលក្រុងដូនកែវ ក៏បានថ្លែងអំណរអរគុណដល់ ព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគភ្នំពេញ ដែលនាំយកជំនួយនេះមកផ្តល់ដល់សាលាក្រុងដូនកែវ និងបានជូនពរដល់លោក អូលីវីយេ៉ និងក្រុមការងាររបស់លោកជួបប្រទះតែសំណាងល្អ៕








# ព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគភ្នំពេញជូនម៉ាសចំនួន ២ម៉ឺន ម៉ាសដល់គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា

*អត្ថបទ៖ ព្រះសហគមន៍ភូមិភាគភ្នំពេញ*

នៅរសៀលថ្ងៃទី១៨ ខែមិថុនានេះ មានលោកបូជាចារ្យកាតូលិក សួន ហង្សលី តំណាងពេញសិទ្ធិ លោកអូលីវីយេ៉ ជ្មិតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានជូនម៉ាសចំនួន២ម៉ឺនម៉ាសដល់គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ដែលទទួលដោយលោកសឹម ម៉ាត់ទោត តំណាងឲ្យលោកឧញ៉ា សុះកំរី ជាគណៈដឹកនាំ។

ក្នុងពិធីប្រគល់ម៉ាស់នេះ លោកបូជាចារ្យកាតូលិក សួន ហង្សលី បានអានលិខិតរបស់លោកអភិបាលអូលីវីយេ៉ ផ្ញើជូនលោកឧញ៉ា សុះកំរី អំពីកិច្ចការមួយចំនួនដែលព្រះសហគមន៍កាតូលិកបាន និងកំពុងធ្វើក្នុងអំឡុងពេលនៃការរាលដាលនៃជំងឺកូវីដ-១៩ ក្នុងប្រទេសកម្ពុជា។

លោកបានបន្តថា ក្នុងពេលនេះ កាតូលិកកម្ពុជាភូមិភាគភ្នំពេញ មានសេចក្តីសោមនស្សរីករាយសូមផ្តល់ជូននូវម៉ាសចំនួន ២ម៉ឺនម៉ាស ដល់ លោកឧកញ៉ា នៃដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ដើម្បីប្រើប្រាស់ និងចែកជូនបងប្អូនប្រជាពលរដ្ឋតាមសេចក្តីត្រូវការ ក្នុងការពារ និងប្រយុទ្ធប្រឆាំនឹងការឆ្លងរីករាលដាល់នៃមេរោគឆ្លងកូវីដ-១៩ ។



ក្នុងឱកាសនោះដែរ លោកសឹម ម៉ាត់ទោត បានមានប្រសាសន៍ថ្លែងអំណរគុណយ៉ាងខ្លាំងចំពោះព្រះសហគមន៍កាតូលិក ដែលតែងតែយកចិត្តទុកដាក់ និងបង្ហាញនូវសាមគ្គីភាព ចំពោះបងប្អូនសាសនាឥស្លាមនៅកម្ពុជា។ លោកបន្តថា នេះជាលើកទី២ហើយដែលព្រះសហគមន៍កាតូលិក បានយកសម្ភារបរិក្ខាដើម្បីទប់ទល់នឹងកូវីដ-១៩ ជូនដល់គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ដែលលើកទី១ គឺមានម៉ាសនិងអាកុល។

សូមជំរាបថា ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដឹកនាំដោយលោកអភិបាលអូលីវីយេ៉ បានយកចិត្តទុក ដាក់យ៉ាងខ្លាំង ក្នុងការចូលរួមប្រយុទ្ធប្រឆាំង នឹងមេរោគឆ្លងកូវីដ-១។ ជាពិសេស យកចិត្តទុកដាក់ ចំពោះបងប្អូនដែលងាយរងគ្រោះ និងរងផលប៉ះពាល់យ៉ាងខ្លាំង ពីកូវីដ-១៩ ដូចជាការចែកស្បៀង និងម្ហូបអាហារ ដល់អ្នកខ្វះខាត និងជនក្រីក្រក្នុងតំបន់បិទខ្ទប់ជាដើមចំនួនជាង១០០០ គ្រួសារ ក៏ដូចជាការប្រគល់ម៉ាសជូន ក្រសួងមន្ទីរ និងអាជ្ញាធរមូលដ្ឋានផងដែរ។ ក្នុងពេលតែមួយព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញក៏បានបន្តកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាព និងសុខដុមរមនាកម្មសាសនា ដោយថ្វាយ ប្រគេន និងជូនម៉ាសដើម្បីការពារមេរោគឆ្លងកូវីដ-១៩ ដល់សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ប្រគេនដលើព្រះសង្ឃតាមវត្ត និង ប្រគល់ជូន គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជានាពេលនេះ៕

# លោកបូជាចារ្យកាតូលិកភូមិភាគភ្នំពេញ ប្រកាសពាក្យសច្ចាប្រណិធានសាជាថ្មី

*អត្ថបទ៖ ដាលីស*

អស់លោកបូជាចារ្យកាតូលិកភូមិភាគភ្នំពេញប្រកាសពាក្យសច្ចាប្រណិធានសាជាថ្មី ដើម្បីរំឭ កពីតួនាទីរបស់ខ្លួនជាបូជាចារ្យ ដោយមានពិធីបុណ្យអភិបូជា ដោយមានការចូលរួមដោយលោកអភិបាលអូលីវីយ៉េ ជ្មីតហាស្លេ និងតំណាងបូជាចារ្យប្រធានមណ្ឌលសកម្មភាពទាំង៩ នៃព្រះសហគមន៍ភូមិភាគភ្នំពេញ។





ពិធីនេះក៏មានការចូលរួមពីតំណាងគ្រីស្តបរិស័ទមួយចំនួនតូច និងមានការផ្សាយផ្ទាល់លើបណ្តាញសង្គម ចេញពីព្រះវិហារសន្តសិលា និងសន្តប៉ូលភ្នំពេញថ្មី ក្នុងឱកាសអភិបូជាប្រសិទ្ធពរលើប្រេងពិសិដ្ឋ កាលពីថ្ងៃទី២៨ ខែមិថុនាកន្លងទៅនេះ។

នៅក្នុងធម្មទេសនានៃពិធីបុណ្យអភិបូជានេះ លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញអូលីវីយ៉េ បានលើកឡើងថា ដោយក្រើនរំឭកអស់លោកបូជាចារ្យទាំងអស់ថា៖ «បន្តិចទៀត យើងនឹងឆ្លើយអស់ពីដួងចិត្ត ដោយបំពេញកិច្ចការតាមព្រះជាម្ចាស់ និងស្ថានភាពកូវីដ-១៩នាំឱ្យយើងស្ថិតនៅក្នុងស្ថានភាពមួយទៀត»។

លោកអូលីវីយ៉េបានបន្តថា ពេលខ្លះ ត្រូវថ្វាយអភិបូជាម្នាក់ឯង មិនមែនមានន័យថាឯកោ ប៉ុន្តែជាពេលវេលាដើម្បីប្រមូលបទពិសោធន៍នឹងគ្រីស្តបរិស័ទថែមទៀត ដោយមានពេលវេលាស្រាវជ្រាវ និងអាចទាក់ទងទៅគ្រីស្តបរិស័ទតាមទូរសព្ទ និងប្រព័ន្ធផ្សព្វផ្សាយ។

លោកអភិបាលបន្ថែមថា ៖ «ដូច្នេះនៅក្នុងកូវីដ-១៩នេះ យើងរកឃើញរបៀបថ្មីដើម្បីបម្រើព្រះជាម្ចាស់តាមរបៀបថ្មី។ កូវីដ-១៩ ធ្វើឱ្យយើងយកពេលគិតថែមទៀតដើម្បីយកចិត្តទុកដាក់ជាមួយអ្នកក្រីក្រ អាជ្ញាធរដែនដី និងយកចិត្តទុកដាក់ជាមួយកូនក្មេង ហើយពិតមែននេះជាពេលវេលាឱ្យយើងចូលយ៉ាងជ្រៅនៅក្នុងតួនាទីរបស់យើងជាអ្នកបម្រើ»។

លោកអភិបាលរូបនេះបានថ្លែងថា ៖ «ពិតមែនជារបៀបផ្សេង ប៉ុន្តែចូលទៅក្នុងជីវិត បេសកកម្ម និងដួងចិត្តរបស់យើង នៅថ្ងៃនេះមិនមែនថ្ងៃស្អែក»។

គង្វាលព្រះសហគមន៍ភូមិភាគភ្នំពេញ បានថ្លែងលើកទឹកចិត្តដល់អស់លោកបូជាចារ្យផងដែរថា បងប្អូនជាទីស្រឡាញ់! យើងបន្តធ្វើដំណើរ ជូនកាលយើងឈឺចិត្ត ជូនកាលយើងអស់សង្ឃឹម ប៉ុន្តែសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ជំរុញយើងដើម្បីប្រកាសដំណឹងល្អដែលជាបេសកម្មរបស់យើង។

លោកបូជាចារ្យ ហ្វេរណាន់ដូ អារាំងហ្គូ ប្រធានមណ្ឌលសកម្មភាពតាកែវបានលើកឡើងដែរថា ការរំឭកពាក្យសច្ចាប្រណិធានជាបូជាចារ្យសាជាថ្មីជារៀងរាល់ឆ្នាំនេះ ដើម្បីឆ្លើយតបនឹងបម្រើប្រជាជនរបស់ព្រះជាម្ចាស់ដែលព្រះជាម្ចាស់បានប្រោសប្រទានឱ្យ។

លោកមានប្រសាសន៍ថា ៖ «តាមរយៈអគ្គសញ្ញាដ៏សំខាន់នេះ យើងនឹងបន្តរួមរស់រួមស្លាប់ជាមួយព្រះយេស៊ូគ្រីស្ត ដែលជាបូជាចារ្យដ៏ពិតប្រាកដ ហើយជាសេចក្តីពិត និងជាជីវិត ដែលបានត្រាស់ហៅយើងជាបូជាចារ្យនិងចាត់ឱ្យយើងទៅក្នុងនាមព្រះជាម្ចាស់ជាព្រះបិតា មិនមែនទៅដោយផ្ទាល់ខ្លួននោះទេ»។

លោកបូជាចារ្យ ហ្វេរណាន់ដូ បានបន្ថែមថា ពិធីនេះរំឭកអំពីតួនាទីនៃបូជាចារ្យដែលជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ជាបូជាចារ្យដែលត្រូវបូជាជីវិតសម្រាប់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ និងត្រូវស្រឡាញ់បងប្អូនឯទៀតៗឱ្យបានដូចព្រះយេស៊ូដែលបានស្រឡាញ់អ្នករាល់គ្នាដែរ។

តាមប្រពៃណីព្រះសហគមន៍កាតូលិក តែងតែអញ្ជើញអស់លោកបូជាចារ្យទាំងអស់ឱ្យប្រារព្ធពិធីប្រកាសពាក្យសច្ចាប្រណិធានសាជាថ្មី នៅក្នុងឱកាសតែមួយជាមួយនឹងពិធីបុណ្យប្រសិទ្ធិពរលើប្រេង ដែលតែងតែប្រារព្ធពិធីប្រសិទ្ធិពរលើប្រេងពិសិដ្ឋទាំងនេះនៅក្នុងរដូវអប់រំពិសេស ឬរដូវត្រៃណមមុនថ្ងៃបុណ្យចម្លងមួយសប្តាហ៍ តាមប្រពៃណីព្រះសហគមន៍កាតូលិកដោយមានលោកអភិបាលទាំងបីភូមិភាគជាអ្នកប្រសិទ្ធិពរ។ ដោយឡែកនៅក្នុងឆ្នាំនេះព្រះសហគមន៍កាតូលិកកម្ពុជាបានលើកពេលវេលាមកធ្វើនៅថ្ងៃនេះវិញ ដោយសារស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩បានធ្វើឱ្យព្រះសហគមន៍ត្រូវពន្យារពេលនៃការប្រារព្ធពិធីនេះ៕

# កុមារ ឈ្វេងយល់ដឹងពីសិទ្ធិ និងការការពារខ្លួនពីកូវីដ១៩

*អត្ថបទ៖ ដាលីស*

កុមារចំនួន៣៥នាក់ដែលមានអាយុចន្លោះពី៥ដល់១៤ឆ្នាំ នៅព្រះវិហារបរិសុទ្ធ ព្រះសហគមន៍សំរោងធំ ក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល ចូលរួមទិវាសិទ្ធិកុមារអន្តរជាតិ នាព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២១ ។



កុមារដែលចូលរួមក្នុងកម្មវិធីនេះ ទទួលបានការអប់រំ និងលើកទឹកចិត្តកុមារ ឱ្យស្គាល់អំពីសិទ្ធិដែលអាទិភាពរបស់ខ្លួន ព្រមទាំងរៀនពីរបៀបសម្របខ្លួនក្នុងរស់នៅក្នុងសម័យកូវីដ-១៩នេះ។

កញ្ញា គុំ ធីតា មេកាយឫទ្ធិ និងជាគ្រូមត្តេយ្យនៅព្រះសហគមន៍សំរោងធំបានឱ្យដឹងថា កម្មវិធីនេះយើងពន្យល់ពីអត្ថន័យនៃសិទ្ធិទាំង៤ឱ្យកុមារយល់ច្បាស់ និងអនុវត្តផ្ទាល់ខ្លួនមានដូចជា សិទ្ធិរស់រានមានជីវិតដែលមានជម្រក និងអាហារ សិទ្ធិទទួលបានការថែទាំនិងព្យាបាល សិទ្ធទទួលបានការសិក្សាអប់រំ និងសិទ្ធក្នុងការកម្សាន្តរីករាយ។

អ្នកគ្រូ ធីតាបន្ថែមថា ក្រៅពីសិទ្ធិទាំងនេះយើងក៏ណែនាំក្មេងៗឱ្យយល់ពីការណែនាំរបស់ព្រះសហគមន៍តាមរយៈសារលោកអភិបាលអូលីវីយ៉េ ដោយផ្តោតលើចំណុចសំខាន់ៗមាន៖ ៣ការពារមានពាក់ម៉ាស់ លាងដៃនិងរក្សាគម្លាត។ ៣កុំមាន៖ កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល កុំទៅកន្លែងមនុស្សច្រើន កុំប៉ះពាល់គ្នាដោយចាប់ដៃ ឬឱបគ្នា។ ព្រមទាំង៣ថៃរក្សា ដោយមានទំនួលខុសត្រូវ សាមគ្គីភាព និងការអធិដ្ឋាន។

អ្នកគ្រូធីតាបន្តថា ៖ «ដោយបញ្ហាកូវីដ-១៩ យើងមិនអាចជុំគ្នាចំនួនច្រើនដូចមុន ហើយរយៈពេលក៏ខ្លីក្នុងការអប់រំ។ ខ្ញុំយល់ឃើញថា នៅក្នុងសម័យកូវីដ-១៩នេះ កូនក្មេងនៅផ្ទះច្រើន មិនសូវទទួលបានការអប់រំដូចមុនទេ»។

អ្នកគ្រូបានបន្តថា ៖ «ដូច្នេះកម្មវិធីនេះពិតជាមានប្រយោជន៍ក្នុងការជួយដល់ក្មេងៗឱ្យទទួលបានការអប់រំខ្លះៗ ហើយក៏មានប្រយោជន៍ក្នុងព្រះសហគមន៍ដោយសង្ឃឹមថាអាចជួយក្មេងតាមរយៈកម្មវិធីដែលយើងអាចធ្វើបាន និងបត់បែនតាមកាលៈទេសៈ»។

ទិវាសិទ្ធិកុមារនេះ រៀបចំឡើងស្របតាមការណែនាំរបស់លោកអភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ អូលីវីយ៉េ ជ្មីតហាស្លេ និងដោយមានការជំរុញ និងគាំទ្រដោយការិយាល័យយុវជន ជំទង់ និងកុមារនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញមានរយៈពេល៤សប្តាហ៍ ដោយគិតចាប់ពីដើមខែរហូតដល់ចុងខែមិថុនា តាមរយៈមេកាយឫទ្ធិនឹងទៅអប់រំកុមារកាយឫទ្ធិតាមផ្ទះជារៀងរាល់ថ្ងៃ ដើម្បីលើកទឹកចិត្តកុមារ ក៏ដូចជានៅតាមព្រះសហគមន៍នីមួយៗ ព្រមទាំងចែកកញ្ចប់អនុស្សាវរីយ៍ដល់កុមារផងដែរ ប៉ុន្តែអនុវត្តតាមវិធានសុខាភិបាល។

លោក ស៊ាន់ សារឿន ប្រធានការិយាល័យយុវជន ជំទង់ និងកុមារ ឆ្លាប់ឱ្យដឹងថា ឆ្នាំនេះការិយាល័យយើងបានរៀបចំយុទ្ធនាការសិទ្ធិកុមារ ដោយមានសម្ភារៈអប់រំដល់កុមារឱ្យមានការយល់ដឹងពីសិទ្ធិ និងសេរីភាពរបស់ក្នុងសង្គម។ ជាពិសេសចង់បង្ហាញពីការយកចិត្តទុកដាក់ពីព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញចំពោះកុមារ។

លោកសារឿនបានឱ្យដឹងទៀតថា អ្វីដែលសំខាន់ជាងនេះគឺចង់បញ្ជ្រាបកុមារ ឱ្យយល់ដឹងអំពីការអប់រំរបស់លោកអភិបាលអូលីវីយ៉េ នៅក្នុងបរិបទកូវីដ-១៩នេះដោយផ្តោតសំខាន់លើ៣ថៃរក្សា គឺការទទួលខុសត្រូវ សាមគ្គីភាព និងអធិដ្ឋាន។

លោកសារឿងបន្ថែមថា ៖ «គោលបំណងរបស់យើងជារៀងរាល់ឆ្នាំ គឺធ្វើឡើងដើម្បីធ្វើយ៉ាងណាជួយឱ្យកុមារយល់ពីតម្លៃ និងសិទ្ធិធំៗរបស់ពួកគាត់ទាំង៤ច្បាស់ ព្រមទាំងឱ្យកុមារទទួលបានអំណរសប្បាយតាមរយៈការបង្កើតកម្មវិធីរបស់យើង»៕

# លោកអភិបាលអូលីវីយេ ផ្តល់គ្រឿងឧបភោគ និងថវិកា ដល់គ្រួសាររុះរើលំនៅពីផ្ទៃទន្លេ



*អត្ថបទ៖ លី សុវណ្ណា*

លោកអភិបាល អូលីវីយេ អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ អញ្ជើញទៅសួរសុខទុក្ខនិងចែកគ្រឿងឧបភោគបរិភោគព្រមទាំងថវិកាមួយចំនួន ជូនបងប្អូនប្រជាពលរដ្ឋចំនួន ១០០គ្រួសារ ដែលបានរុះរើ ផ្ទះបណ្តែតទឹកចេញពីដងទន្លេបាសាក់ ស្ថិតក្នុងសង្កាត់ព្រែកប្រាខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

លោកអភិបាល បានលើកទឹកចិត្តបងប្អូនឲ្យមានការតស៊ូ ក្នុងជីវិតកុំអស់សង្ឃឹម ជាពិសេសក្នុងបរិបទនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ត្រូវតែថែរក្សា អនាម័យជានិច្ច និងរស់នៅរក្សាគម្លាតផងដែរ។ លោកថា "ត្រូវគោរពវិធានរបស់ក្រសួងសុខាភិបាលជានិច្ច ៣ការពារ និង ៣កុំ"។ ជាមួយគ្នានេះដែរ លោកអភិបាលបានរំលឹកបងប្អូនថា៖ «ត្រូវយកចិត្តទុកដាក់រស់នៅដោយគោរពច្បាប់របស់ប្រទេសកម្ពុជាជានិច្ចផងដែរ»។

ដូនជីដួង ខន្តី នៃក្រុមគ្រួសារបងស្រីឧបការគុណនាទីក្រុងភ្នំពេញ បានអញ្ជើញទៅសួរសុខទុក្ខដល់គ្រួសារដែលមានផ្ទះបណ្តែតលើទឹកទាំងនោះ កាលពីប៉ុន្មានសប្តាហ៍មុន។ ដូនជីរូបនេះ បានឲ្យដឹងថាប្រជាជននៅទីនេះ ភាគច្រើនពួកគាត់គ្មានកន្លែងស្នាក់អាស្រ័យទេ គឺត្រូវជួលផ្ទះគេ ឬរស់នៅលើដីដែលសុំគេបណ្តោះអាសន្ន។



ដូនជីបន្ថែមថា៖ «នៅទីនេះ ភាគច្រើនគ្រួសារវៀតណាម និងមានបងប្អូនខ្មែរតិចតួច ដែលគ្មានដីនៅលើគោកទេ។ ពួកគាត់នេសាទត្រី»។

ក្រោយពីរុះរើ គ្រួសារទាំងនោះជួបការលំបាកខ្លាំង ដោយត្រូវផ្លាស់ប្តូររបៀបរស់នៅថ្មី និងសម្របខ្លួនទៅក្នុងបរិយាកាសលើដីគោក ជាពិសេសគឺមុខរបរចិញ្ចឹមជីវិត។ «អ្នកខ្លះគាត់រើសអេតចាយ អ្នកខ្លះទៀតលាងចានឲ្យគេ អ្នកខ្លះទៀតអត់ដឹងរកអី» ដូនជីបន្ថែម។

កន្លងមកក្រុមដូនជីបានផ្តល់នូវគ្រឿងឧបភោគបរិភោគដល់គ្រួសារខ្វះខាតខ្លាំងមួយចំនួន ហើយនៅថ្ងៃនេះ បានស្នើសុំលោកអភិបាលអូលីវីយេ អភិបាលនៃព្រះសហគមន៍ភូមិភាគភ្នំពេញនូវសម្ភារមួយចំនួន ដើម្បីជូនដល់គ្រួសារទាំង ១០០ គ្រួសារ។

គ្រឿងឧបភោគទាំងនោះរួមមាន មីមួយកេស ត្រីខកំប៉ុង ម៉ាស់មួយប្រអប់ អង្ករ១០គីឡូក្រាម ដើម្បីជួយសម្រួលដល់ជីវភាពរបស់ពួកគាត់មួយរយៈពេលខ្លី។ ក្នុងនោះដែរ លោកអភិបាលបានប្រគល់ប្រាក់ចំនួន១៤ម៉ឺនរៀល ដល់គ្រួសារនីមួយៗ។

តាមប្រសាសន៍របស់ដូនជីខន្តី ឲ្យដឹងទៀតថា គាត់មានគម្រោងបន្តជួយដល់អ្នកខ្វះខាតខ្លាំង ឲ្យមានទីជម្រកសមរម្យ និងជួយរកមុខរបរដើម្បីឲ្យពួកគាត់អាចមានជីវិតល្អប្រសើរបាន។

សូមជំរាបថា កាលពីថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២១ សាលារាជធានីភ្នំពេញបានឲ្យម្ចាស់ផ្ទះបណ្តែតទឹក ផ្ទះទូកតូចៗ បែត្រីបណ្តែតទឹក និងសំណង់មិនរៀបរយនៅលើផ្ទៃទន្លេ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ រុះរើចេញដោយបានទុកពេល១សប្តាហ៍ក្នុងការរុះរើ និងបានបញ្ជាក់ថា ការតាំងទីលំនៅទាំងនេះ គឺខុសនឹងច្បាប់របស់កម្ពុជា ដែលធ្វើឲ្យប៉ះពាល់ដល់ប្រព័ន្ធអេកូឡូហ្ស៊ី មានចរន្តទឹកហូរ គោករាក់ ពិសេសការប្រើប្រាស់ចំណីត្រី និងការបញ្ចេញកាកសំណល់ ការបន្ទោបង់ពាសវាលពាសកាលក្នុងទន្លេ ដែលធ្វើឲ្យខូចខាតធ្ងន់ធ្ងរដល់ជីវៈចម្រុះនៅក្នុងទឹក ខូចគុណភាពទឹក បំពុលបរិស្ថាន និងប៉ះពាល់ដល់សោភណ្ឌភាពរាជធានីភ្នំពេញ និងប៉ះពាល់ដល់សុខភាពប្រជាជនដែលប្រើប្រាស់ទឹកមិនស្អាត។

ជាមួយគ្នានេះដែរ រដ្ឋបាលរាជធានី ក៏បានឲ្យដឹងទៀតថា អ្នកដែលរឹងទទឹងមិនព្រមរុះរើ នឹងត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមផ្លូវច្បាប់៕





# សារៈសំខាន់នៃប្រេងក្នុងព្រះសហគមន៍កាតូលិក

*អត្ថបទ៖ លោកបូជាចារ្យដាមីញ៉ាំង ហ្វារនី តំណាងភូមិភាគភ្នំពេញនៃគណៈកម្មការពិធីបុណ្យព្រះសហគមន៍កាតូលិកកម្ពុជា*

ប្រេង មានមុខងារយ៉ាងសំខាន់នៅក្នុងពិធីបុណ្យពិសេសៗនៅក្នុងប្រពៃណីព្រះសហគមន៍កាតូលិក។ ប្រេងពិសិដ្ឋ៣យ៉ាងគឺ៖ សម្រាប់អស់អ្នកដែលត្រៀមទទួលអគ្គសញ្ញាជ្រមុជទឹក សម្រាប់អ្នកជំងឺ សម្រាប់ប្រារព្ធអគ្គសញ្ញាតែងតាំង(ប្រេងគ្រីស្មា)។

នៅក្នុងព្រះគម្ពីរយើងអាចមើលឃើញថា តាំងពីដើមរៀងមកព្រះជាម្ចាស់បង្គាប់ឱ្យមនុស្សប្រើប្រេងដើម្បីប្រារព្ធពិធីផ្សេងៗក្នុងព្រះនាមព្រះជាម្ចាស់។ ប្រេងដែលព្រះសហគមន៍ត្រូវប្រើដើម្បីធ្វើប្រេងដ៏ពិសិដ្ឋគឺប្រេងអូលីវ។ នៅក្នុងព្រះគម្ពីរ ប្រេងបញ្ជាក់ពីសញ្ញាសម្គាល់អំពីជីវិតដែលយើងទទួលពីព្រះជាម្ចាស់ ហើយជីវិតពីព្រះជាម្ចាស់ជាព្រះវិញ្ញាណ។ ដូច្នេះប្រេងពិសិដ្ឋទាំង៣យ៉ាងនេះ ចង់បញ្ជាក់ពីព្រះវិញ្ញាណដ៏វិសុទ្ធដែលចូលជ្រាបនៅក្នុងខ្លួនយើង។ ប្រេងជាអ្វីមួយដ៏ពិសេសមែនទែន ព្រោះថានៅពេលយើងយកប្រេងមកលាបលើស្បែក នោះយើងនឹងឃើញថាប្រេងនឹងជ្រាបចូលក្នុងខ្លួនយើងតែម្តង។ ហើយតាមរយៈប្រេងនេះក៏ជាអគ្គសញ្ញារបស់ព្រះជាម្ចាស់ដែលមានព្រះវិញ្ញាណរបស់ព្រះអង្គជ្រាបចូលក្នុងខ្លួនយើង ដោយប្រោសយើងឱ្យបានវិសុទ្ធ។



អត្ថន័យរបស់ប្រេងទាំងបី

តាំងពីសម្ពន្ធមេត្រីចាស់នៅក្នុងសាសនាយូដាបានប្រើប្រេងដើម្បីអភិសេកតែងតាំងបូជាចារ្យ ព្យាការី និងស្តេច។ ហើយសព្វថ្ងៃ ព្រះសហគមន៍នៅតែបន្តប្រើដើម្បីអភិសេកមនុស្សណាម្នាក់ឱ្យក្លាយជាគ្រីស្តបរិស័ទ តាមរយៈអគ្គសញ្ញាជ្រមុជទឹក ដើម្បីឲ្យគេទទួមុខងារ ជាស្តេចជាបូជាចារ្យ និងជាព្យាការី។ នៅក្នុងអគ្គសញ្ញាលាបថ្ងាស ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ជ្រាបចូលក្នុងខ្លួនរបស់គេ ផ្តល់អំណោយទានទាំង៧យ៉ាង ដើម្បីស្គាល់ព្រះជាម្ចាស់ និងរស់នៅតាមមាគ៌ារបស់ព្រះអង្គ។

ប្រេងមួយទៀត គឺសម្រាប់អ្នកជំងឺ ប្រេងសម្រាប់អ្នកជំងឺ ដែលប្រើសម្រាប់អ្នកដែលឈឺទាំងផ្លូវកាយ និងផ្លូវចិត្តរួមទាំងអស់អ្នកដែលហៀបនឹងអស់ដង្ហើម ដើម្បីជួយពួកគាត់ក្នុងការធ្វើដំណើរចុងក្រោយយ៉ាងសុវត្ថិភាព នៅក្នុងសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់។

ប្រេងពិសេសមួយទៀតគឺប្រេងគ្រីស្មា ដើម្បីតែងតាំងគង្វាលព្រះសហគន៍

មានលោកអភិបាលថ្មី និងលោកបូជាចារ្យ ដោយចាក់ប្រេងលាបលើក្បាល និងដៃទាំងពីររបស់បេក្ខជន ដើម្បីបង្ហាញថា ដៃទាំងពីរនោះជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់គឺដៃរបស់លោកបូជាចារ្យប្រើសម្រាប់ប្រទានពរក្នុងព្រះនាមព្រះជាម្ចាស់។ ហើយប្រេងនេះ ក៏ប្រើសម្រាប់ពិធីសម្ពោធព្រះវិហារថ្មីលើតុសក្ការៈដែលតំណាងឲ្យព្រះយេស៊ូ។ ដូច្នេះហើយ នៅពេលយើងចាប់ផ្តើមអភិបូជា លោកបូជាចារ្យឡើងលើអាសនៈដោយថើបឬសំពះតុសក្ការៈដែលផ្ទាំងថ្មដ៏រឹងមាំគឺជាព្រះគ្រីស្តតែម្តង។

របៀបប្រសិទ្ធពរលើប្រេងគ្រីស្មា គឺត្រូវយកប្រេងអូលីវ កូរលាយជាមួយប្រេងក្រអូប ព្រោះប្រេងគ្រីស្មាត្រូវមានក្លិនក្រអូបដែលជាក្លិនរបស់ព្រះគ្រីស្តដែលនាំយើងទៅជាគ្រីស្តបរិស័ទ ជាបូជាចារ្យ ជាព្យាការី និងទៅជាស្តេច។ ដោយសារប្រេងគ្រីស្មា យើងចូលរួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធព្រះយេស៊ូគ្រីស្ត និងព្រះបិតាដែលជាព្រះត្រៃឯក៕



# ជំនួបលោករវាងលោកប្រ៊ុយណូ កូសម៌ និងលោកកាឌីណាល់ តាក់ឡេនៅទីក្រុងរ៉ូម

*អត្ថបទ៖ អត្ថបទ៖ ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកភូមិភាគកំពង់ចាម*

លោកប្រ៊ុយណូ កូសម៌ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ទទួលបានការអនិញ្ញាតពី លោក កាឌីណាល់ លូស៊ី អន់តូនីញ៉ូ តាកឡេ(Cardinal Lugi Antonio Tagle) ប្រមុខនៃក្រសួងប្រកាស់ដំណឹងល្អដល់ប្រជាជាតិទាំងឡាយ (The Congregation for the Evangelization of Peoples ) ដើម្បីចូលជួប សម្តែងការគួរសមសួរសុខទុក្ខ និងសំណេះសំណាលការងារ កាលពីថ្ងៃពុធ ទី៣០ ខែ មិថុនា ឆ្នាំ២០២១ នៅទីក្រុងរ៉ូម បុរីវ៉ាទីកង់។

លោកអភិបាលប្រ៊ុយណូ កូសម៌ បានឲ្យដឹងថា៖ «គោលបំណងសំខាន់ នៃជំនួបនេះ គឺដើម្បីសួរសុខទុក្ខ បង្ហាញខ្លួន បង្ហាញពីព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា ជាពិសេសស្ថានភាព និងជីវិតគ្រីស្តបរិស័ទក្នុងព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមសព្វថ្ងៃនេះ។ តាមរយៈលោកកាឌីណាល់ដែលមាននាទីជាប្រមុខ នៃក្រសួងប្រកាស់ដំណឹងល្អដល់ប្រជាជាតិទាំងឡាយ បង្ហាញទៅពិភពលោក ឲ្យបានដឹង និងស្គាល់ព្រះសហគមន៍តូចៗ តាមកន្លែងនីមួយៗក្នុងប្រទេសកម្ពុជា និងភូមិភាគកំពង់ចាម»។

អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម រូបនេះបានបន្ថែមថា៖ «ខ្ញុំបានរៀបចំរបាយការណ៍មួយចំនួនពីសកម្មភាពផ្សេងៗក្នុងភូមិភាគ ចែករំលែក ពិភាគក្សា និងសុំមតិយោបល់ខ្លះៗ ពីលោកកាឌីណាល់ ដើម្បីមានគំនិតថ្មីៗក្នុងកិច្ចការប្រកាស់ដំណឹងល្អ ដើម្បីចែករំលែកទៅលោកបូជាចារ្យ បងស្រី ផ្សេងទៀតនៅប្រទេសកម្ពុជា និងក្នុងភូមិភាគកំពង់ចាម ឲ្យមានកម្លាំងបន្ត ដឹកនាំ ព្រះសហគមន៍កាន់តែរីកចម្រើនទៅមុខ។ បើទោះបីជាប្រទេសកម្ពុជា និងបណ្តាប្រទេសផ្សេងទៀត កំពុងតែរងនូវវិបត្តិជម្ងឺកូវីដ-១៩ និងបញ្ហាផ្សេងទៀតក្តី»៕

# លោកឪពុកវ៉ាំងសង់ សេន័យឆាល់ ជាប្រធានថ្មី ក្រុមសាសនទូតក្រៅប្រទេសនាទីក្រុងប៉ារីស (MEP)

*អត្ថបទ៖ ព្រះសហគមន៍ភូមិភាគភ្នំពេញ*

លោកឪពុក វ៉ាំងសង់ សេន័យឆាល់ កើតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៧។ លោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ នៅភូមិភាគ ម៉ាំង Mans ក្នុងក្រុមសាសនទូតក្រៅប្រទេសនាទីក្រុងប៉ារីស (ហៅកាត់ថា MEP) នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០១ ។

លោកវ៉ាំងសង់ សេន័យឆាល់ ទទួលសញ្ញាប័ត្របណ្ឌិតទេវិទ្យាខាងព្រះគម្ពីរ ពីសាកលវិទ្យាល័យ កាតូលិយ៉េគេ ឡឺវ៉េន (Katholieke Universiteit Leuven) និងវិទ្យាស្ថានកាតូលិក នៅទីក្រុងប៉ារីស (និក្ខេបទបណ្ឌិតរបស់លោកបានបោះពុម្ពផ្សាយនៅឆ្នាំ២០០៩ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយវ៉ល់ធឺ ដឺ ហ្គ្រូអ៊ីធឺ-Walter de Gruyter នៅទីក្រុងប៊ែរឡាំង ប្រទេសអាឡឺម៉ង់)។ លោកឪពុក វ៉ាំងសង់ សេន័យឆាល់ បានមកបំពេញកិច្ចការជាសាសនទូត នៅប្រទេសកម្ពុជា ពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ ២០១៦ ។

ក្នុងរយៈពេលបំពេញបេសកកម្មសាសនទូតនៅកម្ពុជា លោកឪពុក វ៉ាំងសង់ ទទួលខុសត្រូវការងារជាច្រើន ដូចជា៖ បូជាចារ្យជំនួយ បន្ទាប់មកបូជាចារ្យទទួលព្រះសហគមន៍ ជាសាស្ត្រាចារ្យបង្រៀននៅទេវវិទ្យាល័យភ្នំពេញ និងបង្រៀនក្នុងវគ្គបណ្តុះបណ្តាលបងប្អូនគ្រីស្តបរិស័ទឯទៀតៗ លោកក៏ជាអគ្គលេខាធិការ និងជាអធិការបតីរបស់លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ។

ជាមួយគ្នានេះលោកក៏ជាតំណាងព្រះសហគមន៍កាតូលិក នៅក្នុងសមាគមព្រះគម្ពីរកម្ពុជា។ លោកជាសមាជិកនៃគណៈកម្មការអន្តរភូមិភាគបកប្រែសៀវភៅ ពិធីបុណ្យអភិបូជាជាភាសាខ្មែរ ហើយលោកក៏ជាអ្នកទទួលខុសត្រូវ មណ្ឌលនិស្សិតកាតូលិកកម្ពុជាផងដែរ។

លោកឪពុក វ៉ាំងសង់ សេន័យឆាល់ ក៏ជាសាស្ត្រាចារ្យ បង្រៀននៅវិទ្យាស្ថានសន្តសិលានៅបឹងហ្គាល័រ ប្រទេសឥណ្ឌា (Institute Pontifical Saint-Pierre de Bangalore)។

ឆ្នាំ២០១៦ លោកត្រូវបានជ្រើសតាំងជាទីប្រឹក្សាក្រុមសាសនទូត ក្រៅប្រទេសនាទីក្រុងប៉ារីស។ លោកទទួលមុខងារជាអ្នកសម្របសម្រួលការងារទូទៅក្នុងក្រុមសាសនទូត មានដូចជាទំនាក់ទំនង ផ្សព្វផ្សាយ អំពីកិច្ចការសាសនទូតក្រៅប្រទេស ហើយលោកក៏ទទួលខុសត្រូវកិច្ចការផ្សេងៗ ក្នុងព្រះវិហាររបស់សាសនទូត MEP និងនៅវិទ្យាស្ថានសិក្សាស្រាវជ្រាវ បារាំងអាស៊ី ដែលលោកបានក្លាយជាប្រធាននៅក្នុងឆ្នាំ២០២១នេះ។

ពីឆ្នាំ២០១៩ រហូតដល់សព្វថ្ងៃ លោកក៏ជាអ្នកទទួលខុសត្រូវ និស្សិតទេវវិទ្យាល័យរបស់ក្រុមសាសនទូត ក្រៅប្រទេស នាក្រុងប៉ារីស (MEP) ផងដែរ។

ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ លោកឪពុក ហ្ស៊ីល រ៉េស៊ីនហ្គេ (Gilles Reithinger) បានតែងតាំងជាលោកអភិបាលឧបត្ថម្ភកៈនៅភូមិភាគស្រ្តាប៊ួ (Strasbourg) ប្រទេសបារាំង។ លោកឪពុក វ៉ាំងសង់ សេន័យឆាល់ ទទួលមុខងារបន្តពី លោកឪពុក ហ្ស៊ីល រ៉េស៊ីនហ្គេ ជាប្រធានក្រុមសាសនទូតក្រៅប្រទេសនាទីក្រុងប៉ារីស៕



# CSC ភ្នំពេញ ពង្រឹងសមត្ថភាព អ្នករាយការណ៍ព័ត៌មានរបស់ខ្លួនតាមព្រះសហគមន៍

*អត្ថបទ៖ ព្រះសហគមន៍ភូមិភាគភ្នំពេញ*

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកភូមិភាគភ្នំពេញ (CSC Phnom Penh) បណ្តុះបណ្តាលយុវជនអ្នកស្ម័គ្រចិត្តចំនួន២៧រូប ជាបណ្តាញអ្នករាយការណ៍ព័ត៌មាននៅតាមតំបន់សកម្មភាពទាំង៩ ក្នុងភូមិភាគភ្នំពេញ ដើម្បីពង្រឹងសមត្ថភាពក្នុងការសរសេរអត្ថបទព័ត៌មាន និងឲ្យស្គាល់ព្រះសហគមន៍តាមតំបន់របស់ខ្លួនឲ្យកាន់តែច្បាស់។

ការបណ្តុះបណ្តាលនេះធ្វើឡើងនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១ ក្រោមអធិបតីភាពលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយេ ស្មីតហាស្លេរ និងលោក លី សុវណ្ណា ប្រធានការិយាល័យផ្សព្វផ្សាយកាតូលិកកម្ពុជា ជាគ្រូបង្គោល។

លោក ង៉ែត សុធីរិទ្ធ ប្រធានការិយាល័យផ្សព្វផ្សាយកាតូលិកភូមិភាគភ្នំពេញ ប្រកាសពីគោលបំណងនៃសិក្ខាសាលានេះ ព្រមទាំងលើកទឹកចិត្តភ្នាក់ងារគ្រប់រូបក្នុងការចូលរួមប្រមូលព័ត៌មាននិងផ្សព្វផ្សាយបន្ត។ លោកបានលើកយកឃ្លាព្រះគម្ពីរ (រ៉ូម១០, ១៤-១៥) ចែងថា៖ «ឱ្យគេឮដូចម្តេចកើតបើគ្មាននរណាប្រកាស? ឲ្យមានអ្នកប្រកាសដូចម្តេចកើត បើគ្មាននរណាចាត់ឲ្យទៅប្រកាសផងនោះ?»។

លោកប្រធានការិយាល័យបន្តថា ឥលូវយើងមានលោកអភិបាលចាត់យើងឱ្យទៅប្រកាសដោយយើងផ្សាយដំណឹងល្អរបស់ព្រះជាម្ចាស់ គឺជាតួនាទីរបស់យើងជាគ្រីស្តបរិស័ទ។ ដូច្នេះសូមបងប្អូនកុំភ្លេចផ្ញើព័ត៌មានមកយើងដើម្បីផ្សាយដល់ពិភពលោក។

នៅក្នុងកិច្ចស្វាគមន៍នៃការបើកកម្មវិធីការបណ្តុះបណ្តាលនេះ លោកអភិបាលព្រះសហគមន៍ អូលីវីយេថ្លែងលើកទឹកចិត្តដល់បណ្តាញអ្នករាយការណ៍ព័ត៌មានទាំងអស់ពីបរិយាកាសដែលយើងបានជាប់តាំងពីខែកុម្ភៈកន្លងមក។ យើងបានឃើញជាក់ស្តែងតាមរយៈការផ្សាយពីការិយាល័យផ្សព្វផ្សាយកាតូលិក និងប្អូនៗដែលនៅក្នុងសិក្ខាសាលានេះ ចូលរួមចំណែកក្នុងការជួយឱ្យព័ត៌មានទាំងនេះបានទៅដល់បងប្អូនឯទៀត។

លោកថា៖ «ជាក់ស្តែងរាល់ពេលខ្ញុំផ្សាយផ្ទាល់ គឺមិនមែនផ្សាយអភិបូជាសម្រាប់តែចំការទៀង ឬភ្នំពេញប៉ុន្តែយើងផ្សាយដល់ពិភពលោកទាំងមូល»។

លោកអភិបាល អូលីវីយេ បង្ហាញវីដេអូពីសកម្មភាពនានា ដែលក្នុងពេលកន្លងមកក្នុងពេលកូវីដ-១៩ផ្ទុះខ្លាំង អ្វីៗត្រូវបានផ្អាកគ្រប់សកម្មភាពក្នុងប្រទេស តែ ព្រះសហគមន៍មានជីវិតនៅគ្រប់វិស័យទាំងអស់។

លោកបន្តថា៖ «ការិយាល័យ ផ្សព្វផ្សាយព័ត៌មានជាសោរមួយដ៏សំខាន់បំផុត ដើម្បីឱ្យយើងមានទំនាក់ទំនងគ្រប់វិស័យទាំងអស់»។

លោក អភិបាលបញ្ជាក់ទៀតថា អ្វីដែលសំខាន់នៅក្នុងកិច្ចការ អ្នករាយការណ៍ព័ត៌មានតាមកន្លែងនីមួយៗ គឺត្រូវប្រមូលព័ត៌មាន ហើយផ្សព្វផ្សាយបន្ត អំពីជីវិតព្រះសហគមន៍។ អ្នករាយការណ៍ព័ត៌មានទាំងអស់ត្រូវការផ្សារភ្ជាប់ជាមួយព្រះសហគមន៍ជានិច្ចដើម្បីបន្តដំណើរទៅមុខ។

លោកអភិបាលអូលីវីយេ បញ្ជាក់ថា៖ «ប្អូនៗត្រូវយកចិត្តទុកដាក់ផ្សព្វផ្សាយសកម្មភាពព្រះសហគមន៍ជីវិតខាងផ្លូវវិញ្ញាណអប់រំជំនឿ អប់រំសិក្សា និង មេត្តាករុណា។

ក្នុងឱកាសនោះ លោក លី សុវណ្ណា ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកកម្ពុជា និងជាគ្រូបង្គោល ក្នុងការបណ្តុះបណ្តាលនេះក៏បាន ថ្លែងថា ៖ «យើង សរសេរព័ត៌មានពីព្រះសហគមន៍ គឺជាការប្រកាស ជំនឿមួយដែរ ព្រោះថាបងប្អូនបង្ហាញពីសកម្មភាពព្រះសហគមន៍ ដែលបង្ហាញពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដល់បងប្អូនឯទៀតៗ តាមរយៈ អត្ថបទ និងរូបភាពរបស់បងប្អូន»។

ក្រោយបញ្ចប់ការបណ្តុះបណ្តាលថ្ងៃនេះ អ្នកចូលរួម ទាំងអស់ បានឈ្វេងយល់បន្ថែម អំពីតួនាទីរបស់អ្នកសារព័ត៌មានគុណសម្បត្តិរបស់អ្នកសារព័ត៌មាន និយមន័យព័ត៌មាន ការស្វែងរកប្រភពព័ត៌មាន និងគំនិតសរសេរជំហានក្នុងការសរសេរព័ត៌មាន វិធីសាស្រ្តការចាប់យកមុំក្នុងការសរសេរព័ត៌មានជាដើម៕

# ព្រះសហគមន៍កាតូលិកបាត់ដំបង ផ្តល់សម្ភារថែទាំសុខភាពនិងទឹកបរិសុទ្ធ ដល់មណ្ឌលចត្តាឡីស័កស្រុករតនៈមណ្ឌល

*អត្ថបទ៖ សេង ស្រីមួយ*

នាព្រឹកថ្ងៃទី០៧ ខែកក្កដា នេះ ព្រះសហគមន៍កាតូលិកបាត់ដំបង ដឹកនាំដោយបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកបាត់ដំបង និងក្រុមការងារ បាននាំយកសម្ភារមួយចំនួនដែលមាន ម៉ាស់ចំនួន៥០០០ម៉ាស់, ទឹកបរិសុទ្ធចំនួន៥០យួរ និងទឹកអាល់កុលចំនួន២កាន ជូនដល់មណ្ឌលចត្តាឡីសក័ស្រុករតនៈមណ្ឌល តាមរយៈមន្ទីរធម្មការ និងសាសនាខេត្តបាត់ដំបង។



ក្នុងពិធីប្រគល់នេះ លោកម៉ានុច កុមារឯកា ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកបាត់ដំបង បានលើកឡើងថា អំណោយទាំងនេះត្រូវបានផ្តល់ជូន តាមការស្នើពីមន្ទីរធម្មការ និងសាសនាខេត្តបាត់ដំបង ហើយក្នុងនាមព្រះសហគមន៍បាត់ដំបងក៏បានរៀបចំជូនដល់មន្ទីរដើម្បីចាត់ចែក សម្រាប់ប្រើប្រាស់នៅក្នុងមណ្ឌលចត្តាឡីស័កដែលកំពុងខ្វះខាតផងដែរ។

ស្របពេលជាមួយគ្នានោះដែរ លោក គុណ សម្បត្តិមុនីរតន៍ ប្រធានមន្ទីរធម្មការ និងសាសនាខេត្តបាត់ដំបង ក៏បានមានប្រសាសន៍ថា៖ «ក្នុងនាមមន្ទីរដែលតែងតែយកជំនួយទាំងឡាយ ចុះទៅដល់មូលដ្ឋានមណ្ឌលចត្តាឡីស័ក ហើយជំនួយដែលបានមកពីព្រះសហគមន៍កាតូលិកបាត់ដំបងនេះ គឺបំរុងយកទៅខាងមណ្ឌលចត្តាឡីស័កស្រុករតនៈមណ្ឌល»។





នៅមណ្ឌលចត្តាឡីស័កស្រុករតនៈមណ្ឌល មានពលករ អ្នកចំណាកស្រុក ត្រឡប់មកពីប្រទេសថៃ ដែលត្រូវបានដាក់ឱ្យធ្វើចត្តាឡីស័កជាច្រើននាក់។

បើតាម លោក គុណ សម្បត្តិមុនីរតន៍ ក្នុងស្រុករតនៈមណ្ឌលនេះ ក៏ត្រូវបានរៀបចំជាទីតាំងដាក់បូជាសពអ្នកស្លាប់ដោយជំងឺកូវីដ១៩ផងដែរ ដូច្នេះហើយកន្លែងនោះជាតំបន់ដែលមានហានិភ័យច្រើន និងកំពុងខ្វះខាតផងដែរ។





លោកបានមានប្រសាសន៍ថា ៖ «នៅកន្លែងបូជាសព ក្រុមការងារកំពុងខ្វះខាតម៉ាស់ និងទឹកអាល់កុល និងខាងមណ្ឌលចត្តាឡីស័កវិញតម្រូវការចាំបាច់ជារៀងរាល់ថ្ងៃនោះគឺទឹកបរិសុទ្ធសម្រាប់ប្រើប្រាស់»។

លោកប្រធានមន្ទីរធម្មការ និងសាសនាខេត្តបាត់ដំបងរូបនេះ បានថ្លែងអំណរគុណចំពោះព្រះសហគមន៍កាតូលិកបាត់ដំបង ដែលតែងតែចូលរួមចំណែកជួយ និងឧបត្ថម្ភដល់មន្ទីររបស់លោកនាពេលកន្លងមក។

គួរបញ្ជាក់ផងដែរថា នេះជាលើកទី២ហើយ ដែលព្រះសហគមន៍កាតូលិកបាត់ដំបងបានផ្តល់អំណោយជាម៉ាស់ និងទឹកអាល់ជូនដល់ខាងមន្ទីរធម្មការ និងសាសនាខេត្តបាត់ដំបង៕

# ព្រះសហគមន៍កាតូលិកប៊ូស្រា រៀបចំពិធីជ្រមុជទឹក និងលាបថ្ងាសជូនបងប្អូន ក្រោយថាន លើកពេលជាច្រើនលើកច្រើនសារ





*អត្ថបទ៖ ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកភូមិភាគកំពង់ចាម*

ដោយសារតែវិបត្តជម្ងឺកូវីដ-១៩ លោកបូជាចារ្យ ទទួលខុសត្រូវ ព្រះសហគមន៍ប៊ូស្រា បានផ្អាក និងលើកពេល ធ្វើអគ្គសញ្ញាជ្រមុជទឹកជូនបងប្អូនដែលបានត្រៀមជាយូរឆ្នាំ គឺបានខកខានពីមួយឆ្នាំទៅមួយឆ្នាំ។ ប៉ុន្តែកាលពីពេលថ្មីៗនេះការទន្ទឹងរង់ចាំរបស់បងប្អូនបានមកដល់ គឺ បេក្ខជនជាមនុស្សពេញវ័យ និងកុមារមួយចំនួនតូចបានទទួលអគ្គសញ្ញាជ្រមុជទឹក និងលាបថ្ងាសយ៉ាងស្ងៀមស្ងាត់។ អ្នកចូលរួម មានតែបេក្ខជន បងធម៌ និងលោកបូជាចារ្យតែប៉ុណ្ណោះ។

ពិធីនេះប្រព្រឹត្តទៅកាលពីថ្ងៃព្រហស្បតិ៍ ទី ០១ ខែ កក្កដា ឆ្នាំ ២០២១ ដោយលោកបូជាចារ្យហ្វ្រង់ស័រ អេមេល្យូដាល បូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍កាតូលិកប៊ូស្រា ស្ថិតនៅក្នុងភូមិ ឡាំមេះ ឃុំ ប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។

លោកហ្វ្រង់ស័រ អេមេល្យូដាល បានឲ្យដឹងថា៖«បេក្ខជនទាំងនោះបានរៀនអប់រំជំនឿ គេត្រៀមចិត្តត្រៀមកាយ ដើម្បីក្លាយជាគ្រីស្តបរិស័យូរហើយ ប្រមាណជិត២ឆ្នាំ ក្នុងនោះក៏មានបងប្អូនថ្មីៗជាច្រើននាក់ផងដែរ កំពុងរងចាំអគ្គសញ្ញាជ្រមុជទឹកនេះ»។

លោកបូជាចារ្យបន្តថា ដោយមានការយល់ព្រមនិងអនុញ្ញាតពីលោកអភិបាល តាមការស្នើសុំជាច្រើនខែកន្លងមកទើបលោក និងគណៈកម្មការព្រះសហគមន៍ សម្រេចចិត្ត រៀបចំឲ្យបងប្អូនបានទទួលអគ្គសញ្ញាជ្រមុជទឹក ដោយគោរពតាមការណែនាំរបស់ក្រសួងសុខាភិបាល គឺធ្វើម្តងតែ៤ទៅ៥នាក់តែប៉ុណ្ណោះ។

លោកបន្ថែមថា សព្វថ្ងៃបងប្អូនដែលត្រៀមទទួលអគ្គសញ្ញាជ្រមុជទឹកចំនួន៣៧នាក់ក្នុងឆ្នាំ២០២។ បេក្ខជនចំនួន១២នាក់ហើយបានទទួលអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាលាបថ្ងាសនៅព្រះសហគមន៍កាតូលិកប៊ូស្រា អ្នកទាំងនោះជាបងប្អូនជនជាតិដើមភាគតិចពូណង(ព្នង)។

លោកបូជាចារ្យហ្វ្រង់ស័រ អេមេល្យូដាល បានដាស់តឿន ដល់គ្រីស្តបរិស័ទទាំងអស់ កុំឲ្យអស់សង្ឃឹម! កុំធ្លាក់ទឹកចិត្ត! ក្រោកឡើងខំតស៊ូជាមួយស្ថានភាពដែលយើងកំពុងជួប កុំឲ្យយើងរស់ក្នុងសភាពភ័យខ្លាចខ្លាំងពេក តែត្រូវមានរបៀបក្នុងការការពារខ្លួន។

លោកសង្កត់ធ្ងន់ថា៖ «ទោះជាយ៉ាងណាសូមបងប្អូនកុំភ្លេចខ្លួន ថាយើងជានណា? ត្រូវរក្សាជំនឿយ៉ាងណា? សូមរកវិធីដើម្បីអាចចូលរួមអភិបូជាថ្ងៃអាទិត្យបាន ដោយដាក់វេនគ្នា ដើម្បីកុំឲ្យមានគ្នាច្រើន។ កុំរសាយចិត្ត ត្រូវអត់ធ្មត់ អធិដ្ឋាន បន្តសកម្មភាពធម៌មេត្តាករុណាជាពិសេសសូមទុកចិត្តទៅលើព្រះជាម្ចាស់ និងផ្ញើជីវិតទាំងស្រុងទៅព្រះអង្គ កុំឲ្យយើងរស់នៅក្នុងប្រអប់ដែលពោពេញដោយភាពភ័យខ្លាច»។

គិតរហូតមកដល់ពេលនេះគ្រីស្តបរិស័ទក្នុងព្រះសហគមន៍កាតូលិកប៊ូស្រា មានចំនួនជាង២៥០នាក់។ បងប្អូនដែលកំពុងស្វែងរកយល់ ជំនឿ ទាំងមនុស្សពេញវ័យ និងកុមារមានប្រមាណជាង៥០នាក់៕



ក្រសួងសុខាភិបាល

# គោលការណ៍អនុវត្តសម្រាប់អ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ

ដាក់ខ្លួននៅដាច់ដោយឡែកពីគ្រួសារ នៅក្នុងបន្ទប់
-មានខ្យល់ចេញចូលល្អ
-មានបន្ទប់ទឹក /បង្គន់ខាងក្នុង

មណ្ឌលប្រតិបត្តិការស្រុក-ខណ្ឌ
សម្រាប់ព្យាបាលជំងឺកូវីដ-១៩ តាមផ្ទះ

បរិភោគអាហារ និង ប្រើប្រាស់
សម្ភារៈបរិក្ខារដាច់ដោយឡែកពីគ្រួសារ

-ខ្ចប់សំណល់ពីការប្រើប្រាស់ ក្នុង
ស្បោងប្លាស្ទិកឱ្យបានត្រឹមត្រូវ
-ដាក់ដាច់ដោយឡែកពីសំរាមរបស់
សមាជិកគ្រួសារដទៃទៀត
-ទុកឱ្យមានសុវត្ថិភាពរយៈពេល
៧២ម៉ោងមុននឹងយកទៅដាក់
នៅកន្លែងប្រមូលសំរាម

ពាក់ម៉ាសជាប់ជានិច្ច

លាងដៃជាមួយអាល់កុល ឬ
ជាមួយសាប៊ូនិងទឹក ជាប្រចាំ

រក្សាគម្លាតពីសមាជិកគ្រួសារ
យ៉ាងតិច ២ ម៉ែត្រ
បើត្រូវពិភាក្សាគ្នា

បើមានសញ្ញាអាសន្ន ត្រូវចាប់
ទាក់ទងមកគ្រូពេទ្យព្យាបាល
សញ្ញាអាសន្នមាន៖
-ហត់ ឬ ពិបាកដកដង្ហើម
-ឈឺទ្រូងខ្លាំង និង ភ្លាមៗ
-វង្វេងស្មារតី(ទើបកើតថ្មីៗ)
-បាត់មាត់បាត់ក
-បញ្ហាសុខភាពផ្លូវចិត្តធ្ងន់ធ្ងរ

តាមដានសុខភាពផ្ទាល់ខ្លួន
(វាស់កំដៅរៀងរាល់ព្រឹក និង ល្ងាច)

ថែរក្សាសុខភាពផ្លូវកាយ
និង ផ្លូវចិត្ត

រក្សាទំនាក់ទំនងជាមួយគ្រូពេទ្យ
ព្យាបាលតាមរយៈទូរសព្ទ ឬ
បណ្ដាញសង្គមរាល់ថ្ងៃ

បរិភោគអាហារដែលមានជីវជាតិ
គ្រប់គ្រាន់

ហាមជក់បារី ផឹកស្រា ឬ
គ្រឿងស្រវឹងផ្សេងៗ

សម្រាប់ព័ត៌មានបន្ថែមអំពីការព្យាបាលជំងឺកូវីដ-១៩ នៅតាមផ្ទះ
សូមទាក់ទងទៅទូរសព្ទទាន់ហេតុការណ៍
1222 **ដោយឥតគិតថ្លៃ**